ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 28-Aug-2012, 09:22
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២**

**ម៉ោង ០៩:០៣ នាទី**

**សវនាការលើកទី១០២**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោក ដាវ អានសាន

លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារារស្មី

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់*(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ

*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក វ៉ែន ពៅ

លោក គឹម ម៉េងឃី

លោក ឡៅ ជុនធី

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms. Christine MARTINEAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក ច័ន្ទ តារាវស្មី | ខ្មែរ |
| លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្ទាឯល | បារាំង |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ហ្សាស្តេ ប៉ៅ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោក អែម អឿន (TCCP-28) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី: លោក អែម អឿន ហៅ អៀប ឡុន** (TCCP-28)

សួរដោយលោក ច័ន្ទ តារាស្មី ផ្តើមពី៖ ........................................ទំព័រ ៣
សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្តើមពី៖ ........................................ទំព័រ ២៣
សួរដោយលោក ហ្សាស្តេ ប៉ៅ ផ្តើមពី៖ ........................................ទំព័រ ៥៨

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៣:៣០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅក្នុងកិច្ចដំណើរការសវនាការពិភាក្សាដេញដោលនៅព្រឹកនេះ អង្គជំនុំជម្រះនឹងបន្តស្ដាប់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី អែម អឿន ដែលនឹងបន្តការតាំងសំណួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា។ មុនផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា លោកដាវ អានសាន ឡើងរាយការណ៍ អំពីស្ថានភាពវត្តមាន អវត្តមានភាគីនិងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន។ នៅក្នុងសវនាការនាព្រឹកថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២ នេះ គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះមានវត្តមាន។ លើកលែងតែជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ ជនជាប់ចោទ អៀង សារី បាន -- តាមរយៈមេធាវីរបស់គាត់ បានស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់នៅចំពោះមុខអង្គជំនុំជម្រះ សម្រាប់រយៈពេលពេញ១ថ្ងៃនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់គាត់បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ដោយឡែក សាក្សីបម្រុងដែលមានរហស្សនាម TCW-480 មានវត្តមាននៅក្នុងអ.វ.ត.ក យើង ហើយកំពុងតែត្រូវបានរៀបចំធ្វើសម្បថ។ សូមអរគុណលោកប្រធាន។

[០៩:០៥:២៤]

**ប្រធានអង្គជំនុំ៖**

អរគុណ។ តទៅនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់លោក អៀង សារី។ អង្គជំនុំជម្រះសាលាដំបូង បានទទួលសំណើរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២ តាមរយៈមេធាវីការពារក្ដីរបស់គាត់ សុំលះបង់សិទ្ធិមានវត្តមាននៅក្នុងសវនាការ ដោយសុំនៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមប្រព័ន្ធសោតទស្សន៍ សម្រាប់រយៈពេលដំណើរការសវនាការពេញ១ថ្ងៃនេះ។

លោកវេជ្ជបណ្ឌិត លីម ស៊ីវុតថា គ្រូពេទ្យទទួលពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅមន្ទីរឃុំឃាំងនៃ អ.វ.ត.ក បានពិនិត្យសុខភាពរបស់លោក អៀង សារី នៅព្រឹកនេះ ហើយបានកត់សម្គាល់ឃើញថា លោក អៀង សារី មានអាការៈអស់កម្លាំងខ្លាំង ឈឺចង្កេះពិបាកអង្គុយ និងបានផ្តល់អនុសាសន៍ថា អង្គជំនុំជម្រះគួរអនុញ្ញាតឲ្យគាត់នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់មួយខាងក្រោមសាលសវនាការនេះ។

[០៩:០៦:២១]

អង្គជំនុំជម្រះយល់ឃើញថា នៅពេលនេះលោក អៀង សារី ដែលបានលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ គាត់មានបញ្ហាសុខភាពដូចគ្រូពេទ្យបានកត់សម្គាល់ តែរូបកាយនិងស្មារតីសមស្រប គាត់អាចចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ ហើយក៏អាចសម្រួលទំនាក់ទំនងរវាងគាត់ជាមួយនឹងក្រុមមេធាវីការពារក្តីរបស់គាត់បានដែរ។

អង្គជំនុំជម្រះសម្រេចយល់ព្រម តាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងកិច្ចដំណើរការសវនាការ នៅក្នុងបន្ទប់សវនាការនេះដោយផ្ទាល់ ដោយឲ្យលោក អៀង សារី នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលធ្វើសវនាការពេញ១ថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់លោក អៀង សារី អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់អំឡុងពេលធ្វើសវនាការសម្រាប់ថ្ងៃនេះ។

[០៩:០៧:២៤]

ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ ហើយមុននឹងផ្តល់ សូម -- អង្គជំនុំជម្រះសូមរំឭកដល់តំណាងសហព្រះរាជអាជ្ញា ក៏ដូចជាភាគីដទៃទៀតដែលមានការពាក់ព័ន្ធក្នុងការតាំងសំណួរដល់សាក្សីរូបនេះ អ៎! ដល់ដើមបណ្តឹងរដ្ឋប្បវេណីនេះ គួរតែត្រូវបានគិតគូរពិចារណា នូវកម្រិតនៃសំណួរទាំងឡាយណាដែលពាក់ព័ន្ធនឹងអង្គហេតុ ដែលអង្គជំនុំជម្រះបានបំបែកមកធ្វើសវនាការកម្រិតក្នុងសំណុំរឿង០០២/០១ បានហើយ ចៀសវាងការចេញឆ្ងាយពីអង្គហេតុដែលបានកំណត់សម្រាប់ធ្វើសវនាការនេះ។ សូមមានការចាប់អារម្មណ៍លើចំណុចនេះឲ្យខ្លាំង ដើម្បីបង្កើននូវប្រសិទ្ធភាពនៃកិច្ច

ដំណើរការសវនាការរបស់យើង។

អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា។ សូមអញ្ជើញ!

[០៩:០៨:៣០]

**លោក ច័ន្ទ តារាស្មី៖**

បាទ ខ្ញុំសូមគោរពលោកប្រធាន! សូមគោរពលោក លោកស្រីចៅក្រម! សូមគោរពអង្គសវនាការទាំងមូល!

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** លោកសាក្សី អែម អឿន ខ្ញុំសូមជម្រាបសួរ។ ខ្ញុំឈ្មោះ ច័ន្ទ តារាស្មី ជាសហព្រះរាជអាជ្ញារងជាតិនៅសាលាក្តីខ្មែរក្រហមនេះ ហើយនិងសូមអនុញ្ញាតសួរលោកទាក់ទងនឹងសំណួរមួយចំនួននៅក្នុងពេលនេះ។ ជាបឋម គឺខ្ញុំសូមសួរលោកព្រឹត្តិការណ៍នៅក្នុងឆ្នាំមួយពាន់ -- មុនឆ្នាំ១៩៧៥ គឺមុនខែមេសា ឆ្នាំ១៩៧៥។ សូមលោកជួយបញ្ជាក់ថា តើពេលណា កាលបរិច្ឆេទច្បាស់លាស់ តើពេលណាដែលលោកបានចូលរួមនៅក្នុងចលនាបដិវត្តន៍?

**លោក អែម អឿន៖**

**ឆ៖** សូមជម្រាបសួរ។ ទាំងអស់ដែលលោកសួរខ្ញុំ ខ្ញុំបាននិយាយខាងដើមរួចថា កាលបរិច្ឆេទច្បាស់លាស់ ខ្ញុំហាក់ដូចអត់មាន ព្រោះការប្រើ ប្រើតាំងពីខ្ញុំនៅតូច។

**ស៖** បាទ សូមអរគុណ។ តើនៅក្នុងឯកសារលោកបាន -- ធ្លាប់បានបញ្ជាក់ថា លោកបានចូលរួមនៅក្នុងចលនានេះចាប់តាំងពីឆ្នាំ១៩៦៩។ តើមែនដែរឬទេបាទ យោងតាមឯកសារដែលលោកបានឆ្លើយនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត?

**ឆ៖** បាទ ពាក្យហ្នឹងគឺ ជាពាក្យពិតរបស់ខ្ញុំហើយ។

**ស៖** បាទ តើលោកបានចូលរួមក្នុងចលនាបដិវត្តន៍នុ៎ង តើលោកបានដឹងអ្វីខ្លះអំពីចលនាបដិវត្តន៍នោះបាទ?

**ឆ៖** សូមបញ្ជាក់លោក ខ្ញុំសូមបញ្ជាក់ថា បើសិនជាសួរតាមលំហានៃការនៃសួរ ខ្ញុំពិបាកឆ្លើយព្រោះការធ្វើវាវែងឆ្ងាយ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវី!

[០៩:១០:៥២]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់ដែលមានវត្តមាននៅទីនេះ។ ខ្ញុំក្រោកឈរនេះ គឺព្រោះថាដោយសារទៅនឹងសំណួរមុននោះ ខ្ញុំយល់ថា សហព្រះរាជអាជ្ញាគាត់យោងទៅលើឯកសារមួយដែលជាភាសាបារាំងនោះ គឺជាកំណត់ហេតុៗស្ដាប់ចម្លើយសាក្សី ក៏ប៉ុន្តែតាមពិតទៅដូចជាអត់មានៗកំណត់ហេតុស្ដាប់ចម្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតទេ។ ដូច្នេះ ខ្ញុំចង់ដឹងថា តើគាត់យោងទៅលើកំណត់ហេតុស្ដាប់ចម្លើយណា ព្រោះថាដើមបណ្ដឹងរដ្ឋប្បវេណីនេះ អត់មានកំណត់ហេតុស្ដាប់ចម្លើយទេ?

[០៩:១១:៣២]

**លោក ច័ន្ទ តារាស្មី៖**

សូមជម្រាបលោកស្រីមេធាវី ខ្ញុំសូមបញ្ជាក់ម្ដងទៀត គឺយោងទៅលើឯកសារ D22/3963 ឯកសារនេះ គឺជាទម្រង់បែបបទព័ត៌មានជនរងគ្រោះបាទ។ នៅក្នុងឧបសម្ព័ន្ធ “ក”។ បាទ សូមបញ្ជាក់ឯកសារហ្នឹង ហើយសូមកែតម្រូវថា គឺទម្រង់បែបបទជនរងគ្រោះបាទ។

សូមអរគុណលោកប្រធាន ខ្ញុំសូមអនុញ្ញាតសួរទៅលោកសាក្សី។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** លោកសាក្សី សូមលោកជួយបញ្ជាក់ នៅពេលដែលលោកបានចូលរួមក្នុងចលនាបដិវត្តន៍នៅក្នុង -- ចាប់ពីឆ្នាំ១៩៦៩ តើលោកអាចចងចាំបានទេ អំពីសកម្មភាពសំខាន់ៗរបស់បដិវត្តន៍ តើគេបានធ្វើអ្វីខ្លះ? ហើយលោកបានចូលរួមនិងធ្វើអ្វីខ្លះនៅក្នុងពេលនោះបាទ?

[០៩:១២:៤១]

**លោក អែម អឿន**

**ឆ៖** ខ្ញុំសូមជម្រាបលោកសហព្រះរាជអាជ្ញា ពាក្យនេះដូចខ្ញុំថាអំមិញ ថាបើបញ្ជាក់ហេតុផលច្បាស់ទៅវាទាល់តែនិយាយវែង ព្រោះតាមការធ្វើរបស់ខ្ញុំវាវែងឆ្ងាយណាស់ ព្រោះខ្ញុំតាំងពីដឹងក្ដីធ្វើតាមការងារនេះរហូត។ តែប្រធានបទនៃការនិយាយអាចបាននិយាយខ្លះ និយាយបានខ្លះត្រង់ចំណុចណា

ដែលខ្ញុំចាំ។ សូមលោកប្រធានសួរចុះបាទ។

**សៈ** បាទ អរគុណ។ ទាក់ទិននឹងបញ្ហាបក្សកុម្មុយនីស្តកម្ពុជា តើលោកបានដឹងអ្វីខ្លះអំពីបក្សកុម្មុយនីស្តកម្ពុជាបាទ? សូមលោកជួយបញ្ជាក់ខ្លឹមសារសំខាន់ៗ និងអ្វីដែលលោកបានចងចាំបាទ?

**ផៈ** បាទ សូមគោរពសាធារណៈទាំងអស់។ ត្រង់នេះ ខ្ញុំបាទសូមបញ្ជាក់ពីខាងដើម គោលការណ៍នៃការបង្កើតបក្សកុម្មុយនីស្តនៅកម្ពុជាដែលស្ថិតនៅលើក្នុងកម្ពុជា ដែលជាហេតុដំបូងតាមខ្ញុំដឹងតាមវ័យរបស់ខ្ញុំផ្ទាល់តែម្តង គឺការចាប់កសាង ចាប់ផ្តើមដំបូងគឺគេចម្រាញ់យកជនណាដែលស្រឡាញ់បដិវត្តន៍ ហៅថា "ស្រឡាញ់បដិវត្តន៍"។ និយាយឲ្យខ្លីគឺ "ស្រឡាញ់លទ្ធិក្រហម" ហ្នឹងឯង។

[០៩:១៣:៥៧]

អ៊ីចឹងរូបភាពដំបូងបង្អស់គេ ស្រាវជ្រាវបុគ្គលណាដែលមានធ្វើចំណេញដល់ផលប្រយោជន៍របស់គេ ដែលគេត្រូវការ ហើយអ្នកដែលធ្វើបានកាតព្វកិច្ច គេថា តាមការត្រូវការនោះ បើសិនអ្នកនុ៎ងបំពេញអ្វីមួយបានមានស្នាដៃល្អ គេនឹងដាក់បញ្ចូលបុគ្គលនោះទៅជាជនចម្រើន បើសិនជាយុវជនខាងណាជនចម្រើន។ ហើយបើជាជនទូទៅហៅថា ប្រជាជន ទូទៅគេហៅ ជនចម្រើនដូចគ្នា ប៉ុន្តែដល់ -- បើក្រៅពីលើសពីជនចម្រើនទៅ វាចូលដូចខ្ញុំជាយុវជននៅពេលនោះ គឺខ្ញុំចូលជាសម្ព័ន្ធយុវជននេះឯង។ ហ្នឹងហៅ "សម្ព័ន្ធយុវកក" លោកប្រធាន។

**សៈ** បាទ សូមអរគុណ។ ចុះបក្ស -- ចុះចលនាហ្នឹងគឺកើតមានដោយសារតែមានគោលការណ៍ និងទ្រឹស្តីនេះកុម្មុយនីស្ត តើលោកបានចងចាំ លោកបានដឹងអ្វីខ្លះអំពីកុម្មុយនីស្តបាទ? និយាយជាទូទៅ តើកុម្មុយនីស្តហ្នឹង គេបង្កើតឡើងក្នុងគោលបំណងអី ហើយតាមការយល់ដឹងរបស់លោកនៅក្នុងសម័យកាលនោះ តើកុម្មុយនីស្តហ្នឹងសំដៅលើសកម្មភាពបែបណាបាទ?

**ផៈ** បាទ ខ្ញុំសូមនិយាយត្រង់ហ្នឹង បំណងនៃកុម្មុយនីស្ត ខ្ញុំមិនបានដឹងថាគោលដៅយ៉ាងណានោះទេ បើសិនជាដឹង ប្រហែលជា ក៏នៅគេចមិនបំផុតនោះមើលទៅ ប៉ុន្តែខ្ញុំសូមនិយាយពីដឹងរបស់ខ្ញុំខ្លះ។ ខាងដើមការចាប់ផ្តើមដំបូងនៃការបង្កើតកុម្មុយនីស្ត ខ្ញុំមើលទៅតាមមូលដ្ឋាន តាមផ្ទះសម្បែង គឺគេបង្កើតមុនគេបង្អស់ គឺបង្កើត គេហៅថា សហគមន៍គាំទ្រ។ រយៈពេលគាំទ្រនោះ គេយកជារឿងពិតគេធ្វើជាអង្ករក្តាប់ ប្រសិនបើបុគ្គលណាមួយតាមគ្រួសារ ដែលចាត់ទុកខ្លួនឯងជាសមាជិកនៃបក្សបដិវត្តន៍នោះហើយ គេត្រូវដាក់អង្ករក្តាប់ បានន័យថា ម៉ាពេលដែលយើងដាំបាយ គឺត្រូវដាច់ខាតយកអង្ករក្តាប់ដាក់ក្នុងស្បោងមួយ ឬក៏ធុងមួយ គេដាក់ទុកថា ដាំមួយពេល ត្រូវក្តាប់មួយដៃដាក់ធុងនោះ

ឯង។ សូមលោកប្រធានជ្រាប បាទ។

[០៩:១៦:០២]

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងការចូលរួមនៅក្នុងចលនាបដិវត្តន៍ និងការចូលរួមនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា តើលោកបានចូលរួមដោយស្ម័គ្រចិត្ត ឬក៏មានអ្នកណាគេមានការបង្ខិតបង្ខំលោក ឬក៏យ៉ាងម៉េចបាទ? មានមូលហេតុអ្វីបានជាលោកចូលទៅក្នុងចលនាបក្សកុម្មុយនីស្តកម្ពុជា និងចលនាបដិវត្តន៍? បាទ សូមអរគុណ។

**ឆ៖** សូមជម្រាបជូន បញ្ហាហ្នឹង ការបញ្ជាក់ថាស្ម័គ្រចិត្ត ឬបង្ខំ ខ្ញុំសូមរឿងពិតថា ពេលនោះខ្ញុំមិនបាន -- មិនមានអ្នកណាបង្ខំទេ ប៉ុន្តែខាងដើមដំបូងទាំងអស់ គឺទៅដំណើរដែលឪពុកខ្ញុំប្រើក្នុងការងាររបស់គាត់។ ឧបមាថា ខ្ញុំត្រូវយកសំបុត្រ យកដំណឹងទៅនេះ ទៅនោះ គឺខ្ញុំធ្វើតាមរយៈនេះឯង។ បាទ សូមជម្រាបលោកប្រធាន។

**ស៖** បាទ ខ្ញុំសូមឆ្លងទៅសំណួរមួយទៀត។ តើនៅក្នុងពេលដែលលោកបានចូលរួមនៅក្នុងចលនាបដិវត្តន៍កម្ពុជា តើលោកធ្លាប់បានជួប ឬក៏បានឃើញ ឬក៏ធ្លាប់បានទាក់ទងជាមួយនឹងមេដឹកនាំនៃចលនាបដិវត្តន៍កម្ពុជា ឬក៏បក្សកុម្មុយនីស្តកម្ពុជាហ្នឹងដែរឬទេបាទ?

[០៩:១៧:១៥]

**ឆ៖** ត្រង់ហ្នឹងខ្ញុំសូមនិយាយប្រាប់លោកឲ្យច្បាស់ថា ខាងដើមឡើយ ខ្ញុំស្ថិតនៅតូច ម្ល៉ោះហើយខ្ញុំមិនស្គាល់ថា អ្នកណាជាអ្នកណាទេ។ តែការជួប ឧស្សាហ៍ជួបជាញឹកញយតាមរយៈឪពុកខ្ញុំប្រើផងតាមរយៈឪពុកខ្ញុំនាំទៅផង។ អ៊ីចឹង ខ្ញុំមិនបានស្គាល់ថា បុគ្គលនោះ ជាអ្នកណាទេ។ ព្រោះពេលនោះគេធ្វើចូលចិត្តបិទមុខ មិនសូវបង្ហាញឈ្មោះទេ លោកប្រធាន។

**ស៖** បាទ លោកអាចបញ្ជាក់បន្ថែមបានទេថា នៅក្នុងចន្លោះ១៩៦៩ ដល់ ១៩៧៥ តើមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាណាខ្លះ ដែលលោកធ្លាប់បានជួប ឬក៏បានឃើញ ឬក៏បានទាក់ទងដោយផ្ទាល់ទេបាទ?

[០៩:១៨:០៣]

**ឆ៖** ត្រង់ហ្នឹង តាមដំណើរពិត ព្រោះឪពុកខ្ញុំផ្ញើ អ៊ំ! ប្រើខ្ញុំ ខ្ញុំប្រើតែតាមរយៈគាត់ធ្វើការជាមួយគឺខ្ញុំឧស្សាហ៍ជួបជាងគេ គឺលោក សោ ភឹម នេះឯង។ បន្ទាប់មកទៀត ជាអ្នកណាៗ ខ្ញុំឧស្សាហ៍ជួបប៉ុន្តែខ្ញុំអត់ស្គាល់គេទេ។ សូមជម្រាបលោកប្រធាន បាទ។

**ស៖** បាទ តើលោកធ្លាប់ជួបលោក សោ ភឹម នៅកន្លែងណា? ហើយជួបហ្នឹង គឺនៅពេលណាដែរ លោកចាំបានទេបាទ?

**ឆ៖** ក្នុងឋានៈខ្ញុំជាអ្នកនាំដំណឹង ក៏ដូចជានីរសារ ខ្ញុំធ្លាប់ជួបកន្លែងនៅផ្ទះរបស់គាត់ ធ្លាប់ជួបនៅកន្លែងធ្វើការរបស់គាត់ ប៉ុន្តែពេលនោះ ភាគច្រើនក្នុងព្រៃ។ បាទ សូមជម្រាបលោកប្រធាន។

**ស៖** បាទ អរគុណ។ តើលោក សោ ភឹម បានបញ្ជាក់ប្រាប់លោកអ្វីខ្លះទេ នៅក្នុងពេលដែលលោកបានជួបគាត់នៅក្នុងសម័យកាលនោះបាទ?

**ឆ៖** ត្រង់ហ្នឹង គាត់បានបញ្ជាក់ ឧស្សាហ៍ប្រាប់ខ្ញុំផ្ទាល់តែម្តង ថាចូលប្អូនប្រឹងប្រែងក្នុងការតស៊ូ ព្រោះយើងមានគោលដៅតែមួយគត់ គឺរំដោះវណ្ណៈ។ ហ្នឹងគឺជាពាក្យលោក សោ ភឹម គឺថា រំដោះវណ្ណៈ តែពេលនោះ ខ្ញុំស្គាល់ថា វណ្ណៈ ពាក្យ “វណ្ណៈ” នោះជាស្អីទេ។ សូមជម្រាបលោកប្រធាន បាទ។

**ស៖** តើពេលនោះ លោក សោ ភឹម លោកបានដឹងទេ ថា លោក សោ ភឹម មានមុខនាទីជាអ្វីបាទ? គាត់កាន់មុខដំណែងនៅពេលនោះ?

[០៩:១៩:៣៨]

**ឆ៖** សូមជម្រាបលោកប្រធាន ត្រង់ហ្នឹង ខ្ញុំសូមបញ្ជាក់ដែរ ខ្ញុំមិនបានដឹងថានាទីគាត់ហ្នឹងជាស្អីទេ ប៉ុន្តែកាលណោះ ខ្ញុំបានដឹង ឮថាឧស្សាហ៍ៗនិយាយ គេហៅថា ផ្នែក។ មានផ្នែក១០, ផ្នែក២០ ផ្នែកអីចឹងទៅ ប៉ុន្តែផ្នែកហ្នឹង ថាជាអីអត់ដឹងទេ។ សូមលោកប្រធានជ្រាប បាទ។

**ស៖** បាទ សូមអរគុណ។ តើចាប់តាំងពីពេលណាដែលលោកបានក្លាយទៅជាសមាជិកយុវកករបស់បក្សកុម្មុយនីស្តកម្ពុជាបាទ?

**ឆ៖** នៅពេលដែលខ្ញុំក្លាយខ្លួនទៅជាសម្ព័ន្ធយុវកកកុម្មុយនីស្តកម្ពុជា នៅប្រហែលជាក្នុងឆ្នាំ៧៣។ សូមជ្រាបលោកប្រធាន។

**ស៖** បាទ សូមអរគុណ។ តើលោកធ្លាប់បានក្លាយជាសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

**ឆ៖** ខ្លួនខ្ញុំត្រង់ហ្នឹងបានក្លាយទៅជាជន -- ជាសមាជិកបក្សកុម្មុយនីស្តកម្ពុជានៅក្រោយៗឆ្នាំ៧៥។ សូមលោកប្រធានជ្រាបបាទ។

**ស៖** តើក្លាយជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាក្រោយឆ្នាំ១៩៧៥នេះ លោកបានចូលក្នុងសមាជិកបក្សហ្នឹងដោយស្ម័គ្រចិត្ត ឬក៏ដោយមានហេតុផលណាផ្សេងទៀតបាទ?

[០៩:២១:០៤]

**ឆ៖** ត្រង់ហ្នឹងជារូបភាពស្ម័គ្រចិត្ត ខ្ញុំយល់ថារូបភាពស្ម័គ្រចិត្ត ប៉ុន្តែក្នុងចន្លោះហ្នឹង ការបញ្ចូលហាក់ដូចគ្រាន់តែបង្គ្រប់បំពេញនៃការត្រូវការរបស់អ្នកប្រើប្រាស់ប៉ុណ្ណោះឯង មើលទៅលោកប្រធានបាទ។

**សៈ** បាទ សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមអនុញ្ញាតឆ្លងទៅប្រធានបទមួយទៀត ទាក់ទងទៅនឹងគោលមាគ៌ានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាចំពោះព្រះពុទ្ធសាសនា។ បាទ ប្រធានបទនេះ គឺខ្ញុំសួរលោកទាក់ទងនឹងព្រះពុទ្ធសាសនា។ សូមលោកជួយបញ្ជាក់ថានៅចន្លោះឆ្នាំ១៩៦៩ ដល់ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ តើលោកបានឃើញអំពីចលនាបដិវត្តន៍ហ្នឹង តើគេបានដាក់ចេញនូវគោលមាគ៌ានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា និងមាគ៌ារបស់ចលនាដបិវត្តន៍ហ្នឹងយ៉ាងដូចម្តេចខ្លះ ចំពោះព្រះពុទ្ធសាសនានៅកម្ពុជាសម័យនោះបាទ?

**ឆ៖** សាធុ! ត្រង់ណេះសូម -- ខ្ញុំបាទសូមថ្លែងពីរឿងពិតដែលខ្ញុំឃើញ ចាប់ផ្តើមឃើញដំបូងចំពោះបក្សពេលឱកាសនោះនៅក្នុងសង្គមបដិវត្តន៍កុម្មុយនីស្តកម្ពុជា។ ការចាប់ផ្តើមដំបូង គឺខ្ញុំបានចាំនៅក្នុងអារម្មណ៍របស់ខ្ញុំពីដើមកន្លងមកជាគឺថាជាជនបដិវត្តន៍ ដើម្បីគោលការណ៍ប្រឆាំងនឹងអំពើ គឺថាអំពើហ្វាស៊ីសពុករលួយនោះទេ ព្រោះអង្កាល់នុំងខ្ញុំគ្រាន់ដឹងថា ដឹងថាមានពាក្យហ្នឹង។ ប៉ុន្តែនៅក្នុងឱកាសនោះពាក់ព័ន្ធនឹងផ្លូវសាសនាក្នុងអំឡុងមុនឆ្នាំ១៩៧២ ដូចជាមិនមានសកម្មភាពដាក់សាសនាប៉ុន្មានទេ។ ប៉ុន្តែចាប់ពីឆ្នាំ១៩៧២ រហូតដល់ ៧៥ ហាក់ដូចមានការផ្លាស់ប្តូរជារៀងរហូត។ ខ្ញុំសូមជម្រាបលោកប្រធាន។

[០៩:២២:៥៩]

**សៈ** បាទសូមអរគុណ។ តើការអនុវត្តសាសនាព្រះពុទ្ធនៅពេលនោះមានការហាមឃាត់ ហើយការហាមឃាត់នេះកើតមានដោយសារតែមានការកំណត់នៅក្នុងឯកសារ ឬក៏ការហាមឃាត់ដោយមាត់ទទេបាទ?

**ឆ៖** ត្រង់ណេះលោកប្រធាន បើនិយាយអំពីផ្ទាំងឯកសារ ខ្ញុំនៅក្នុងឆ្នាំ៧២នេះ មិនបានឃើញផ្ទាំងឯកសារអីទេ ប៉ុន្តែខ្ញុំទទួលឥទ្ធិពល ទទួលស្គាល់នេះ គឺតាមដំណើរការធ្វើឃោសនានយោបាយទៅតាមអ្នកដឹកនាំ គេហៅថាកម្មាភិបាលដឹកនាំនេះចូលតែប្រើ -- ចូលចិត្តប្រើពាក្យថា "កុំយកការងារវត្តអារាម ឬការងារព្រះធម៌នេះជាធំស្អី បើនិយាយពីលោកសង្ឃ បើបួសទៅជាលោកសង្ឃធ្វើឲ្យខាតពេល

នេះមួយ ធ្វើឲ្យខាត បើយើងមើលឲ្យខ្លីទៅ គឺខាត។ ខាតអ្វី? គឺខាតសម្លៀកបំពាក់ធំជាងបង្អស់ មួយ, មួយទៀត ខាតមនុស្ស មិនអាចចូលរួមក្នុងចលនាបដិវត្តន៍បាន ទី៣ ទី២, ទី៣ គឺខាតពេលវេលាដែលយើងក្នុងជីវិតមិនព្រមជួយរំដោះជាតិ បែរទៅជាអ្នកឯងធ្វើលោកទៅវិញ”។ នេះគឺជាភាសារបស់អ្នកដឹកនាំបាទ។ សូមលោកប្រធានជ្រាបបាទ។

[០៩:២៤:២៤]

**ស៖** បាទ សូមអរគុណ។ ហេតុអ្វីបានជាមានការហាមឃាត់ តើលោកធ្លាប់បានដឹងឮទេថាមានគេនិយាយប្រាប់ទេអំពីមូលហេតុអ្វី បានជាគេហាមឃាត់មិនឲ្យមានការគោរពបូជាផ្នែកព្រះពុទ្ធសាសនា?

**ឆ៖** ខ្ញុំបានបញ្ជាក់អំមិញហើយថា ភាសាថាគោលបំណងអី ព្រោះខ្ញុំមិនទាន់បានជ្រាបអីនៅឡើយទេ ប៉ុន្តែគេបានបញ្ជាក់គ្រាន់ថា បញ្ជាក់ទៅ បួសនាំតែខាតពេល បួសនាំខាតបាយ បួសនាំតែខាតសម្លៀកបំពាក់។ ហ្នឹងសូមលោកប្រធានជ្រាបបាទ។

**ស៖** បាទ សូមអរគុណ។ នៅក្នុងទម្រង់បែបបទព័ត៌មានជនរងគ្រោះ លោកបានបញ្ជាក់ថា “ការគោរពសាសនា គឺត្រូវបានបក្សកុម្មុយនីស្តកម្ពុជា ចាត់ទុកថាជាសត្រូវ”។ តើមែនដែរឬទេបាទ?

**ឆ៖** នៅមុនឆ្នាំ១៩៧២ មិនមានបញ្ហាហ្នឹងកើតឡើងទេ តែក្រោយមកនៅឆ្នាំ១៩៧២ បក្សបដិវត្តន៍កុម្មុយនីស្តកម្ពុជានេះ ហាក់ដូច មិនមែនហាក់ទេ គឺការពិត មានបំណងប្រឆាំងសាសនាផ្ទាល់តែម្តង ព្រោះគេមិនដែលឃើញគុណបំណាច់ ឬគុណប្រយោជន៍របស់សាសនាឡើយ។ សូមលោកប្រធានជ្រាបបាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវី!

[០៩:២៦:០៣]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសោកស្តាយណាស់ដែលបានកាត់ផ្តាច់ជាថ្មីម្តងទៀត គឺពាក់ព័ន្ធទៅនឹងបញ្ហានៃល្បឿននៃការសួរ និងការឆ្លើយ ជាភាសាបារាំង គឺភាគច្រើននោះ យើងតែងតែទទួលបានចម្លើយសាក្សីនៅពេលដែលសហព្រះរាជអាជ្ញា គាត់សួរសំណួរមួយទៀត។ ដូច្នេះ ខ្ញុំសូមឲ្យសហព្រះរាជអាជ្ញាបន្ថយល្បឿនបន្តិច ហើយសូមសម្រាកបន្តិច មុននឹងសួរសំណួរថ្មីមួយទៀតនោះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយច្រើនលើកច្រើនសាហើយ គួរតែអាចចងចាំ ព្រោះសំណើសុំនេះមិនតិចជាងដប់ដងទេ បញ្ហាភាសាបារាំង ដែលមិនអាចបកប្រែបាន ហើយពិសេសអំឡុងពេលនៃការដេញវាងភាគីជាតិ និងសាក្សី ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីជាតិនេះ គឺមានបញ្ហា។ អ៊ីចឹងសូមចាប់អារម្មណ៍ចំណុចនេះឲ្យខ្លាំង ហើយជាអចិន្ត្រៃយ៍តទៅ ទី១។ បញ្ហាទី២ សូមរំឭកតំណាងសហព្រះរាជអាជ្ញាថា ការធ្វើទុក្ខបុកម្នេញខាងសាសនាមិនមែនជាកម្មវត្ថុនៃអង្គហេតុ ដែលសម្រាប់យកមកធ្វើសវនាការដេញដោលនៅក្នុងសំណុំរឿង០០២/០១ ទេ។ កំហិតត្រឹមតែការធ្វើទុក្ខបុកម្នេញខាងនយោបាយ។ កម្រិតត្រឹមតែផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១និងទី២។ អ៊ីចឹងហើយបានជាយើងអំមិញបានរំឭកថា ការរៀបចំនូវសំណួរគប្បីគិតពិចារណាកំហិតត្រឹមតែវិសាលភាពនៃអង្គហេតុទាំងឡាយណា ដែលអង្គជំនុំជម្រះបានកំណត់យកមកឲ្យពិភាក្សាដេញដោលនៅក្នុងក្របខ័ណ្ឌនៃសំណុំរឿង០០២/០១។ នៅក្នុងនោះគឺបានបង្ហាញទាំងផ្នែកអង្គច្បាប់ផង ផ្ទុះបញ្ជាំងអំពីគោលបំណងនៃការដេញដោលនេះ ដើម្បីផ្ទុះបញ្ជាំងទៅនឹងបទល្មើសមួយចំនួន ដែលពាក់ព័ន្ធនៅក្នុងដីកាដំណោះស្រាយ ដែលយើងកំណត់បញ្ចូលបំបែកយកមកធ្វើសវនាការនៅក្នុងសំណុំរឿង០០២/០១។ ដោយការពិនិត្យនូវប្រតិចារឹកឡើងវិញ កាលពីធ្វើសវនាការសប្តាហ៍មុន កត់សម្គាល់ឃើញថា ការសួរដេញដោលដោយក្រុមមេធាវីការពារ -- នាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានអង្គហេតុ មានសំណួរជាច្រើនក្រៅអង្គហេតុ។ អ៊ីចឹងហើយបានជារំឭកបញ្ហានេះ។ យើងព្យាយាមមិនកាត់ទេ យើងព្យាយាមរំឭក។

[០៩:២៨:៥៥]

**លោក ច័ន្ទ តារាស្មី៖**

បាទ អរគុណលោកប្រធាន។ ប្រធានបទដែលខ្ញុំសួរអំមិញ គឺទាក់ទិននឹងមាគ៌ានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ចំពោះព្រះពុទ្ធសាសនា ហើយបើតាមខ្លឹមសារនៃដីកាដំណោះស្រាយនេះ គឺមានផ្នែកនៃនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាហ្នឹង ពាក់ព័ន្ធនឹងសាសនាដែរ។ ដោយហេតុផលនេះហើយបានជាខ្ញុំលើកឡើង ដើម្បីបញ្ជាក់ចំពោះជនរងគ្រោះរូបនេះ ឲ្យដឹងអំពីតើមាគ៌ានយោបាយហ្នឹងមានដំណើរការយ៉ាងដូចម្តេចនៅក្នុងពេលនោះបាទ។ ឥឡូវខ្ញុំសូមអនុញ្ញាតបន្តទៅប្រធានបទថ្មី។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** លោក អែម អឿន ខ្ញុំសូមសួរលោកទាក់ទងនឹងការបណ្តុះបណ្តាលពេទ្យ នៅទីក្រុងភ្នំពេញ

ម្តងបាទ ការបណ្តុះបណ្តាលពេទ្យទីក្រុងភ្នំពេញនោះ។ តើលោកអាចបញ្ជាក់បានទេថា ក្រោយពេលដែលលោកមកដល់ទីក្រុងភ្នំពេញ លោកបានទទួលការបណ្តុះបណ្តាលហ្នឹង ប្រើពេលរយៈពេលប៉ុន្មាននៅក្នុងការបណ្តុះបណ្តាលវិជ្ជាពេទ្យនៅទីក្រុងភ្នំពេញនោះបាទ? គឺក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥។

**ឆ៖** ត្រង់ហ្នឹងខ្ញុំបានបញ្ជាក់ពីម្សិលមិញថា រយៈពេលដែលខ្ញុំមាននាទីមកនៅទីក្រុងភ្នំពេញគឺរយៈពេល១ឆ្នាំ។ នោះគឺជាក្របខ័ណ្ឌ ប៉ុន្តែដំណើរដែលមកនៅបាន បានប្រហែលជា៩ខែ ទៅ១០ខែប៉ុណ្ណោះ មិនបាន១២ខែទេលោកប្រធាន។

**ស៖** បាទ អរគុណ។ តើលោកធ្លាប់បានធ្វើកិច្ចការនៅក្នុងតំបន់២០ ដែលលោកបានមានប្រសាសន៍កាលពីសប្តាហ៍មុនហ្នឹង តើលោកធ្វើកិច្ចការអ្វីសំខាន់នៅក្នុងទីនោះបាទ?

**ឆ៖** ក្នុងឱកាសធ្វើការនៅក្នុងតំបន់២០ ជាជំហានដែលការធ្វើការរបស់ខ្ញុំដំបូង គឺខ្ញុំក្នុងឋានៈជាយុវជនផង ក្នុងឋានៈជាពេទ្យផង។ ដូច្នេះកាតព្វកិច្ចរបស់ខ្ញុំ គឺធ្វើពីរនេះឯង គឺពេទ្យផង ខាងយុវជនផង។ ហ្នឹងសូមលោកប្រធានជ្រាបបាទ។

[០៩:៣១:០០]

**ស៖** បាទ តើលោកធ្វើការនៅតំបន់២០ហ្នឹងរយៈពេលប៉ុន្មានដែរបាទ?

**ឆ៖** ក្នុងតំបន់២០ ដូចខ្ញុំបានជម្រាបហើយ គឺថាខ្ញុំធ្វើការរហូតពីដឹងក្តីមក ធ្វើក្នុងតំបន់ហ្នឹងរហូត។ ប៉ុន្តែរយៈពេល ខ្ញុំមិនបានកំណត់បាន ព្រោះថាខ្ញុំធ្វើការពេលនោះមិនបានគិតថា យើងធ្វើដើម្បីអី? ធ្វើទៅណាទេ? តែខ្ញុំគ្រាន់តែមានទស្សនៈមួយ ធ្វើដើម្បីបម្រើជាតិនោះឯង។ អ៊ីចឹងការ ដូច្នេះការកំណត់ពេលវេលា ខ្ញុំមិនបានគិតទុកជាមុនថាត្រូវកត់ ឬក៏ត្រូវទុកអីយ៉ាងណា? ដូច្នេះ បើសិនជាខ្ញុំលើកមកនិយាយក្នុងឱកាសហាក់ដូចជាខ្ញុំមិននិយាយរឿងពិត។ អ៊ីចឹង ខ្ញុំសូមរក្សាធាតុពិតរបស់ខ្ញុំត្រង់ណាសូមលោកបាទ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសួរទៅលើលោកបន្តទៀត ទាក់ទងនឹងព្រឹត្តិការណ៍នៅក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥។ សូមលោកជួយបញ្ជាក់ថា តើការចូលរៀនពេទ្យនៅទីក្រុងភ្នំពេញ គឺនៅពេទ្យខ្មែរ-សូវៀត ហ្នឹងតើមានអ្នកចូលរួមរៀនហ្នឹងប៉ុន្មាននាក់ ពេលដែលគេរៀនជាមួយលោកនោះបាទ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន។ ត្រង់ណោះ ខ្ញុំមិនដឹងចំនួនច្បាស់ ប៉ុន្តែមើលទៅការប៉ាន់ស្មាន គឺមិនតិចជាង១ពាន់ បើតិចៗតួចវាអាច។ សូមជម្រាបលោកប្រធានបាទ។

[០៩:៣២:៣០]

**សៈ** តើសិស្សដែលបានចូលរៀនពេទ្យនោះ ពួកគេអញ្ជើញមកពីតំបន់ផ្សេង និងភូមិភាគផ្សេងៗ ក្នុងគ្រប់ទីកន្លែងនៅក្នុងប្រទេសកម្ពុជា ឬក៏យ៉ាងណាបាទ?

**ឆៈ** ត្រង់នេះ លោកប្រធាន បើតាមៗគោលការណ៍ក្នុងការអញ្ជើញពី ពីមជ្ឈិមទៅ គឺអញ្ជើញថ្នាក់តំបន់ បានន័យថាក្នុងមន្ទីរតំបន់ គឺយកអ្នកជំនាញ អ្នកដែលគួរទុកចិត្តបានយកពីរនាក់ ហ្នឹងមួយ។ មួយទៀតតាមក្រសួងមន្ទីរទាំងអស់នៅក្នុងកម្ពុជាទាំងមូល និងភូមិភាគទាំងមូល គឺយកប្រធាន អនុប្រធាននោះឯង។ ការពិតគឺបើសិនជាមិនមែនជាប្រធានទេ ឲ្យអ្នកនោះទទួលនាទីជាបច្ចេកទេស ហ្នឹងទើបមានសិទ្ធិចូល លោកប្រធាន សូមជម្រាបច្បាស់បាទ។

**សៈ** បាទ សូមអរគុណ។ តើសិស្សដែលគេមករៀនពេទ្យនៅពេទ្យខ្មែរ-សូវៀតនោះ ពួកគេមានជំនាញ មានការយល់ដឹង មានចំណេះដឹងអំពីជំនាញខាងពេទ្យហ្នឹង ពីមុនរួចជាស្រេច ឬក៏យ៉ាងណាបាទ?

**ឆៈ** ខ្ញុំសូមជម្រាបលោកប្រធានបានធ្វើសំណួរត្រង់ណោះ។ មានន័យថា ការចូលមកសិក្សានៅក្នុងគេហៅថា ពេទ្យ១៧មេសា គឺជាពេទ្យរបស់មជ្ឈិម។ អ៊ីចឹងការឡើងមក អ្នកត្រូវបញ្ជូនមក យកតែអ្នកដែលបានចេះស្រាប់ហើយ ដើម្បីមកបំពេញបន្ថែម។ អ៊ីចឹងអ្នកទាំងអស់នោះ ចេះទាំងមើលជំងឺ ចេះទាំងវះកាត់។ អ្នកដែលមករៀន គ្រាន់តែមានឈ្មោះថាមកបំពេញប៉ុណ្ណោះឯង។ សូមលោកប្រធានជ្រាបបាទ។ គឺមានតែប៉ុណ្ណឹងលោកប្រធាន។

[០៩:៣៤:៣៦]

**សៈ** បាទ សូមអរគុណ។ តើសិស្សដែលចូលរៀនវិជ្ជាពេទ្យនោះ គិតជាមធ្យមតើគេមានអាយុប្រហែលពីប៉ុន្មាន ដល់ប៉ុន្មានបាទ?

**ឆៈ** បើខ្ញុំមើលទៅ ប៉ាន់ស្មាន ខ្ញុំប៉ាន់មើលទៅមនុស្សដែលចូលរៀន សិក្សាៗរៀនសូត្រនោះ គេធ្វើទៅតាមដំណើរ ដែលអ្នកធ្វើបានហើយ គឺភាគច្រើន គឺអាយុចាប់ពី២០ឡើង។ បាទ សូមជ្រាប។ គឺមនុស្សទាំងអស់នោះ ចាប់ពីអាយុ២០ទៅ បានន័យថាអ្នកនោះចេះវះកាត់ស្រាប់ ចេះនយោបាយផង ហើយភាគច្រើន ខ្ញុំសូមបញ្ជាក់ឲ្យហើយថា ភាគច្រើនគេចាប់បញ្ជូនមនុស្សជាសម្ព័ន្ធយុវជននេះឯងឡើងទៅរៀនបាទ។ ហ្នឹងសូមជ្រាបបាទ។ មានប៉ុណ្ណឹងលោកប្រធាន ចង់បញ្ជាក់សួរទៀតចុះបាទ។

**សៈ** បាទ សូមអរគុណ ខ្ញុំសូមសួរបន្តទៀត។ តើកូនសិស្ស សិស្សដែលមករៀនវិជ្ជាពេទ្យនោះ មានការរើសចេញមកពីកូនកសិករ កូនកម្មករ កូនកម្មាភិបាល ឬក៏កូនមកពីវណ្ណៈសង្គមថ្នាក់ផ្សេងណា

ដែរឬទេ?

[០៩:៣៦:០៥]

**ឆ៖** ត្រង់ហ្នឹង ខ្ញុំមើលទៅតាមការជួបប្រទះផ្ទាល់តែម្តង មើលទៅហាក់ដូចជាគេមិនរើសវណ្ណៈទេ តែមើលទៅភាគច្រើនៗជាកម្មាភិបាល និងកូនកម្មាភិបាល។ សូមលោកប្រធានជ្រាប។

**ស៖** សូមអរគុណ។ តើលោកអាចបញ្ជាក់បានទេអំពីរចនាសម្ព័ន្ធរបស់មន្ទីរពេទ្យបាទ នៅក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ គឺមន្ទីរពេទ្យខ្មែរ-សូវៀតនោះ ដែលលោកបានធ្លាប់បានចូលរៀននៅទីនោះបាទ?

**ឆ៖** ត្រង់ហ្នឹង ព្រោះថាខ្ញុំមិនមែនជាអ្នកធ្វើការនៅក្នុងៗមន្ទីរពេទ្យ គឺគ្រាន់តែមាននាទីមួយ ជាសិស្ស ដើម្បីបំពេញវិជ្ជាទេ។ ដូច្នេះរចនាសម្ព័ន្ធ ខ្ញុំហាក់ដូចជាមិនបានដឹងអស់ទេបាទ លោកប្រធានជ្រាបបាទ។

**ស៖** សូមអរគុណ។ តើលោកអាចបញ្ជាក់បានទេថា តើពេលនោះអ្នកណាខ្លះជាអ្នកដឹកនាំមន្ទីរពេទ្យខ្មែរ-សូវៀត? ហើយមន្ទីរពេទ្យខ្មែរ-សូវៀតហ្នឹង មានបែងចែកជាផ្នែកអីខ្លះបាទ?

**ឆ៖** ក្នុងមន្ទីរពេទ្យនោះ តាមមើលទៅលក្ខណៈជំងឺ គេបែងចែកច្រើនដែរ លោកប្រធាន ដែលសូមនិយាយតាមដំណើរដែលឃើញច្បាស់ថា ឯខ្ញុំកាត់ចិត្តថាប៉ុន្មានចំនួននោះ មិនបានច្បាស់ទេ។ ខ្ញុំសូមនិយាយឈ្មោះតែម្តង។ ខ្ញុំសូមលោកប្រធានរើសយកចុះថា គោលការណ៍នៃការបង្កើតហ្នឹង គេមានឯកទេសរបស់គេ គឺខ្ញុំពិនិត្យមើលទៅ ឯកទេសហ្នឹងវះកាត់ ជំហានដំបូង ជំងឺស្ត្រី ជំងឺទូទៅ ជំងឺធ្មេញ ជំងឺៗហៅថា ជំងឺៗសរសៃសាស្ត្រផ្សេង ជំងឺក្នុងនោះផ្សេង។ មានន័យថាជំងឺវះកាត់នោះ គឺជំងឺរបួសផ្សេង ជំងឺទូទៅផ្សេង។ សូមលោកប្រធានជ្រាប។

[០៩:៣៨:១១]

ហើយក្នុងហ្នឹងគេបែងចែកជាពីរ។ មួយ មន្ទីរកន្លែងអគាររបស់កម្មាភិបាល។ ពីរ គឺអគាររបស់រដ្ឋការ អាហ្នឹងថា អ្នកធ្វើការក្នុងៗជួរបក្ស។ ទីបី គឺក្នុងចំណោមប្រជាជន និងកម្មករ ដែលស្ថិតនៅក្នុងទីក្រុងភ្នំពេញ។ សូមលោកប្រធានជ្រាបបាទ។

**ស៖** បាទ តើលោកអាចបញ្ជាក់បានអំពីឈ្មោះរបស់អ្នកដឹកនាំមន្ទីរពេទ្យខ្មែរ-សូវៀតនៅសម័យនោះបានដែរឬទេបាទ?

**ឆ៖** ត្រង់ហ្នឹងខ្ញុំសូមបញ្ជាក់លោកប្រធានថា តាមការដឹង ដំណើរដែលខ្ញុំដឹងពិតហ្នឹង គឺអ្នកដឹក

នាំក្នុងមន្ទីរពេទ្យនោះ គឺអ្នកស្រី ឡេង សី ហ្នឹង ជាមួយអ្នកស្រី យុន យ៉ាត ហើយទទួលខុសត្រូវធំជាងគេគឺលោក ជួន ជឿន។ ឯវេជ្ជបណ្ឌិតបង្រៀន គឺខ្ញុំមិនបានចាំឈ្មោះអស់ទេ ព្រោះគាត់ទៅតាមត្រង់ណាថាជំងឺគ្រុញចាញ់ គាត់មានវេជ្ជបណ្ឌិតម្នាក់ ជំងឺរះកាត់ គាត់មានវេជ្ជបណ្ឌិតម្នាក់ ហើយជំងឺទូទៅ គាត់មានវេជ្ជបណ្ឌិតម្នាក់។ ការពិតទៅក្នុងការសិក្សាទៅតាមជំនាញ។ បើចូលតាមជំងឺអី គឺវេជ្ជបណ្ឌិតនោះមកតែម្តង។ សូមលោកប្រធានជ្រាបបាទ។

[០៩:៣៩:៤៤]

**ស៖** បាទ សូមអរគុណ។ សូមលោកជួយបញ្ជាក់ថា តើមន្ទីរពេទ្យខ្មែរ-សូវៀត នៅក្នុងសម័យនោះស្ថិតនៅក្រោមការគ្រប់គ្រងការត្រួតពិនិត្យ ការដឹកនាំរបស់ក្រសួងណាមួយបាទ?

**ឆ៖** ក្នុងនាទីខ្ញុំដឹងតាំងពីមកមូលដ្ឋាន ខ្ញុំដឹងនៅមូលដ្ឋានថា ផ្នែកពេទ្យគឺទទួលខុសត្រូវ មានអ្នកដឹកនាំគឺសង្គមកិច្ច និងសុខាភិបាល សូមលោកប្រធានជ្រាបបាទ។

**ស៖** សូមអរគុណ។ តើលោកអាចបញ្ជាក់បានទេថា ក្រសួងសង្គមកិច្ចនៅពេលនោះ អ្នកណាគេជារដ្ឋមន្ត្រី ហើយពីណាគេជាអនុរដ្ឋមន្ត្រីដែលគ្រប់គ្រងមន្ទីរពេទ្យនោះ? អ៊ីចឹងទៅក្រសួងសង្គមកិច្ចហ្នឹង អ្នកណាគេជារដ្ឋមន្ត្រី ហើយមានអ្នកណាគេជាអនុរដ្ឋមន្ត្រី គឺអនុរបស់រដ្ឋមន្ត្រីនោះបាទ?

[០៩:៤០:៥០]

**ឆ៖** ពេលនោះលោកប្រធាន ខ្ញុំសូមជម្រាបទុកជាមុនហើយថា ខ្ញុំមិនបានវែកញែកថាអ្នកណាប្រធាន អ្នកណាអនុ ខ្ញុំមិនបានច្បាស់ទេ។ តែគ្រាន់តែដឹងថា អ្នកដែលធ្វើនោះ មន្ទីរទទួលនាទីខុសត្រូវ គឺអ្នកធំជាងគេនោះគឺខាងក្រសួងសង្គមកិច្ច។ អ៊ីចឹងលោកប្រធានថា អ្នកណាធ្វើសង្គមកិច្ច ដូចខ្ញុំថាអំមិញលោកដឹងហើយ។ បន្ទាប់មកលោក ជួន ជឿន នេះគឺជាខាងសុខាភិបាល។ អ៊ីចឹងសូមលោកប្រធានជ្រាប បានន័យថាសុខាភិបាលទទួលបន្ទុកខាងពេទ្យ ទាំងជំងឺ ទាំងថ្នាំពេទ្យហ្នឹង សូមលោកជ្រាប។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងបានន័យថា លោកបានអត់បានចាំ ឬក៏បានស្គាល់ពីណាគេរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចទេ មែនដែរឬទេបាទ?

**ឆ៖** ត្រង់ហ្នឹងខ្ញុំមិនបានស្គាល់ទេ លោកប្រធាន បាទ។

**ស៖** សូមអរគុណ។ តើលោកអាចបញ្ជាក់បានទេថា នៅពេលដែលលោករៀននៅមន្ទីរពេទ្យខ្មែរ-សូវៀតនោះ តើលោកធ្លាប់បានឃើញមេដឹកនាំណាមកចូលរួមប្រជុំនៅក្នុងមន្ទីរពេទ្យនោះ ជាមួយនឹងសិស្សដែលរៀនពេទ្យនោះដែរឬទេ?

[០៩:៤២:២០]

**ឆ៖** ត្រង់ហ្នឹង ខ្ញុំសូមបញ្ជាក់ប្រាប់លោកប្រធានថា ការស្គាល់ថាអ្នកណាជាអ្នកចូលរួមប្រជុំដឹកនាំនោះ ខ្ញុំហាក់ដូចមិនបានជួបទេក្នុងមន្ទីរពេទ្យ។ ប៉ុន្តែនៅក្នុងឱកាសនោះ សូមបញ្ជាក់លោកប្រធានងាយយល់ថា នៅពេលនោះខ្ញុំមានឱកាស មានសិទ្ធិឡើងមករៀននយោបាយនៅក្នុងបុរីកីឡាម្តង រយៈប្រហែលជា៧ថ្ងៃ សូមលោកប្រធានជ្រាបបាទ។

**ស៖** សូមអរគុណ។ តើលោកធ្លាប់បានចូលរួមប្រជុំនៅក្នុងកិច្ចប្រជុំ ដែលរៀបចំដោយមន្ទីរពេទ្យ ឬក៏ក្រសួងសង្គមកិច្ចដែរឬទេ?

**ឆ៖** ក្នុងពេលវេលានោះ សូមជម្រាបលោកប្រធានឲ្យច្បាស់ថា ខ្ញុំមិនដែលបានចូលរួមប្រជុំទេ។ មូលហេតុដែលមិនបានចូលរួមប្រជុំហ្នឹង ដោយសារខ្ញុំហ្នឹងរវល់ជាប់នៅក្នុងឋានៈជាសិស្ស គឺប្រឹងរៀនផង ហើយក្នុងឋានៈជាខ្លួនឯងប្រធានសិស្ស ក៏ប្រឹងប្រែងមើលការខុសត្រូវអ្នកធ្វើការនេះឯង ព្រោះខ្លាចៗមានទោសដល់ខ្លួន លោកប្រធាន បាទ។

**ស៖** សូមអរគុណ បាទ។ នៅពេលដែលលោកកំពុងរៀននៅក្នុងមន្ទីរពេទ្យនោះ តើលោកធ្លាប់បានឮអ្នកដឹកនាំមកនិយាយប្រាប់លោកអ្វីខ្លះ ចំពោះសិស្ស ឬនឹងរូបលោកផ្ទាល់នៅពេលដែលកំពុងរៀននៅក្នុងមន្ទីរពេទ្យខ្មែរ-សូវៀតនោះ?

**ឆ៖** ត្រង់ហ្នឹងខ្ញុំសូមបញ្ជាក់លោកប្រធាន ប្រាប់ថា ជម្រាបលោកប្រធានថា ចំណុចដែលពិសេស ដែលខ្ញុំចងចាំមិនបាត់ទេ គឺការសិក្សា គឺអ្នកដឹកនាំនៅពេលនោះ ភាគច្រើនគឺគេអប់រំតាមដំណើររបស់បក្ស។ ព្រោះខ្ញុំជាសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជា អ៊ីចឹងគេតែងតាំងខ្ញុំទៅធ្វើប្រធានសិស្សដើម្បីពង្រឹងអ្នកចូលសិក្សា។ គោលការណ៍ទាំងអស់ គេបង្ហាញ បង្ហាត់បង្ហាញពីតួនាទីរបស់ខ្លួនឲ្យច្បាស់ថា បើមិត្តធ្វើអី ចូរអ្នកមិត្តស្គាល់ឲ្យច្បាស់ការងាររបស់ខ្លួន ធ្វើអីឲ្យស្គាល់ហ្នឹង បើសិនជាអស់លោកអស់មិត្តធ្វើមិនបាន មិត្តនឹងទទួលខុសត្រូវការងារដែលលោកធ្វើ។ អ៊ីចឹង គេមិនមែនហៅលោកណ៎ា គេហៅតែមិត្ត។ អ៊ីចឹងសូមលោកប្រធានជ្រាបថា ការធ្វើការងារកាលនោះ ខ្ញុំមិនបានពិចារណាហេតុផលទាំងអស់នេះឡើយ ខ្ញុំគ្រាន់តែយកចិត្តទុកដាក់អំពីការងាររបស់ខ្ញុំថា ធ្វើអី ទទួលស្គាល់នោះឯង។

[០៩:៤៥:០៦]

អ៊ីចឹងការអប់រំរបស់បក្សនៅសម័យនោះគឺគិតអំពី ទី១ បើអ្នករៀន ពេទ្យគឺត្រូវចេះពេទ្យ។ បើអ្នកទទួលតួនាទីខាងនយោបាយផងនោះ ត្រូវអ្នកស្គាល់កាន់តែខ្លាំងឡើង គឺស្គាល់ខាងនយោបាយ គឺត្រូវ

ធ្វើអី? អ៊ីចឹងឱកាសនោះ គឺខ្ញុំតែងតែពង្រឹងបុគ្គលដែលជាសមាជិករបស់ខ្លួនដើម្បីគេចឲ្យផុតអំពីដំណើរដែលបក្សស្តីបន្ទោសនោះ។ សូមលោកប្រធានជ្រាបបាទ។

**ស៖** បាទ សូមអរគុណ។ តើជាទូទៅការរៀបចំកិច្ចប្រជុំនៅមន្ទីរពេទ្យខ្មែរ-សូវៀត រៀបចំដោយមានបញ្ហាពីខាងណាបាទ? ហើយប្រធានបទសំខាន់ គឺជាទូទៅនិយាយពីរឿងអ្វី?

**ឆ៖** ត្រង់ហ្នឹងខ្ញុំសូមបំបែកឲ្យជ្រាបទុកជាមុន គឺថាបំបែកទុកជាពីរ គឺថាការងាររបស់ខ្ញុំទី១ គឺអប់រំសិស្សផ្នែកនយោបាយ ទី២ គឺអប់រំសិស្សខាងផ្នែកបច្ចេកទេស។ អ៊ីចឹងសូមលោកប្រធានជ្រាបថាការងារពីរនេះនិយាយខុសគ្នា។ ទី១ យើងអប់រំអំពីសិស្សដែលជាសមាជិករបស់សម្ព័ន្ធយុវកកក៏ដោយ សមាជិកបក្សក៏ដោយ ចូរអ្នកដឹងតួនាទីអំពីការងាររបស់ខ្លួនថាបក្សធ្វើអ្វី? ហើយជនកុម្មុយនីស្តធ្វើអីខ្លះ? ដើម្បីរីកចម្រើនឲ្យទាន់ដំណើរការកិច្ចការនយោបាយដែលផ្លាស់ប្តូរថា ផ្លាស់ប្តូរទៅជាសង្គម កុម្មុយនីស្តមហាលោតផ្លោះ មហាអស្ចារ្យ តើខ្លួនឯងជាសមាជិកបក្សត្រូវធ្វើអីខ្លះ? ហើយមិត្តឯងបំពេញការងារពេទ្យ តើពេទ្យត្រូវយកចិត្តទុកដាក់យ៉ាងម៉េច? តែការសង្កត់ធ្ងន់ គឺក្នុងដំណើរនោះខ្ញុំចាំបាន យល់ថា (ឮមិនច្បាស់)របស់គេលើកឡើងថា "ចូរអ្នកគោរពបក្សឲ្យបានម៉ឺងម៉ាត់ បើបក្សថាធ្វើអីគឺធ្វើនោះ មិនអាចក្បត់បក្សបានឡើយ ទោះបីអ្នកឯងជាស្អីក៏ដោយ"។ នេះខ្ញុំសូមជម្រាបលោកប្រធានបាទ។

[០៩:៤៦:00]

**ស៖** បាទ អរគុណ។ កាលពីសប្តាហ៍មុនលោកបានមានប្រសាសន៍ថា ធ្លាប់មានការចាប់ខ្លួននៅក្នុងមន្ទីរពេទ្យខ្មែរ-សូវៀត។ តើលោកអាចបញ្ជាក់បានទេថា តើរាល់ពេលប្រជុំមានគេនិយាយប្រាប់អំពីការចាប់ខ្លួននេះជូនដល់សមាជិកអង្គប្រជុំក្នុងសម័យនោះដែរឬទេ? តើគេនិយាយពីរឿងអ្វីខ្លះបាទ?

**ឆ៖** ត្រង់ហ្នឹងខ្ញុំសូមៗឆ្លើយទៅតាមសំណួរដែលលោកបានសួរ។ អ៊ីចឹងហេតុទាំងអស់នេះ ខ្ញុំជាស្អីក៏ដោយខ្លាចប៉ះណាស់ចំពោះប្រធានបទ អ៊ីចឹងខ្ញុំគ្រាន់ចង់សួរថា អ៎! សុំឆ្លើយថា ឱកាសនោះក្នុងតួនាទីរបស់ខ្ញុំជាអ្នកនយោបាយដែរ ខ្ញុំក៏ខ្លាចណាស់ពាក្យមួយម៉ាត់ថា "ធ្វើកុំឲ្យបំពានភារកិច្ច" អ៊ីចឹងពេលនោះ ថ្ងៃនោះក៏បានដឹងថា អ្នកដែលដឹកនាំបក្សក៏ធ្លាប់បានបង្រៀនខ្ញុំដែរ នៅក្នុងឱកាសខ្ញុំសិក្សារៀនពេទ្យនេះ គឺបាននិយាយពីតួនាទី វណ្ណៈធ្វើបដិវត្តន៍។ អ៊ីចឹង កិច្ចការទាំងអស់នេះខ្ញុំបាទមិនមែនថា មិនដឹងទេ ដឹង ប៉ុន្តែដឹងទី១ ដឹងដោយឃើញរូបភាពនឹងភ្នែក។ ពីរទៀត ដឹងឮទៅតាមការខ្សឹបខ្សៀវគ្នានៅពេលឱកាសស្លាត់ណាស់ អង្គាល់នុំងប្រហែលជាអស់លោកបានដឹងហើយ ធ្លាប់បានចូល ការងារ ធ្លាប់ដឹងហើយថា ទៅធ្វើអ្វីត្រូវគិតអ្វីនិយាយអីទៅតាមដំណើរបក្សប្រើ បើបក្សមិនប្រើអ្នកកុំធ្វើ កុំស្តាប់បញ្ជា

របស់អ្នកណាឲ្យសោះ។ ដូច្នេះ ហេតុផលដឹងបានត្រឹមដឹង ហើយការដេញដោលខ្ញុំមិនប៉ានដេញដោលទេ លោកប្រធាន ដូច្នេះសូមលោកដឹង។ បាទសូមអរគុណ។

[០៩:៤៩:០៧]

**ស៖** បាទ សូមអរគុណ។ តើនៅក្នុងពេលប្រជុំដែលលោកធ្លាប់បានចូលរួម តើលោកធ្លាប់បានឮមេដឹកនាំ ឬក៏ប្រធានអង្គប្រជុំហ្នឹងបាននិយាយពន្យល់អំពីការចាប់ខ្លួន ឬក៏និយាយអំពីពាក្យថា"ជនក្បត់" ឬក៏សត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជាហ្នឹង នៅក្នុងពេលប្រជុំនោះដែរឬទេ? តើគេមាននិយាយអ្វីខ្លះនៅក្នុងពេលប្រជុំនោះ? អំពីជនក្បត់? អំពីសត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា?

**ឆ៖** សូមទោស សាធារណជនទាំងឡាយ ការនិយាយរបស់ខ្ញុំហាក់ដូចខ្ញុំភ័យ ប៉ុន្តែមិនមែនទេ ខ្ញុំស្ទិតមាត់ មានជំងឺស្ទិតមាត់ និយាយអត់រួច។ អ៊ីចឹងត្រង់នេះ ខ្ញុំសូមបញ្ជាក់ប្រាប់លោកប្រធានថា បើនៅក្នុងមន្ទីរពេទ្យមិនដែលឮប្រធាន -- មិនដែលឮនិយាយនយោបាយពីនេះទេ តែក្នុងឱកាសនេះ បើពេលដែលទៅរៀននៅបុរីកីឡាទើបឮបាទ។ សូមអរគុណ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមសួរសំណួរបន្តទៀត អំពីការចាត់ទុកថាសត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា បញ្ជាឲ្យចាប់ខ្លួន។ តើលោកអាចបញ្ជាក់បានទេថា នរណាគេបញ្ជាឲ្យចាប់ខ្លួនកម្មាភិបាល ឬក៏គ្រូពេទ្យនៅក្នុងពេទ្យខ្មែរ-សូវៀត ដែលលោកធ្លាប់បានចូលរួមរៀនជំនាញពេទ្យនោះបាទ?

**ឆ៖** ត្រង់ហ្នឹងខ្ញុំសូមបញ្ជាក់ថា ឈ្មោះថាចាប់ខ្លួនដឹងមុនថាត្រូវចាប់អ្នកណា អ្នកណាខុស ត្រូវចាប់នោះត្រង់ណោះ ខ្ញុំសូមបញ្ជាក់ប្រាប់លោកប្រធានថា ខ្ញុំមិនបានដឹងជាមុនទេ។ អ៊ីចឹងការឃើញ គ្រាន់តែឃើញ។ ឧបមា ក្នុងនេះបាន -- ខ្ញុំបាននិយាយថា ក្នុងឱកាសខ្ញុំសិក្សានៅទីនោះ ខ្ញុំបានឃើញអ្នកស្រី ទីវ អុល ដែលជាប្រពន្ធរបស់លោក អ៎! អ្នកស្រី ទីវ អុល គឺជាអ្នកស្រី ឡេង សី។ ខ្ញុំគ្រាន់តែដឹងថា អ្នកស្រីនោះគឺជាគ្រូធ្លាប់អប់រំខ្ញុំផ្នែកនយោបាយក៏គាត់ធ្លាប់ ហើយខាងបច្ចេកទេសពេទ្យក៏គាត់ធ្លាប់។ ការពិតក្នុងឋានៈគាត់ជាអ្នកទទួលខុសត្រូវមន្ទីរពេទ្យ។ អ៊ីចឹងហេតុការណ៍ដឹង គឺដឹងទៅតាមការឃើញ ដឹងទៅតាមការឮត្រចៀក ដែលមិត្តភក្តិខ្សឹបខ្សៀវគ្នាប៉ុណ្ណោះឯងលោកប្រធាន។

[០៩:៥១:៤១]

**ស៖** បាទ សូមអរគុណ។ សំណួរបន្តទៀត សុំសួរថា តើលោកបានឃើញការចាប់ខ្លួនមនុស្សនៅក្នុងមន្ទីរពេទ្យនោះ បន្ទាប់មកតើគេចាប់មនុស្សហ្នឹងដាក់ឡាន ឬក៏ដឹកដោយមធ្យោបាយណាមួយផ្សេងទៀត? ហើយតើឡាននោះគឺឡានរបស់អង្គភាពណា ដែលគេដឹកមនុស្សយកចេញពីមន្ទីរពេទ្យនោះ?

**ឆ៖** ត្រង់ហ្នឹងខ្ញុំសូមបញ្ជាក់ប្រាប់រឿងពិតថា ប្រាប់រឿងដែលខ្ញុំឃើញថា អ្នកដែលចាប់នោះ ភាគច្រើនគឺចាប់ ដែលខ្ញុំឃើញចាប់នៅក្នុងមន្ទីរពេទ្យ ហើយអ្នកដែលត្រូវការគេចាប់នោះ ខ្ញុំមិនបានស្គាល់អស់ថាអ្នកនោះជាសិស្សនៅទីនោះ ឬក៏ជាសិស្សទៅពីភូមិភាគ។ ប៉ុន្តែភាគច្រើន ខ្ញុំឃើញបុគ្គលិកនៅទីនោះក៏ចាប់ អ្នកទៅរៀនដូចខ្ញុំក៏ចាប់ ភាគច្រើនឃើញនឹងភ្នែក ដោយចាប់ដាក់ឡាន ឡានរបៀបជាឡានឃោធា។ អ៊ីចឹងថាទៅពីខាងណា ខ្ញុំមិនបានស្គាល់ទេលោកប្រធាន ថាឡានជាឡានអី ព្រោះខ្ញុំមិនបានដេញដោលគេទេបាទ។ សូមទោស។

[០៩:៥៣:០១]

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមឆ្លងទៅសំណួរផ្សេងមួយទៀត។ តើលោកធ្លាប់បានឃើញ បានជួបលោក ប៉ុល ពត, លោក អៀង សារី, លោក ខៀវ សំផន, លោក នួន ជា ដែរឬទេ?

**ឆ៖** លោកទាំងបួនឈ្មោះដែលលោកប្រធានបានសួរនេះ ខ្ញុំបានជួបតែជួបពេលខ្លី គឺជួបពេលខ្លី ហើយពេលតែមួយ គឺជួបនៅសាលានយោបាយបុរីកីឡានេះឯង។ សូមលោកប្រធានជ្រាប។

**ស៖** បាទ អ៊ីចឹងនៅក្នុងមន្ទីរពេទ្យ តើលោកបានឃើញលោក អៀង សារី, លោក ខៀវ សំផន, លោក នួន ជា, លោក ប៉ុល ពត ដែលធ្លាប់ចូលទៅក្នុងមន្ទីរពេទ្យខ្មែរ-សូវៀតហ្នឹងដែរឬទេ? ហើយដែលជួបលោក ឬក៏និស្សិតដែលកំពុងរៀននោះដែរឬទេបាទ?

**ឆ៖** ត្រង់ហ្នឹងខ្ញុំមិនដែលឃើញអស់លោកទាំងប៉ុន្មានឈ្មោះហ្នឹងចូលក្នុងមន្ទីរពេទ្យទេលោកប្រធាន។

[០៩:៥៤:២៤]

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមឲ្យលោកជួយបញ្ជាក់បន្ថែមបន្តិចទៀតថា តើមានឡានរបស់ក្រសួងសង្គមកិច្ច ឬក៏ឡានរបស់មន្ទីរពេទ្យខ្មែរ-សូវៀតហ្នឹង ត្រូវបានគេប្រើសម្រាប់ដឹកជនដែលគេចាប់ខ្លួននោះ ចេញពីមន្ទីរពេទ្យនោះដែរឬទេ? តើលោកធ្លាប់បានឃើញទេបាទ?

**ឆ៖** សូមជម្រាបលោកប្រធាន សំណួរត្រង់នេះ មិនមែនខ្ញុំបដិសេធទេ ប៉ុន្តែការពិតខ្ញុំមិនដែលបានឃើញថា គេចាប់ដាក់ឡានពេទ្យនោះទេ។ ហើយនៅពេលនោះឡានទាំងអស់នេះមានបេសកកម្មទាល់តែមាននាទីរបស់គេចេញ បានគេចេញ ហើយបើឡានពេទ្យ គេបិទឃ្លុប។ ដូច្នេះ មិនបានឃើញអីទាំងអស់លោកប្រធាន។ ហ្នឹងសូមជម្រាបបាទ។

**ស៖** សូមអរគុណ។ សំណួរបន្តទៀត សូមសួរលោកថា ក្នុងឋានៈលោកជាគ្រូពេទ្យនៅក្នុងមន្ទីរ

ពេទ្យខ្មែរ-សូវៀត តើបក្សកុម្មុយនីស្តកម្ពុជាធ្លាប់បានដាក់បទបញ្ជា ជាវិន័យយ៉ាងដូចម្តេចខ្លះ ដែលត្រូវអនុវត្តចំពោះគ្រូពេទ្យ? តួយ៉ាងដូចជារូបលោក និងអ្នកដទៃទៀតក៏ដូចគ្នាដែរបាទ តើមានបទបញ្ជាវិន័យយ៉ាងដូចម្តេចដែលកំណត់ចេញមកពីបក្សកុម្មុយនីស្តកម្ពុជា សម្រាប់អនុវត្តចំពោះគ្រូពេទ្យ?

[០៩:៥៦:១៥]

**ឆ៖** ត្រង់ហ្នឹងខ្ញុំសូមនិយាយរឿងពិត មិនមែនខ្ញុំកាន់ជើងអ្នកណា ឬការពារអ្នកណាឡើយ សូមនិយាយរឿងពិត។ នៅក្នុងការសិក្សានៅក្នុងមន្ទីរពេទ្យសូវៀតនេះ បើនិយាយពីការដឹកនាំរបស់បច្ចេកទេស មិនដែលនិយាយអំពីការធ្វើបាប ធ្វើទុក្ខ ធ្វើទោសដល់អ្នកណាឡើយ។ ពិសេសបំផុតលោកគ្រូទាំងអស់នោះ បង្រៀនខ្ញុំឱ្យស្គាល់ពីតួនាទីខ្លួនឯងជាពេទ្យ។ ពេទ្យត្រូវកាន់ចិត្តជាមនុស្សធម៌លោកប្រធាន អ៊ីចឹងការធ្វើនៅក្នុងមន្ទីរពេទ្យរុស្ស៊ី យើងតែការពិត ការធ្វើយ៉ាងណានោះ ក្នុងជាកិច្ចការរបស់ពេទ្យ ខ្ញុំអត់ដឹងទេ ព្រោះក្នុងៗមន្ទីរពេទ្យ។ បើការងារពេទ្យដល់តំបន់ បានស្គាល់ខ្លះ។ សូមលោកប្រធានជ្រាបបាទ។

**ស៖** បាទ សូមអរគុណ។ សូមលោកជួយបញ្ជាក់អំពីសេចក្តីសម្រេចរបស់បក្សកុម្មុយនីស្តកម្ពុជា ឬក៏របស់ថ្នាក់ដឹកនាំថ្នាក់ខ្ពស់ ឬក៏ថ្នាក់កណ្តាល ដែលដាក់មកឱ្យថ្នាក់ក្រោមអនុវត្ត តើរាល់សេចក្តីសម្រេចទាំងអស់នោះ ត្រូវតែអនុវត្តតាមជាដាច់ខាត ឬមួយក៏មនុស្សថ្នាក់ក្រោម បុគ្គលិក គ្រូពេទ្យថ្នាក់ក្រោមអាចតវ៉ា ឬក៏អាចធ្វើសំណូមពរអ្វីបានខ្លះចំពោះថ្នាក់លើ? ឬក៏យ៉ាងណាបាទ?

[០៩:៥៧:៥៤]

**ឆ៖** ត្រង់ណេះខ្ញុំសូមនិយាយរឿងពិតទាំងអស់ ព្រោះខ្ញុំនិយាយនៅទីនេះខ្ញុំចូលចិត្តប្រើបពាក្យថា "ខ្ញុំសូមនិយាយតែរឿងពិត"។ ដូច្នេះខ្ញុំ រឿងពិតដល់ខ្ញុំត្រង់ហ្នឹង ខ្ញុំសូមបញ្ជាក់ត្រង់ៗថា ពាក្យថា "ផ្តាច់ការ" ខ្ញុំជួបអំពើ មិនដែលជួបពាក្យទេ មិនទាន់ជួបពាក្យទេ តែជួបអំពើមុន។ អំពើបក្សបដិវត្តន៍កម្ពុជានេះគេប្រើក្នុងលក្ខណៈវាបសាល្អណាស់ ទាំងខ្ញុំ ទាំងគេនៅធ្វើនយោបាយខាងលើ ក៏នៅតែវាបសា។ ប៉ុន្តែដល់ការអនុវត្ត ខុសពីការនិយាយ។ ហ្នឹងសូមជម្រាបលោកប្រធានឱ្យដឹងថា ការធ្វើគេដូចខ្ញុំជាក្រសួងសុខាភិបាល គេប្រើពាក្យថា "ចូលអ្នកយកចិត្តជាមនុស្សធម៌ ឲ្យចំជាការងារពេទ្យ"។ ប៉ុន្តែពាក្យមួយម៉ាត់ទៀតដាក់ថា "បើមិត្តធ្វើអីក៏ដោយ ចូរមិត្តស្តាប់ការដឹកនាំរបស់បក្ស បើអ្នកម្នាក់ធ្វើប្រឆាំងនឹងបក្ស មានន័យថាក្បត់"។ អ៊ីចឹងសូមលោកប្រធានពិចារណាចុះ មានប៉ុណ្ណឹងលោកប្រធាន។

[០៩:៥៩:00]

**ស៖** បាទ សូមអរគុណ។ សំណួរបន្តទៀត សូមសួរលោក។ តើយោងតាមមាគ៌ារបស់បក្សកុម្មុយនីស្តកម្ពុជា ដែលត្រូវអនុវត្តចំពោះគ្រូពេទ្យ តើភាពស្មោះត្រង់របស់គ្រូពេទ្យ ការអនុវត្តតាមមាគ៌ានយោបាយរបស់បក្ស គឺជាការចាំបាច់ជាងសមត្ថកិច្ចជំនាញរបស់គ្រូពេទ្យ ក្នុងការព្យាបាលជំងឺ ឬក៏ក្នុងការធ្វើកិច្ចការផ្សេងទៀតនៅក្នុងពេទ្យ ឬក៏យ៉ាងណា? តើបក្សកុម្មុយនីស្តកម្ពុជាឱ្យតម្លៃទៅលើភាពស្មោះត្រង់ចំពោះបក្ស ចំពោះការអនុវត្តមាគ៌ានយោបាយរបស់បក្ស គឺជាការត្រឹមត្រូវប្រសើរជាងជំនាញរបស់គ្រូពេទ្យ ឬក៏យ៉ាងណាបាទ? សូមលោកជួយបញ្ជាក់អំពីចំណុចនេះបាទ។

[១០:០០:០៨]

**ឆ៖** ត្រង់ណោះ លោកប្រធានខ្ញុំសូមជម្រាប មើលគោលការណ៍ដែលការធ្វើដែលខ្ញុំជួប ការងារបក្សមួយសារ -- ពេលនោះ មិនបានគិតដល់អាយុជីវិតពលរដ្ឋទេ គឺគេគិតគោរពវិន័យធំជាង។ អ៊ីចឹងបានខ្ញុំប្រើពាក្យមួយមាត់ថា "បើបក្សដាក់អី ត្រូវតែធ្វើនោះឯង មិនអាចគេចបានឡើយ"។ ហ្នឹង សូមលោកប្រធានជ្រាប។

**ស៖** បាទ សូមអរគុណ។ តើលោកអាចបញ្ជាក់បានទេថា មានគ្រូពេទ្យដែលរៀនចប់ថ្នាក់សាកលវិទ្យាល័យ ឬក៏មហាវិទ្យាល័យ មុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ហើយអស់លោកទាំងអស់នោះធ្លាប់បានទៅបណ្តុះបណ្តាលលោក ឬក៏ធ្វើការជាមួយលោកដែរឬទេ?

**ឆ៖** ត្រង់ហ្នឹងខ្ញុំសូមជម្រាបពីដំណើរពិតរបស់ខ្ញុំដែលបានជួប។ បើនិយាយអំពីគោលការណ៍ថាប្រកាន់អ្នកចេះ អ្នកដឹង ឬអី យើងមើលមិនឃើញទេ ប៉ុន្តែខ្ញុំយល់បានថា អ្នកទៅរៀនទាំងអស់វាទាល់តែជាប់ខ្សែកម្មាភិបាល ឬៗក៏ត្រូវជាកូនជាចៅអ្នកដឹកនាំ។ មួយៗទៀត ដំណើរការនៃការរៀបចំបក្សបដិវត្តន៍កម្ពុជានៅពេលនោះ គេចូលចិត្តប្រើតាមវិធីមួយ បើថាអ្នកណា គេចង់ឱ្យអ្នកណាចេះពេទ្យ គឺគេយកអ្នកនោះ ទៅរៀនពេទ្យ។ អ្នកណាចង់ចេះបកប្រែពាក្យ គឺគេឱ្យអ្នកនោះ រៀនបកប្រែ។

[១០:០១:៥៤]

បើអ្នកណា គេចង់ឱ្យចេះអី គឺគេប្រើអ្នកនោះផ្ទាល់តែម្តង ដោយមិនបានសិក្សាពីចេះ ការចេះដឹងហ្នឹង មុនទៅធ្វើទេ លោកប្រធាន។ បានន័យថា ទាល់តែទៅធ្វើបានគេឱ្យអ្នកនោះរៀនតែម្តង។ ខ្ញុំសូមជម្រាបលោកប្រធាន រឿងពិត បាទ។ ហើយអ៊ីចឹងការសិក្សានេះ ខ្ញុំពិនិត្យទៅឃើញថា ខ្ញុំមិនដែលជួបទេអ្នកបាននិស្សិត បញ្ញវន្តអី អត់ដឹងទេ ប៉ុន្តែភាគច្រើន ដែលខ្ញុំជួប ចូលចិត្តជួបតាមដំណើរ គឺថាពិភាក្សាគ្នាលេង បានដឹងថា អ្នកណាទៅរៀនសូត្រថ្នាក់ណា អ្នកណារៀនសូត្រថ្នាក់ណា ទាល់តែស្គាល់គ្នា

ស្និទ្ធស្នាល បានអាចដឹងបាន លោកប្រធាន។ ការដឹងតាមរូបភាពដឹងខាងក្រៅ ដូចជាមិនដឹងទេ សូមជម្រាបលោកប្រធាន បាទ។ ជម្រាបប៉ុណ្ណឹងលោកប្រធាន។

**សះ** បាទ សូមអរគុណ។ អ៊ីចឹងមានន័យថា លោកមិនបានដឹងអំពីចំនួនដែលអ្នកបានទទួលការបណ្តុះបណ្តាលថ្នាក់សាកលវិទ្យាល័យខាងពេទ្យ ឬក៏ខាងមហាវិទ្យាល័យពេទ្យនោះទេនៅក្នុងពេលនោះមែនទេបាទ?

**ផះ** ពេលនោះ ការយល់ដឹងខាងដើមរបស់អ្នកចូលសិក្សា ខ្ញុំមិនដឹងថា គេបានចេះដឹងពីកម្រិតណា ផ្នែកវប្បធម៌ ខ្ញុំមិនដឹងទេលោកប្រធាន។ តែខ្ញុំគ្រាន់តែស្គាល់ថា វគ្គដែលខ្ញុំចូលរៀននោះ គឺវគ្គបំពេញកាតព្វកិច្ចជាពេទ្យមធ្យម កម្រិតឆ្នាំទី៣ អ៊ីចឹងសូមលោកប្រធានជ្រាប។ អ៊ីចឹងថាកម្រិតនោះ ជាអី ខ្ញុំអត់ដឹង ព្រោះខ្ញុំទទួលចូលរៀន ដឹងតែចូលប៉ុណ្ណឹង។ តែថានាទីនោះស្អីៗ គ្រាន់តែគេប្រាប់ខាងក្រៅថាហ្នឹងឆ្នាំទី៣ ពេទ្យមធ្យម ឆ្នាំទី៣។ ហ្នឹង សូមលោកប្រធានជ្រាបបាទ។

[១០:០៣:៤១]

**សះ** បាទ សូមអរគុណ។ តើក្នុងអំឡុងពេលដែលលោកទៅរៀនពេទ្យ ខ្មែរ-សូវៀត ឬក៏ធ្វើការនៅទីនោះ តើធ្លាប់បានគេណែនាំឲ្យលោកសរសេរជីវប្រវត្តិផ្ទាល់ខ្លួនរបស់លោកដែរឬទេ?

**ផះ** ត្រង់ហ្នឹង តាមដំណើរគេគ្រាន់ -- គេមាន មិនមែនថាអត់មានការសរសេរប្រវត្តិរូប។ គេដឹង គេចង់ដឹងថាយើងស្ថិតនៅភូមិណា ឃុំណា តំបន់ណា។ អ៊ីចឹង នៅក្នុងមន្ទីរពេទ្យ អ្នកណាជាអ្នកឧទ្ទេសនាមមករៀន ដូចៗលោកប្រធានសួរអ៊ីចឹងដែរបាទ។ ការពិតមាន មិនមែនអត់ទេ ការធ្វើប្រវត្តិរូបមានបាទ។ សូមទោស។

**សះ** បាទ សូមអរគុណ។ សំណួរបន្តទៀត សូមសួរថា តើមានហេតុផលអ្វី បានជាគេតម្រូវឲ្យលោកសរសេរជីវប្រវត្តិផ្ទាល់ខ្លួនរបស់លោក នៅក្នុងសម័យដែលលោកស្ថិតនៅក្នុងមន្ទីរពេទ្យខ្មែរ-សូវៀតនោះ?

**ផះ** ហេតុផលថាជាយ៉ាងណានោះ ខ្ញុំផ្ទាល់ជាអ្នកទទួលនាទី ខ្ញុំមិនបានដឹងថាគេចង់ដឹងពីអី ខ្ញុំអត់ដឹងទេ ប៉ុន្តែដូចខ្ញុំជម្រាបខាងដើម លេខាតំបន់២០ ខាងដើម ហាក់ដូចជាគាត់ដឹងមុនថាយ៉ាងណា ព្រោះអី? ព្រោះគាត់ប្រើៗប្រវត្តិរូបនិងឈ្មោះខ្ញុំខុសពីហ្នឹងៗលោកប្រធាន។ ដូចខ្ញុំជម្រាបកាលពីម្សិលមិញថា ឈ្មោះខ្ញុំដល់ពេលមុនទៅរៀនពេទ្យនេះ គណៈតំបន់នោះប្រែឈ្មោះឲ្យហើយ អ៊ីចឹងការទៅនេះគឺឧទ្ទេសនាមឈ្មោះដែលទៅនោះឯង។ អាឈ្មោះដែលប្រើកន្លងមក លោកគាត់បំបាត់ចោល ចូរមិត្តកុំប្រើ

ឲ្យសោះ ពាក្យន៉ែ ឈ្មោះហ្នឹង។ ត្រង់ហ្នឹងដែលខ្ញុំគិតទុកមុនថា ប្រហែលជាគ្រួសារខ្ញុំមានវិបត្តិអីហើយ។ អ៊ីចឹងខ្ញុំគិតទុកជាមុន អ៊ីចឹងខ្ញុំប្រើតាមដំណើរគាត់ថា។ តែក្នុងនោះគាត់បានប្រាប់ថា ចូរមិត្តរក្សាជីវិតឲ្យបាន ហើយឈ្មោះហ្នឹងមិត្តត្រូវតែទទួលស្គាល់ខ្លួនឯង។ ខ្ញុំរក្សា គាត់ប្រាប់ថា “ខ្ញុំរក្សាមិត្តឯងឲ្យ ដើម្បីសងគុណម្ដាយឪពុកអ្នកឯង” គ្រាន់តែដឹងប៉ុណ្ណឹងលោកប្រធាន។

[១០:០៦:០០]

អ៊ីចឹងប្រវត្តិអ្វីក៏ដោយ ខ្ញុំបានប្រែឈ្មោះកាលនោះ ខ្ញុំប្រើឈ្មោះខ្ញុំទូទៅ គេប្រើឈ្មោះ ន៉ែ ឲ្យប្រើ ពេលនោះគេឲ្យប្រើឈ្មោះ អៀបៗ អឿន មិនមែន អឿន ទេ អៀប ខ្ញុំនឹករកឈ្មោះខ្ញុំសិន ដែលដាក់ថា អៀប ឡុន! បាទ ប្រើ អៀប ឡុន ហើយមិនមែនប្រើហើយ ត្រកូល អៀប នេះគឺជាត្រកូលជីតារបស់ខ្ញុំខាងម្ដាយ អ៊ីចឹងអត់ឲ្យប្រើ អ៊ូច-- អែម អឿន អីទេគឺគេ អ៊ូច ឡុន។ អ៊ីចឹងសូមជម្រាបលោកប្រធានបាទ។

**ស៖** បាទ អរគុណ។ ខ្ញុំមានតែបីសំណួរទៀតទេលោកប្រធាន ខ្ញុំសូមសួរ។ តើគេឲ្យលោកសរសេរជីវប្រវត្តិរបស់លោកនោះចំនួនប៉ុន្មានដងដែរបាទ?

**ឆ៖** នៅពេលឱកាសនោះ ខ្ញុំតាមបញ្ជារបស់កន្លែងពេទ្យ គេឲ្យខ្ញុំសរសេរតែម្ដងទេលោកប្រធាន គឺសរសេរមុនពេលចូលនយោបាយនៅបុរីកីឡានេះឯង។ ហ្នឹងសូមលោកប្រធានជ្រាបបាទ។

**ស៖** សូមអរគុណ។ តើរាល់ការសរសេរប្រវត្តិរូបរបស់លោក តើលោកធ្លាប់បានទទួលការណែនាំពីកម្មាភិបាលថ្នាក់លើរបស់បក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

**ឆ៖** នៅក្នុងការស្រាវជ្រាវដូចបង្ហាញហេតុផលយ៉ាងណាៗ ខ្ញុំអត់បានទទួលទេលោកប្រធាន។ មិនដែលទទួលការណែនាំពីការធ្វើប្រវត្តិរូបទេលោកប្រធាន គ្រាន់តែឲ្យខ្ញុំធ្វើប៉ុណ្ណោះឯងបាទ។ សូមមានប៉ុណ្ណឹង។

[១០:០៧:៥៧]

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមសួរសំណួរចុងលោក អែម អឿន។ តើក្នុងអំឡុងពេលដែលលោកធ្វើជាសិស្សរៀននៅមន្ទីរពេទ្យខ្មែរ-សូវៀត លោកធ្លាប់បានឃើញទិដ្ឋភាពជាទូទៅដែលមាននៅក្នុងមន្ទីរពេទ្យនុ៎ង យ៉ាងដូចម្ដេចខ្លះទាក់ទិនទៅហ្នឹងសិស្សដែលមករៀនពេទ្យនៅក្នុងសម័យនោះ? តើពួកគេជួបការលំបាកអ្វីខ្លះនៅក្នុងពេលរៀននៅក្នុងមន្ទីរពេទ្យនោះបាទ? ហើយពួកគេធ្លាប់និយាយអ្វីខ្លះប្រាប់លោក?

**ឆ៖** ត្រង់ហ្នឹង ខ្ញុំសូមនិយាយរឿងដែលកើតឡើង ហើយដឹងឮខ្លះ ពិសេសបំផុត ភាគច្រើនគឺ

និយាយតាមភូមិភាគ។ រឿងពិត គេមិនដែលនិយាយរឿងអីទាំងអស់ មូលហេតុ ខ្ញុំសួរថាអ្វីបានមិនដែលបានិយាយគ្នា លេងសើច? ដល់គេបង្ហើបមកវិញ គេថាខ្លាចៗហួសពីការ -- ព្រោះកាលណានិយាយខ្លាចគេចោទប្រកាន់ថា យើងក្បត់បក្ស។ ម៉្លោះហើយអ្នកទាំងអស់ក្នុងនាមយុវជនទៅរៀនសូត្រនោះ មិនដែលនិយាយអី លេងសើចអីទេលោកប្រធាន។ ទាំងគេទាំងខ្ញុំប្រឹងប្រែងដើម្បីកុំឲ្យមានកំហុស ព្រោះកំហុសនៅពេលនោះ អត់មានសួរនាំឡើយ កាលណាបុគ្គលណាខុស ដាច់ខាតត្រូវតែឡើងឡាននេះឯង។ ហើយអនុវត្តនៅមន្ទីរពេទ្យ ខ្ញុំឃើញភាគច្រើនអ្នកនៅតាមភូមិភាគ គេទៅតាមចងពីមន្ទីរពេទ្យរហូតភូមិភាគណា ទៅចងភូមិ -- បញ្ជូនទៅភូមិភាគនោះវិញបណ្ដោយ។ អ៊ីចឹងរូបភាពទាងអស់នេះហើយធ្វើឲ្យសិស្សទាំងអស់មិនបានិយាយអី លោកប្រធាន។ អ៊ីចឹងអាថ៌កំបាំងនៃការនិយាយស្ដីថា ភូមិភាគនេះយ៉ាងណាៗខុសគ្នាយ៉ាងម៉េច អត់ដឹងទេ លោកប្រធាន និយាយរឿងពិត ហ្នឹងការជួបប្រទះ។ អ៊ីចឹងអ្វីក៏ដោយអ្នកដែលបានសិក្សារៀនសូត្រ បានត្រឹមបក្សឲ្យធ្វើអី ធ្វើតាមប៉ុណ្ណោះឯង លោកប្រធានសូមជ្រាបបាទ។

[១០:០៩:៥៦]

**លោក ច័ន្ទ តារាស្មី៖**

បាទ សូមអរគុណលោកប្រធាន។ សូមអរគុណលោក អែម អឿន ដែលបានឆ្លើយសំណួររបស់ខ្ញុំយ៉ាងក្បោះក្បាយ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងច្រើនចំពោះលោក ដែលបានចំណាយពេលវេលាឆ្លើយសំណួររបស់ខ្ញុំយ៉ាងក្បោះក្បាយ។ សូមអរគុណបាទ។

ហើយខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីជូនសហការីរបស់ខ្ញុំ គឺលោក វ៉ាំងសង់ បន្តសួរសំណួរដែលគាត់ចង់សួរបន្តទៀតបន្ទាប់ពីខ្ញុំបាទ។ សូមអរគុណ។ សូមអញ្ជើញលោក វ៉ាំងសង់!

[១០:១០:៣០]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រមជម្រាបសួរភាគីទាំងអស់ ជម្រាបសួរលោកដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរពាក់ព័ន្ធតែវគ្គអប់រំនយោបាយនៅបុរីកីឡាតែប៉ុណ្ណោះ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោក អែម អឿន នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី លោកបានឆ្លើយថា

លោកគេបានបញ្ជូនទៅបុរីកីឡាដើម្បីរៀនសូត្រនយោបាយ គឺនៅពេលដែលលោកទទួលការបណ្ដុះបណ្ដាលនៅមន្ទីរពេទ្យ នៅថ្ងៃទី១៧ មេសា។ កាលពីថ្ងៃព្រហស្បតិ៍កន្លងទៅនេះ លោកបញ្ជាក់ថា លោកបានចូលរួមនៅក្នុងវគ្គសិក្សានយោបាយជាច្រើនលើក។ តើលោកអាចបញ្ជាក់ឲ្យបានច្បាស់ទេ អំពីចំនួនវគ្គដែលលោកបានចូលរួមនោះ តើប៉ុន្មានវគ្គដែរ ដែលមានរយៈពេលពី៧ ទៅ១០ថ្ងៃនោះ? គឺខ្ញុំចង់សំដៅទៅដល់វគ្គដែលលោកបានចូលរៀននៅបុរីកីឡា តើមានតែមួយវគ្គ ឬក៏មានច្រើនវគ្គ? សូមលោកបញ្ជាក់ចំណុចនេះឲ្យបានច្បាស់។

**លោក អែម អឿន៖**

**ឆ៖** បាទ ខ្ញុំសូមជម្រាបទៅតាមសំណួរដែលសួរ។ ខ្ញុំនិយាយពាក្យថា “គេបើកច្រើនវគ្គ” ប៉ុន្តែមិនមែនបើកតែខ្ញុំម្នាក់ទេ តាមពិតទៅ ខ្ញុំចូលរៀនបានតែមួយវគ្គទេ បាទ សូមនិយាយច្បាស់។ ខ្ញុំបានចូលរៀនតែមួយវគ្គបាទ។ សូមទោស សូមអរគុណ។

[១០:១២:១២]

**ស៖** សូមអរគុណ។ នៅពេលដែលលោកចូលរួមក្នុងវគ្គនោះ តើមានកម្មាភិបាលមន្ទីរពេទ្យ១៧ មេសា ឬក៏អ្នកណាផ្សេងទៀតដែលបានចូលរួមដែរឬទេ? ឬក៏លោកទៅតែម្នាក់ឯងទេ ពីមន្ទីរពេទ្យ១៧ មេសា នុ៎ង?

**ឆ៖** ត្រង់ហ្នឹង ខ្ញុំមិនបានដឹងថា បុគ្គលណា ព្រោះខ្ញុំនៅមន្ទីរពេទ្យរុស្ស៊ីហ្នឹង ខ្ញុំមិនបានស្គាល់គេអស់ទេ ប៉ុន្តែនាទីដែលខ្ញុំទៅរៀននេះ ក្នុងឋានៈខ្លួនឯងជាបក្ស។ អ៊ីចឹងបក្សតំណាងឲ្យសិស្សនៅក្នុងសាលា គេតម្រូវឲ្យខ្ញុំឡើងរៀននយោបាយ។ ហ្នឹងសូមជ្រាបបាទ។

**ស៖** សូមអរគុណ។ កាលពីថ្ងៃព្រហស្បតិ៍កន្លងទៅនេះ លោកបានបញ្ជាក់ពីឈ្មោះ យុន យ៉ាត, ប៉ុល ពត, នួន ជា, ខៀវ សំផន, ហើយនិង ហ៊ូ នឹម ដែលលោកថា ពួកគាត់នោះ ជាមេដឹកនាំដែលបាននិយាយ ឬក៏ធ្វើបទឧទ្ទេសនាមនៅក្នុងវគ្គអប់រំនយោបាយ ដែលលោកបានចូលរួមផងដែរនោះ ហើយលោកក៏បានឆ្លើយផងដែរថា ចំពោះ អៀង សារី នោះលោកមិនសូវច្បាស់ទេ។ ខ្ញុំចង់ដឹងថាតើមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជានោះ បានណែនាំខ្លួនយ៉ាងម៉េចនៅពេលវគ្គបណ្ដុះបណ្ដាលនោះ? ពួកគាត់ប្រាប់ឈ្មោះដល់លោក ឬក៏មានអ្នកណាម្នាក់ផ្សេងទៀត ប្រាប់ថា ពួកគាត់នោះឈ្មោះអីៗ ដូចជា យុន យ៉ាត, ប៉ុល ពត, នួន ជា, ខៀវ សំផន អ៊ីចឹង ហ៊ូ នឹម អីជាដើម។ តើពួកគាត់ណែនាំលោកឲ្យស្គាល់ឬក៏មានអ្នកណាម្នាក់ប្រាប់លោក?

[១០:១៤:០៦]

**ផ៖** ត្រង់ហ្នឹងមិនមែននេះទេ គឺគណៈសាលានយោបាយនេះទេ អ្នកប្រាប់ថា បុគ្គលណាជាអ្នកណា បុគ្គលណាអ្នកណាទៅតាមការខឡែសនាម ណែនាំឲ្យស្គាល់។ មូលហេតុដែលស្គាល់ហ្នឹងដោយសារការខឡែសនាមនេះឯង ក្នុងការមុននឹងសិក្សាគេឲ្យយើងជាសិស្សដឹងគ្រូ ស្គាល់គ្រូ។ អ៊ីចឹងសូមជ្រាបបាទ។

**សៈ** សូមអរគុណ។ នៅសម័យនោះ នៅពេលដែលលោកទទួលការបង្រៀនពី ប៉ុល ពត តើលោកដឹងទេថា តើ ប៉ុល ពត មានតួនាទីអ្វីនៅក្នុងឋានានុក្រមបក្សកុម្មុយនីស្តកម្ពុជា និងក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ?

**ផ៖** នៅក្នុងពេលនោះ ខ្ញុំបាទ បានដឹងថា ប៉ុល ពត គឺជាលេខាបក្សបដិវត្តន៍កម្ពុជា សូមលោកជ្រាបបាទ។

**សៈ** នៅពេលនោះតើលោកដឹងទេថា លោក នួន ជា កាន់តំណែងអ្វីដែរនៅក្នុងបក្ស?

**ផ៖** ក្នុងនោះ លោក នួន ជា គឺគាត់កាន់តំណែងជាប្រធានសភា។ សូមជ្រាបបាទ។

**សៈ** តើមុខងារនេះគេប្រាប់លោកនៅពេលដែលលោករៀនសូត្រនៅបុរីកីឡា ឬក៏លោកដឹងតាំងពីមុនពេលដែលលោកទៅបុរីកីឡាហ្នឹងហើយ ថាលោក នួន ជា ជាប្រធានសភាហ្នឹង?

**ផ៖** ត្រង់ហ្នឹង ខ្ញុំបានដឹងមុនពេលខ្ញុំចូលរៀន ព្រោះខ្ញុំដឹងតាំងពីប្រធានតំបន់ និងភូមិភាគប្រាប់ថា លោក នួន ជា ឡើងទៅជាប្រធានសភា។ អាហ្នឹងសូមជ្រាបបាទ។

[១០:១៦:២៦]

**សៈ** ចុះលោក ខៀវ សំផន វិញ លោកដឹងទេនៅពេលគាត់ទៅបង្រៀននយោបាយនៅបុរីកីឡានោះ លោកដឹងថាគាត់មានតួនាទីអ្វីទេ?

**ផ៖** លោក ខៀវ សំផន ក្នុងតួនាទីក៏ដឹងនៅពេលដែលខ្ញុំទៅរៀន របស់គាត់ តួនាទីរបស់គាត់យ៉ាងណាៗ ដឹងមុនរៀនដែរ ហ្នឹងដឹងតាមរយៈលោកប្រធានតំបន់២០ និងភូមិភាគ គាត់ប្រាប់ថា លោក ខៀវ សំផន គឺជាគណៈប្រធានរដ្ឋ។ ហ្នឹងសូមជ្រាបបាទ។

**សៈ** ដើម្បីបញ្ជាក់ឲ្យបានច្បាស់ថា ខ្ញុំយល់មិនខុសទេនោះ អម្បាញ់មិញនេះលោកបានឆ្លើយថា នៅពេលដែលលោកនៅបុរីកីឡា គឺជាលើកដំបូងបង្អស់ដែលលោកបានឃើញ ប៉ុល ពត, នួន ជា, និង ខៀវ សំផន និងមេដឹកនាំផ្សេងទៀត។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ នោះគឺជាការពិត ខ្ញុំទើបឃើញដំបូងបង្អស់បាទ ក្នុងជីវិត។

**ស៖** សូមអរគុណ។ ដូច្នេះសូមឲ្យលោកព្យាយាមរំឭកអំពីថ្ងៃដំបូងនៃវគ្គរៀនសូត្រ។ លោកបានបញ្ជាក់ថាគណៈកម្មការសាលានោះបានបង្ហាញឈ្មោះវាគ្មិនផ្សេងៗដល់លោក។ តើមេដឹកនាំទាំងអស់ហ្នឹងនៅកន្លែងហ្នឹង នៅជុំគ្នានៅពេលដែលបើកវគ្គរៀនសូត្រនោះនៅថ្ងៃដំបូងមែនទេ?

**ឆ៖** ពេលនោះ ពេលបើកវគ្គដំបូង គឺគាត់ទាំងអស់គ្នាជុំគ្នា។ សូមជ្រាប។

[១០:១៨:២៩]

**ស៖** តើ នួន ជា និង ខៀវ សំផន បានចូលរួមនៅពេលដែល ប៉ុល ពត បានធ្វើបទបង្ហាញ ឬក៏ធ្វើសុន្ទរកថាអ្វីទេនៅថ្ងៃដំបូងនោះ?

**ឆ៖** ពេលថ្ងៃដំបូង គឺលោក ប៉ុល ពត បានធ្វើសុន្ទរកថាការបើក ការបើកសាលានយោបាយបើកដំបូង គឺលោក ប៉ុល ពត តែម្តង។ ជ្រាប។

**ស៖** បាទ អ៊ីចឹងនៅពេលដែលថ្លែងសុន្ទរកថាបើកនោះ តើលោកមានបានកត់សម្គាល់ឃើញទេថាមានវត្តមាន ខៀវ សំផន និង នួន ជា នៅទីនោះដែរនោះ ហើយបន្ទាប់ពីមានការណែនាំពីគណៈកម្មការសាលាហើយនោះ។ ហើយនៅពេល ប៉ុល ពត ថ្លែងសុន្ទរកថានោះ តើគាត់នៅស្តាប់ដែរ ឬក៏គាត់ចេញទៅមុនពេល ប៉ុល ពត ថ្លែងសុន្ទរកថាបើក?

**ឆ៖** ទាំងអស់គ្នាគាត់ ទាំងលោក ខៀវ សំផន ទាំងលោក ប៉ុល ពត ទាំងលោក នួន ជា និងអ្នកអង្គុយជាអធិបតីនៅពេលនោះ គឺអង្គុយស្តាប់ទាំងអស់គ្នា។ សូមជ្រាបបាទ។

[១០:១៩:៥៧]

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមត្រឡប់មកអ្វីដែលលោក ប៉ុល ពត បាននិយាយនៅក្នុងវគ្គនោះ។ គឺពាក់ព័ន្ធទៅនឹងរបៀបទូទៅនៃការប្រព្រឹត្តទៅនៃវគ្គនយោបាយ។ តើលោក ហើយនិងអ្នកចូលរួមផ្សេងទៀត មានសិទ្ធិសេរីភាពក្នុងការឡើងនិយាយ ឬក៏សួរសំណួរទៅកាន់មេដឹកនាំ ឬក៏ផ្លាស់ប្តូរទស្សនៈផ្សេងៗនៅក្នុងវគ្គប្រជុំនុ៎ង -- នៅក្នុងវគ្គរៀនសូត្រនុ៎ងដែរឬទេ?

**ឆ៖** ត្រង់ហ្នឹងខ្ញុំសូមបញ្ជាក់ថា ទាំងគេទាំងខ្ញុំអត់មានយោបល់អីទាំងអស់។ ខ្ញុំសូមជម្រាបបាទ។

**ស៖** អ៊ីចឹងតើមេដឹកនាំនោះ មានសួរសំណួរលោកទេ? ហើយមានឲ្យលោកឆ្លើយ ឬក៏ឲ្យលោកផ្តល់យោបល់អីទេនៅក្នុងវគ្គនុ៎ង ឬមួយក៏លោកគ្រាន់តែចូលរួមស្តាប់ ហើយមេដឹកនាំជាអ្នកធ្វើបទ

ឧទ្ទេសនាមតែឯងអ៊ីចឹងទៅ?

[១០:២១:១៤]

**ឆ៖** ត្រង់ហ្នឹងខ្ញុំសូមបញ្ជាក់ថា ក្នុងឱកាសធ្វើនយោបាយនេះ ដែលគាត់ធ្វើសាលាពេលនេះ គឺយើងបានត្រឹមទៅអង្គុយស្តាប់អ្វីដែលបក្សណែនាំ។ មិនមានបុគ្គលណាមានមតិអ្វីឡើយ។ លើកលែងតែគ្នាគាត់ប៉ុន្មាននាក់ជាគណៈដឹកនាំនោះឯង។ សូមជម្រាបបាទ។

**ស៖** សូមអរគុណលោក អែម អឿន។ ពាក់ព័ន្ធទៅនឹងបទឧទ្ទេសនាមរបស់ ប៉ុល ពត នៅថ្ងៃដំបូង។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីអាននូវឃ្លាមួយនៃចម្លើយរបស់លោកនៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានលេខ D22/3963។ សូមការអនុញ្ញាតពីលោកប្រធាន ដើម្បីបញ្ចាំងឯកសារនេះនៅលើអេក្រង់។ ជាភាសាអង់គ្លេសគឺនៅទំព័រទី៧, ជាភាសាបារាំងទំព័រ១៦, ជាភាសាខ្មែរគឺ 00573978។ ខ្ញុំមានឯកសារជាក្រដាស ហើយសូមការអនុញ្ញាតពីលោកប្រធានផ្តល់ឯកសារនេះជូនទៅគាត់ផងដែរ។ សូមអរគុណលោកប្រធាន។

[១០:២២:៣១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខាងសហព្រះរាជអាជ្ញាបានរើសយកអង្គហេតុដែល -- ជ្រើសរើសយកការអនុវត្តដែលមិនត្រឹមត្រូវ ព្រោះថាជាដំបូងគាត់សួរសាក្សី -- ជាដំបូងគាត់គួរតែសួរសាក្សីថាតើស្គាល់ ឬក៏ធ្លាប់ឃើញនេះឬអត់? បន្ទាប់មក ទុកឲ្យសាក្សីបញ្ជាក់ថាធ្លាប់ឃើញ ឬក៏មិនឃើញ។ ដូច្នេះនៅពេលនោះ គឺថាយើងអាចនឹងធ្វើការរំឭកសាក្សីឲ្យដឹង ដោយការអាននូវព័ត៌មានរបស់គាត់។

ដូច្នេះ ដំបូងគឺត្រូវឲ្យសាក្សីបញ្ជាក់នូវចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីសិន គឺអ្វីដែលគាត់និយាយកាលពី២ឆ្នាំមុន។ ដូច្នេះ នេះគឺជាអ្វីដែលគំរូដែលយើងធ្វើចំពោះសាក្សី ហើយខ្ញុំស្នើដល់ព្រះរាជអាជ្ញាថា ធ្វើនូវការអនុវត្តដែលត្រឹមត្រូវ ដែលដំបូងសួរសាក្សី ថាតើស្គាល់នូវចម្លើយ ឬក៏ព័ត៌មាននេះឬអត់សិន?

[១០:២៣:៤០]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ខ្ញុំសូមការអនុញ្ញាត ដើម្បីឆ្លើយតប។ ខ្ញុំគិតថា ករណីនេះគឺមានសុពលភាពហើយ យើងមិនបាច់ចាំបាច់សួរដើមបណ្តឹងរដ្ឋប្បវេណីពីអ្វីដែលគាត់ជាអ្នកសរសេរនោះទេ។ ឯកសារនេះជាឯកសាររបស់គាត់។ ដូច្នេះ ខ្ញុំអាចសួរសំណួរបន្ថែមពាក់ព័ន្ធទៅនឹងចម្លើយរបស់គាត់នៅក្នុងពាក្យសុំនេះ។ ហើយជាពិសេសនោះ គឺថាមួយផ្នែកធំនៃឯកសារនេះបានបញ្ជាក់នៅក្នុងសវនាការនេះកាលពីថ្ងៃព្រហស្បតិ៍សប្តាហ៍មុនរួចទៅហើយ។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីអាននូវឃ្លានេះ ហើយនិងសួរសំណួរបន្ថែមពាក់ព័ន្ធទៅនឹងពាក្យដែលប្រើប្រាស់ផ្ទាល់ដោយដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

[១០:២៤:៤៣]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ឯកសារនេះគឺជាឯកសារសរសេរដែររបស់លោកផ្ទាល់ លោក អែម អឿន។ ខ្ញុំនឹងអានឃ្លាមួយនៅក្នុងឯកសារនេះ។ "ថ្ងៃដំបូងបង្អស់ ប៉ុល ពត និយាយអំពីនយោបាយបដិវត្តន៍។ ក្នុងនោះ ប៉ុល ពត និយាយអំពីគោលនយោបាយមហាលោតផ្លោះ មហាអស្ចារ្យ ហើយក្នុងពាក្យរបស់ ប៉ុល ពត នោះគាត់បានបញ្ជាក់ថា ដើម្បីឲ្យឈានទៅដល់មហាអស្ចារ្យ មហាលោតផ្លោះ នោះ យើងត្រូវតែដឹងឲ្យច្បាស់ថា អ្នកណាជាមិត្ត អ្នកណាជាសត្រូវ ដោយមិនគិតថា អ្នកនោះជាបងប្អូន ឬជាឪពុកម្តាយឡើយ។ ដើម្បីឲ្យត្រូវតាមពាក្យ "មហាអស្ចារ្យ មហាលោតផ្លោះ" របស់អង្គការយើងត្រូវតែកម្ទេចចោល "ខ្មាំង"។ ខ្ញុំសូមឈប់ត្រឹមនេះសិន។

ខ្ញុំមានសំណួរទី១ ពាក់ព័ន្ធទៅនឹងពាក្យថា "មហាអស្ចារ្យ មហាលោតផ្លោះ" កាលពីថ្ងៃព្រហស្បតិ៍សប្តាហ៍មុន នៅក្នុងសេចក្តីព្រាងនៃប្រតិចារឹកនៅថ្ងៃទី២៣ សីហា គឺប្រហែលជាម៉ោង ១៤:២២ រហូតទៅដល់ ១៤:២៤ លោកបានបញ្ជាក់ថា លោកបានចូលរួមវគ្គនយោបាយដែលគេបង្រៀនដើម្បីគ្រប់គ្រងទៅលើសតិអារម្មណ៍របស់ប្រជាជន ដើម្បីឲ្យស្របទៅតាមមាគ៌ានយោបាយមហាអស្ចារ្យមហាលោតផ្លោះ។ ហើយកាលពីថ្ងៃព្រហស្បតិ៍សប្តាហ៍មុននេះ លោកបានឆ្លើយថា "គឺយើងឆ្លងពីប្រជាធិបតេយ្យទៅកុម្មុយនីស ដោយមិនចាំបាច់ឆ្លងកាត់តាមសង្គមនិយម"។ សំណួររបស់ខ្ញុំ ខ្ញុំចង់ឲ្យលោក

ពន្យល់អំពីអ្វីដែល ប៉ុល ពត ឬមេដឹកនាំផ្សេងទៀតនិយាយប្រាប់លោក ដើម្បីឲ្យសម្រេចជោគជ័យនៅក្នុងជីវិតប្រចាំថ្ងៃ ដើម្បីជា-- ដើម្បីគ្រប់គ្រងទៅលើសតិអារម្មណ៍របស់ប្រជាជន ដើម្បីឲ្យឈានទៅរកនយោបាយមហាអស្ចារ្យ មហាលោតផ្លោះ។ លោកអែម អឿន តើលោកយល់សំណួររបស់ខ្ញុំទេ?

[១០:២៦:៤២]

**លោក អែម អឿន៖**

**ឆ៖** ខ្ញុំសូមបញ្ជាក់ត្រង់ហ្នឹងហាក់ដូចជាមិនបាច់បន្ថែមទេ ព្រោះការនិយាយនេះ គឺរឿងពិតរបស់ខ្ញុំហើយ។

**ស៖** ខ្ញុំមានសំណួរបន្ថែម។ លោកបានឆ្លើយថា "ប៉ុល ពត បញ្ជាក់ថា អ្នកណាដែលមិនអនុវត្តតាមមាគ៌ាមហាអស្ចារ្យ មហាលោតផ្លោះ នុំងគឺចាត់ទុកថាជាខ្មាំង"។ តើខ្ញុំចង់ដឹងថា យើងយ៉ាងម៉េចបានថា អ្នកណាម្នាក់អាចអនុវត្តតាមមាគ៌ាមហាអស្ចារ្យ មហាលោតផ្លោះនោះ? ខ្ញុំចង់ដឹងឲ្យបានច្បាស់។ ខ្ញុំចង់ដឹងថា តើយើងអាចដឹងបានយ៉ាងម៉េចថាអ្នកណាធ្វើតាមមាគ៌ា មហាអស្ចារ្យ មហាលោតផ្លោះ ហើយអ្នកណាមិនធ្វើតាមនោះ?

[១០:២៧:៤៨]

**ឆ៖** ត្រង់ហ្នឹង ខ្ញុំបានសរសេរក្នុងពាក្យបណ្ដឹងរួចហើយថា ដើម្បីបញ្ជាក់ថា អ្នកណាជាជនកុម្មុយនីស្តរបស់បក្ស អ្នកណាជាអ្នកប្រឆាំងគោលការណ៍របស់បក្ស ត្រង់ហ្នឹងខ្ញុំបានបញ្ជាក់ក្នុងឯកសារដែលខ្ញុំបានសរសេររួចហើយ ដូចលោកខាងណាអំមិញថា -- ខាងការពារហ្នឹង លោកយកមកបង្ហាញជាឯកសារបានពីសហាចៅក្រមនិយាយហ្នឹង គឺបានន័យថា ចម្លើយនេះគឺជាចម្លើយពិត ហើយការ ដើម្បីដឹងថាជនណាជាជនបក្សកុម្មុយនីស្តពិតៗនោះ ដូចភាសាក្នុងនេះបានលើកខ្លះៗថា "បក្សពេលនោះហាក់ដូចមិនមើល មិនយកគោលការណ៍អីធំដុំប៉ុន្មានទេ ដើម្បីបោសសម្អាតខ្មាំងរបស់គេឲ្យបានស្អាតបាតនោះគេមើលតាំងពីភាពអនុវត្តរបស់បុគ្គល"។ ឧបមាថា បើខ្ញុំឡើងមករៀន ពេលនេះបើធ្វើមិនបានចាត់ទុកថា នោះឯងហើយគឺអ្នកក្បត់។ ហើយបើអ្នកធ្វើការជាទូទៅក្នុងឯកសាររបស់គាត់បានអត្ថាធិប្បាយក្នុងកិច្ចការនយោបាយនោះ គាត់បានបញ្ជាក់ថា "មិនថាការងារនោះធំឡើយ ចូលអ្នកពិនិត្យពិច័យឲ្យបានច្បាស់ថា ឲ្យតែជនណាប្រឆាំងគោលការណ៍របស់បក្ស ជនណារំខានការងាររបស់បក្ស នោះឯងហើយគេហៅថា លួកលាន់នៃកិច្ចការនយោបាយរបស់បក្ស។ បើសិនជាលួកលាន់ហើយ នោះឯងហើយគឺជាជនក្បត់បដិវត្តន៍ហ្នឹង"។ សូមលោកសួរ យកតាមដំណើរបាទ។ សូមសួរបន្ថែមចុះបាទ។

[១០:២៩:២៥]

**ស៖** លោក អែម អឿន ខ្ញុំចង់ឲ្យលោកឆ្លើយពន្យល់ឃ្លានៅក្នុងឯកសារនេះ ដែលថាជាសម្ដីរបស់ ប៉ុល ពត គឺថា គាត់ថា ប៉ុល ពត ថា "ត្រូវបែកចែកឲ្យបានច្បាស់ មិត្ត និងខ្មាំង ដោយមិនគិតថាជាឪពុកម្ដាយ បងប្អូនអ្វីឡើយ"។ តើលោកអាចបញ្ជាក់ឲ្យបានច្បាស់បន្តិចទេថា តើត្រង់នេះលោកចង់បានន័យថាម៉េចដែរ?

[១០:២៩:៥៧]

**ឆ៖** ត្រង់ហ្នឹងខ្ញុំសូមបញ្ជាក់ នោះឯងជាគោលការណ៍របស់បក្សដែលបានដឹកនាំខ្ញុំជាសមាជិកបក្ស ដែលបានអនុវត្តទៅតាមគោលការណ៍របស់បក្ស។ ពេលនោះគឺលោកមានប្រសាសន៍ថាអ៊ីចឹង។ មានន័យថា "ឈ្មោះថា មិនគិតថាម្ដាយមានឪពុក មានអី ថាបើសិនជាឪពុក ឬយើងជាកូន យើងក្បត់របស់បក្ស ខ្ញុំទៅជាកូន ឬក៏ឪពុកខ្ញុំទៅក្បត់បក្ស ខ្ញុំដាច់ខាតត្រូវតែគោរពគោលការណ៍របស់បក្ស បើសិនជាឪពុកនោះប្រឆាំងនឹងការសម្រេចរបស់បក្ស គឺចាត់ទុកថាឪពុកខ្ញុំនោះក្បត់បក្ស សួរថាឲ្យតម្លៃធ្វើយ៉ាងម៉េច? យ៉ាងម៉េចទើបដឹងថា យល់ថាក្បត់បក្ស? ឧបមាថា បើឪពុកខ្ញុំក្បត់ បក្សលោកសម្រេចចិត្តថាឲ្យខ្ញុំសម្លាប់ឪពុក នេះនិយាយការពិត។ បើសិនឪពុកខ្ញុំក្បត់ គឺបក្សបានសម្រេចថាឲ្យអ្នកឯងសម្រេចកម្ទេចអ្នកនោះ តើអ្នកឯងហ៊ានដែរឬក៏អត់? នេះគឺជាការពិត ដែលជាសំឡេងគោលដៅនៃការណែនាំរបស់ពេលនោះឯង។ អ៊ីចឹងហើយដែលខ្ញុំនិយាយថា ខ្ញុំនិយាយខាងដើមអំមិញថា បក្សពេលនោះហាក់ដូចជា មិនគិតពីតម្លៃនៃការរស់នៅរបស់មនុស្សទេ គាត់មើលឃើញតែវិន័យធំជាងគេបង្អស់។ ដល់ត្រង់ហ្នឹងក៏ដូចគ្នាដែរ អស់លោកជ្រាបបាទ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ ខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំ សម្រាប់សាក្សីដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មនេះវិញ នូវពេលវេលាដែលបានកំណត់អម្បាញ់មិញនេះ គឺម៉ោងដប់មួយខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣១ នាទី ដល់ម៉ោង ១០:៥២ នាទី)*

[១០:៥២:៣០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

សូមអញ្ជើញ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមអរគុណលោកប្រធាន។

[១០:៥២:៥៧]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** បាទ លោក អែម អឿន អម្បាញ់មិញនេះយើងនិយាយអំពីវគ្គសិក្សារៀនសូត្រនៅបុរីកីឡា ហើយនិងអ្វីដែល ប៉ុល ពត បានលើកឡើងនៅក្នុងថ្ងៃបើកវគ្គរៀនសូត្រ ដែលលោកបានចូលរួមនេះ។ ហើយយើងក៏បាននិយាយអំពីមិត្ត ហើយនិងខ្មាំង ដែលត្រូវបែងចែកឲ្យបានច្បាស់លាស់ ទោះបីជាបងប្អូនឬក៏ឪពុកម្តាយក៏ដោយ។ ទៅតាម ប៉ុល ពត ហើយនិងអ្នកដឹកនាំផ្សេងៗទៀតដែលចូលរួមក្នុងការរៀនសូត្រនេះ តើអ្នកណាមានសិទ្ធិកំណត់ថា អ្នកនេះ ឬក៏អ្នកនោះជាមិត្តឬក៏ជាសត្រូវ? តើបក្សដែលស្ថិត -- កម្មាភិបាលមានសិទ្ធិធ្វើការបែងចែកនេះថាអ្នកនេះជាមិត្ត អ្នកនេះជាខ្មាំង ឬក៏កម្មាភិបាលជាន់ខ្ពស់ ឬក៏អង្គការដែលត្រូវចេញសេចក្តីសម្រេចនេះ?

**លោក អែម អឿន៖**

**ឆ៖** ត្រង់ហ្នឹងខ្ញុំសូមធ្វើចម្លើយទៅតាមដំណើរជាក់ស្តែង តាមការឃើញពិត។ បើនិយាយឲ្យខ្លីទៅក្នុងបក្សទាំងអស់សម័យនោះហាក់ដូចជាអត់អំណាច។ អ្នកទាំងអស់ចូលចិត្តស្តាប់តែសារាចរមួយ ខ្ញុំចាំបានថា សារាចរនោះគឺលេខ ៨៧០។ បើសិនជាសារាចរនោះចេញមកថាម៉េច គឺត្រូវតែគោរព ទាំង

គេ ទាំងខ្ញុំ ឲ្យតែឮថាសារាចរ៨៧០ អនុវត្តសម្រេចថាយ៉ាងណាៗនោះ អ្នកនោះត្រូវតែទទួល។ តែពីនោះដល់នេះ ខ្ញុំអត់ស្គាល់ថា សារាចរនោះជាអ្នកណាទេ។ នេះសូមជម្រាបបាទ។

[១០:៥៤:៥២]

**ស៖** តើលោកមានទទួលសារាចរលេខ ៨៧០ នុ៎ងដែរទេ? ហើយអ្នកណាជាអ្នកផ្តល់សារាចរនេះឲ្យលោក?

**ឆ៖** សំណួរត្រង់ហ្នឹង ខ្ញុំសូមជញ្ជាក់ថា ខ្ញុំមិនដែលទទួលទេ ប៉ុន្តែខ្ញុំធ្លាប់ទទួលឥទ្ធិលនៃៗសារាចរ មានន័យថា សារាចរនេះគេអនុវត្តទៅតាមទីកន្លែងរបស់គេ ឧបមាថា បើគេឋានៈជាមេភូមិ ឬៗថាឋានៈជាប្រធានក្រសួង ឬប្រធានកន្លែងណាមួយ គេតែងតែយកឯកសារហ្នឹងមកឲ្យអាន។ រួចបានគេបញ្ញត្តិថា "កាលណាអ្នកបានបន្លឺ -- ឮហើយ ត្រូវតែអនុវត្តទៅតាមសារាចរអ្នកឯង។ ហ្នឹងសូមជម្រាបបាទ។

[១០:៥៥:៤៨]

**ស៖** តើសារាចរនេះមានកំណត់ថា អ្នកនេះអ្នកនោះមានសិទ្ធិចាប់ខ្មាំង ហើយនិងកម្ទេចខ្មាំងដែរឬទេ?

**ឆ៖** ត្រង់ហ្នឹង ខ្ញុំនិយាយតាមរឿងពិត មិនមែនឆ្លើយសម្រាល ឬក៏ឆ្លើយបន្ថឹងបន្ទៀននោះទេ សូមនិយាយរឿងពិត។ មានន័យថា ប្រហែលជាអត់មានអ្នកណាជាអ្នកសម្រេចនោះទេមើលទៅ ព្រោះថា អ្នកទាំងអស់ ឲ្យតែឃើញសារាចរនេះគឺៗដូចជាគោរពមិនឈប់ ដាច់ខាតត្រូវតែគោរព។ ខ្ញុំសូមបន្ថែមក្នុងកិច្ចការទាំងអស់ហ្នឹង ខ្ញុំសូមនិយាយរឿងពិត ដែលបានឃើញ ហើយខ្ញុំឆ្លើងឆ្លល់ រហូតដល់ខ្ញុំខ្លាចខ្លួនឯង ក្រោយពីពេលយល់ទៅខ្លាច។ ចំណុចមួយ សូមលើកក្រៅការសួរ គឺនិយាយរឿងពិត និងមូលហេតុ។ មើលទៅរបបពេលនោះហាក់ដូចជាព្រះរាជអំណាចច្រើនពេក បានន័យថា សហករណ៍ក៏មានអំណាច សិទ្ធិៗ ប៊ានសិទ្ធិសម្រេចចាប់អ្នកនេះអ្នកនោះ ហើយបើប្រធានល្អួបតូចមួយក៏មានសិទ្ធិវៃមនុស្សចោល។ អ៊ីចឹងមើលទៅអំណាចពេលនោះហាក់ដូចជា អ្នកកាន់កាប់អត់ឃុំគ្រងអំណាច ហ្នឹងការឃើញ។

ដូច្នេះខ្ញុំនិយាយរឿងថា អ្នកណាជាអ្នកណា អត់ដឹងទេ សូមអ្នកសួរសំណួរពិចារណាចុះបាទ។ សូមអស់។

[១០:៥៧:២២]

**ស៖** បាទ ដើម្បីត្រឡប់មកនិយាយអំពី ប៉ុល ពត ហើយនិងសុន្ទរកថារបស់គាត់នៅថ្ងៃទី០១ នៅបុរីកីឡាវិញ ដែលលោកនិយាយអំពីបែងចែកខ្មាំង ហើយនិងមិត្ត។ តើគាត់មានការបែងចែកខ្មាំងផ្ទៃក្នុង ហើយនិងខ្មាំងខាងក្រៅដែរឬទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ជូនម្ចាស់សំណួរថា ខ្មាំង ប៉ុល ពត និយាយឲ្យខ្លីទៅ របបកម្ពុជាប្រជាធិបតេយ្យនេះខ្លាចបំផុត គឺខ្មាំងសត្រូវ គេហៅថា ខ្មាំងស៊ីរូងផ្ទៃក្នុង។ បើខ្មាំងរូបភាព គេបានប្រើពាក្យថា "បើខ្មាំងមានរូបភាព គេមើលឃើញ តែបើខ្មាំងផ្ទៃក្នុងនេះ យើងមើលមិនឃើញទេ"។ អាការមើលមិនឃើញនេះហើយ ដែលកើតជាបង្កើតគោលការណ៍សម្លាប់មនុស្ស នេះមកពីការមិនទុកចិត្តរបស់ថ្នាក់ដឹកនាំលើពលរដ្ឋ ឬលើបុរសណា -- បុគ្គលណាដែលទទួលផែនការ។ អ៊ីចឹងភាពមិនទុកចិត្ត គេមិនទុកចិត្តខ្ញុំ ខ្ញុំមិនទុកចិត្តគេ ការប្រើងប្រែង ប្រឹងប្រុងប្រយ័ត្ន ប្រុងរហូត។ ហើយធាតុពិតវាអ៊ីចឹងមែន ឲ្យតែបុគ្គលណាបក្ស -- ឲ្យតែបុគ្គលណាមានទំនាស់ក្នុងសហករណ៍ អ្នកនៅក្នុងសហករណ៍ ទំនាស់សហករណ៍អ្នកនោះពិតជាបាត់ខ្លួន នេះមួយ។ បើក្នុងអ្នកនៅក្នុងក្រសួងមន្ទីរអាចនឹងប៉ះបាត់អ៊ីចឹងមែន។ ដូច្នេះខ្ញុំមិនដឹងថាយ៉ាងម៉េច សូមជម្រាបបាទ។ សូមអរគុណ។

[១០:៥៨:៤៨]

**ស៖** បាទ សូមអរគុណ។ លោក តើលោកៗថា លោក ប៉ុល ពត ប្រើពាក្យ "កម្ទេចខ្មាំង" ហើយនៅថ្ងៃនេះលោកនិយាយៗ អំពីការកម្ទេចខ្មាំងនេះ តើលោកបញ្ជាក់បានដែរឬទេ ចំពោះថ្នាក់ដឹកនាំខ្មែរក្រហមហ្នឹង ពាក្យថា "កម្ទេចឲ្យក្លាយជាផេះ" ឬក៏ "បំបាត់ចោល" ហ្នឹងមានន័យយ៉ាងម៉េច?

**ឆ៖** ត្រង់ណេះ ខ្ញុំបានឃើញរូបភាព--

**លោក សុន អរុណ៖**

សូមៗកាត់លោកប្រធាន!

**ប្រធានអង្គជំនុំ៖**

សូមសាក្សីកុំអាលទាន់ឆ្លើយ!

សូមអញ្ជើញលោកមេធាវីជាតិការពារក្តីលោក នួន ជា!

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន។ ខ្ញុំយល់ថា សំណួររបស់សហព្រះរាជអាជ្ញានាំមុខ ដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើការស្មាន ឆ្លើយទៅវិញក្នុងការស្មានទាំងអស់ អត់មានអី

ប្រាកដប្រជាទេ។ សូមអរគុណ។

[១០:៥៩:៥៨]

**លោក វ៉ាំងសង់ វ៉ាយជ៍ ដេស្នាឯល៖**

បាទ សូមអរគុណលោកប្រធាន។

ខ្ញុំគ្រាន់តែចង់ដឹងថា ដើមបណ្ដឹងរដ្ឋប្បវេណីនេះ អាចជម្រាបយើងថានៅក្នុងបរិបទនោះ នៅពេលដែលអ្នកដឹកនាំនិយាយថា “កម្ទេច” នេះ គឺថាមានន័យយ៉ាងម៉េច។ ខ្ញុំមិនដឹងចង់ឲ្យគាត់ឆ្លើយស្មានៗនោះទេ គាត់អាចគ្រាន់តែឆ្លើយប្រាប់យើងថា នៅក្នុងបរិបទនោះ គឺថា៧៥-៧៩ នោះ ថាតើពាក្យពេចន៍នោះ មានន័យយ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

បាទ សេចក្ដីជំនាស់ និងមូលហេតុនៃសេចក្ដីជំនាស់ មិនត្រឹមត្រូវ មិនសមស្រប។ អង្គជំនុំជម្រះត្រូវការស្ដាប់នូវចម្លើយតបរបស់សាក្សី ទៅនឹងសំណួរដែលសួរឡើងតំណាងសហព្រះរាជអាជ្ញា។

សាក្សីសូមផ្ដល់ចម្លើយ ហើយចម្លើយរបស់លោក យើងបានប្រាប់ពីមុនហើយ -- អ៎ តំណាងដើមបណ្ដឹងដើមប្បវេណី គឺពេលស្ដាប់សំណួរ ត្រូវស្ដាប់សំណួរឲ្យច្បាស់ ហើយឆ្លើយតបទៅនឹងសំណួរ ប្រសិនបើលោកអត់ដឹង លោកឆ្លើយថាមិនដឹងទេ ចប់ហើយ។ លោកមិនអាចប៉ាន់ស្មាន ឬក៏ឆ្លើយស្មាននូវអ្វីដែលមានការនឹកគិត យល់ខ្លួនឯង ឆ្លើយតបទៅនឹងសំណួរទេ។ ឃើញ ឮ ដឹង ចងចាំ គឺជាក់ច្បាស់អ្វីដែលច្បាស់ខ្លួនឯង សូមឆ្លើយ។ បើមិនច្បាស់ទេ កុំឆ្លើយ។ មិនអាចស្មានបានទេ ឬក៏ប្រហែលបានទេ។ ពាក្យប្រហែល ពាក្យស្មានហ្នឹង គឺមិនមានតម្លៃ ជាភស្តុតាងនៅក្នុងដំណើរក្ដីទេ។

[១១:០១:៤៥]

លោកអាចឆ្លើយបានទេ នូវពាក្យអម្បាញ់មិញនេះ គឺពាក្យថា “កម្ទេច” នេះ ព្រោះលោកបានឆ្លើយអំពីការបទខឡេសនាម វាពាក់ព័ន្ធនឹងភាសានេះ។ តើវាមានអត្ថន័យយ៉ាងម៉េច តាមដែលលោកចងចាំ ឬក៏ដែលធ្លាប់ជួបប្រទះនូវបញ្ហាដែលគេប្រើពាក្យពេចន៍ ពាក្យ “កម្ទេច” នេះ?

**លោក អែម អឿន៖**

**ឆ៖** ខ្ញុំសូមបញ្ជាក់ចំពោះលោកតុលាការ សូមបញ្ជាក់ ខ្ញុំសូមបញ្ជាក់ជូនពាក្យថា “កម្ទេច”ៗ នេះ មិនមែនជារឿងស្មានទេ គឺការពិត របស់ឥឡូវវាអត់មានរូបភាព សូមបញ្ជាក់ថែម។ ការពិត កម្ទេចៗ គឺយកបុគ្គលនោះ ទៅបាញ់ចោលតែម្ដង និយាយត្រង់។ ហ្នឹង រឿងពិត។ ខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹងឯង។

**ស៖** បាទ សូមអរគុណ។ បាទ ឥឡូវ ខ្ញុំសូមត្រឡប់មកនិយាយអំពីសុន្ទរកថារបស់លោក នួន ជា វិញម្តង។ លោកបានលើកឡើងនៅថ្ងៃទី២៣ សីហា មុននេះ ថាបន្ទាប់ពី ប៉ុល ពត ធ្វើសុន្ទរកថាចប់ហើយ នួន ជា បានយកពាក្យរបស់ ប៉ុល ពត មកនិយាយឡើងវិញ មុននឹងចាប់ផ្តើមសុន្ទរកថារបស់គាត់។ តើ នួន ជា មានបាននិយាយអំពីមហាលោតផ្លោះ ហើយនិងខ្មាំងដែលត្រូវកម្ទេចដែរឬទេ?

[១១:០៣:២១]

**ឆ៖** ត្រង់ហ្នឹង ខ្ញុំសូមបញ្ជាក់ ដូចខ្ញុំនិយាយខាងដើម ថាមុននឹងគាត់ធ្វើអ្វីមួយ និយាយអ្វីមួយបន្តទៀត គាត់ទាំងពីរនាក់ ទាំងបីនាក់ ហ្នឹង តែងតែប្រើពាក្យប្រធានបទខាងដើម លោក ប៉ុល ពត ថាយ៉ាងណា គាត់មិនធ្វើអីទៀត និយាយអីទៀត គាត់ប្រើពាក្យថា "ដូចបក្សលោកលើកឡើងថា បើមិនធ្វើតាមដំណើររបស់បក្សទេ។ ទៅ យើងត្រូវតែទទួលខុសត្រូវនូវអ្វីដែលយើង -- ទង្វើដែលយើងធ្វើ"។ នោះ គឺជាពាក្យពិត។ ដូច្នេះ ទាំងបីនាក់ ដែលគាត់លើកឡើងខាងដើម លោក ប៉ុល ពត លើកហើយលោក នួន ជា ក៏លើកដូចគ្នា ហើយលោក ខៀវ សំផន ក៏លើកដូចគ្នា រួចហើយបានគាត់ចាប់ផ្តើមនៃការបង្កើតវិធានបទរបស់គាត់។ ហ្នឹង សូមជម្រាបបាទ។

**ស៖** តើអ៊ីចឹង បានន័យថា លោកមិនកត់សម្គាល់អ្វីទេ នៅក្នុងសុន្ទរកថារបស់ នួន ជា ដែលបង្ហាញថា គាត់នៃសុន្ទរកថារបស់គាត់ហ្នឹង មានភាពផ្ទុយអំពីសុន្ទរកថារបស់លោក ប៉ុល ពត?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា អ៎! តំណាងមេធាវីអន្តរជាតិការពារក្តីឲ្យលោក នួន ជា។

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់និយាយថា នេះជាសំណួរនាំមុខ ហើយខ្ញុំស្នើថា គួរតែមានការរៀបចំសំណួរសាជាថ្មីឡើងវិញ។ សូមអរគុណ។

[១១:០៥:០០]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** បាទ ខ្ញុំសូមរៀបសំណួរឡើងវិញ ដើម្បីឲ្យចំណេញពេលវេលា។ តើលោកមានបានសង្កេតឃើញអ្វី -- ពាក្យពេចន៍អ្វីមួយនៅក្នុងសុន្ទរកថារបស់លោក នួន ជា ដែលបង្ហាញថា នួន ជា មិនយល់ស្របនឹងសុន្ទរកថារបស់ ប៉ុល ពត ដែរឬទេ ទាក់ទង -- ឧទាហរណ៍ទាក់ទងនឹងមហាលោតផ្លោះ

ទាក់ទងទៅនឹងការកម្ទេចខ្មាំងជាដើមនោះ?

**លោក អែម អឿន៖**

**ឆ៖** ត្រង់ហ្នឹង ខ្ញុំសូមបញ្ជាក់ ឆ្លើយបញ្ជាក់បន្ថែម ពាក្យអំមិញថាខ្ញុំហ្នឹងថា លោក នួន ជា ប្រឆាំង។ មិនមែនជារឿងប្រឆាំងទេ គ្រាន់ថាមុននឹងនិយាយអីចេញគោលការណ៍អីពីគាត់ទៀតនោះ គាត់តែងតែរក្សាទុកតម្លៃនៃសំឡេងរបស់លោក ប៉ុល ពត រួចហើយបានគាត់និយាយភាសារបស់គាត់ណាគាត់គិតទុកជាមុនយ៉ាងម៉េចៗបានគាត់ប្រើអនុសាសន៍របស់គាត់ផ្ទាល់។ ហ្នឹងខ្ញុំគ្រាន់តែនិយាយថាមុននឹងធ្វើអីមួយសម្រាប់គំនិតរបស់គាត់ផ្ទាល់តែម្តង គាត់តែងតែលើកគំនិតរបស់ ប៉ុល ពត ហើយបានលោកធ្វើបន្តទៀត។ សូមជ្រាបបាទ។

[១១:០៦:០៨]

**ស៖** កាលពីថ្ងៃព្រហស្បតិ៍មុននេះ លោកបានលើកឡើងថា គឺថានៅក្នុងពង្រាងប្រតិចារឹកនៅម៉ោង១៤:៣៤ ហើយនិងម៉ោង ១៤:៣៧ លោកនិយាយថា នួន ជា បានលើកឡើងនៅបុរីកីឡា សូមដកស្រង់ពាក្យសម្តី៖ "គឺថាត្រូវរកខ្មាំងបង្កប់នៅក្នុងបក្សឲ្យឃើញ ហើយគាត់និយាយនេះយ៉ាងមុតមាំថានៅក្នុងឋានៈជាមេដឹកនាំយើងត្រូវដឹងថាអ្នកណាជាអ្នកប្រឆាំងបក្ស ហើយអ្នកណាដែលបង្កប់នៅក្នុងជួរបក្ស"។ សូមបញ្ចប់ការដកស្រង់។ ហើយលោកក៏បានលើកឡើងផងដែរថា នួន ជា បានវាយប្រហារបញ្ញាជន ហើយនិងនិស្សិតមកពីបរទេសនៅក្នុងសុន្ទរកថារបស់គាត់នោះ។ តើ នួន ជា -- បាទនៅក្នុងការអន្តរាគមន៍គាត់ដដែលនោះ តើគាត់មានបានផ្តល់ឧទាហរណ៍ជាក់លាក់អី? ឧទាហរណ៍ដូចជាឈ្មោះកម្មាភិបាលបក្ស ដែលត្រូវបានចាត់ទុកថាជាជនក្បត់ ឬក៏ខ្មាំងបង្កប់នោះ។ តើគាត់មានឲ្យឧទាហរណ៍អ្វីទេ? ឲ្យឈ្មោះអីទេ?

[១១:០៧:២៦]

**ឆ៖** សូម--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

**លោក ហ្សាស្តេ ប៉ោះ**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាប្រតិចារឹកដដែលនោះបានរៀបចំ -- បានបង្ហាញថានៅទំព័រទី៨២ ជាភាសាអង់គ្លេសគឺមានសំណួរដូចតទៅនេះ តើ នួន ជា បានពន្យល់បន្ថែមទៀតថា តើអ្នក

ណាត្រូវបានចាត់ទុកថាជាខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងដែរឬអត់? ហេតុដូច្នេះ -- ហើយបន្ទាប់មកខាងដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយតប។ ដូច្នេះ ខ្ញុំគិតថាខាងមេធាវីគួរតែបន្តទៅប្រធានបទដែលទាន់បានសួររួចហើយ អានេះគឺសួររួចរាល់ទៅហើយ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

សូមឆ្លើយតប សំណួរនេះគឺទាក់ទងទៅនឹងឈ្មោះជាក់លាក់ ហើយឈ្មោះជាក់លាក់នេះសំណួរទាក់ទងជាក់លាក់នេះមិនទាន់បានចោទសួរទេ កាលគេចោទសួរមុននោះ គេចោទសួរតែរឿងប្រភេទខ្មាំងទេ អ្នកដែលត្រូវគេចាត់ទុកថាជាខ្មាំង។ អ៊ីចឹងសំណួរខ្ញុំនេះសាមញ្ញទេ អ៊ីចឹងក៏ឆ្លើយនោះ ក៏អាចឆ្លើយឲ្យសាមញ្ញផងដែរ។ នេះជាគោលបំណងនៃសំណួររបស់ខ្ញុំលោកប្រធាន។

[១១:០៨:៣៨]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងសេចក្តីសំអាងហេតុនៃសេចក្តីជំទាស់មិនសមស្រប។ សេចក្តីជំទាស់គ្មានប្រសិទ្ធភាព អង្គជំនុំជម្រះត្រូវការស្តាប់ចម្លើយតបរបស់សាក្សី -- របស់ដើមបណ្តឹងរដ្ឋប្បវេណីតបទៅនឹងសំណួរដែលសួរឡើងដោយតំណាងសហព្រះរាជអាជ្ញាអម្បាញ់មិញនេះ។ សាក្សីឆ្លើយតប!

**លោក អែម អឿន៖**

សូមបញ្ជាក់សំណួរម្តងទៀតបាទៗ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

**ស៖** បាទ សំណួរខ្ញុំអម្បាញ់មិញនេះ គឺចង់ដឹងថា តើ នួន ជា បាទ នៅពេលដែលគាត់ថ្លែងសុន្ទរកថានៅបុរីកីឡានោះ គាត់មានបានឲ្យឈ្មោះកម្មាភិបាលបក្សដែលគេត្រូវចាត់ទុកថាជាខ្មាំងបង្កប់ ឬក៏ជាជនក្បត់ដែរឬទេ?

**លោក អែម អឿន៖**

**ឆ៖** ខ្ញុំសូមបញ្ជាក់ហេតុផលត្រង់នេះ មិនមែនថាលោក នួន ជា មិនលើកសោះទេ នេះសំអាងហេតុឈ្មោះថាអី គាត់លើកមិនមែនថាមិនលើកគាត់លើកថា "ចូរមិត្តកុំយកតម្រាប់តាមដូចនៅក្នុងក្រុងភ្នំពេញ គេហៅថា កុយ ធួន ដែលខ្ញុំបានស្គាល់ឈ្មោះទេ គ្រាន់តែឮឈ្មោះ កុយ ធួន ជាអ្នកក្បត់បក្សនៅក្នុងភ្នំពេញ តែអ្នកនោះជាអ្នកណាខ្ញុំមិនស្គាល់ទេ"។ តែគ្រាន់ថាឮភាសាលោក នួន ជា ប្រើប្រាស់ដូចជាលោកប្រធានភូមិភាគឦសាន លោក កែវ មាស ហៅ យ៉ា អីហ្នឹង តាមដំណើរហ្នឹង រឿងពិតឮតាមសម្តី

គាត់ផ្ទាល់។ នេះគឺជាការអះអាងថា "ចូរអស់មិត្តជាសមាជិកបក្សកុំធ្វើតាមដំណើរនោះ កាលណាអ្នកឯងក្បត់បក្ស ត្រូវតែកម្ទេចចោលដូចពួកអស់នោះ ដូចជានៅក្នុងភ្នំពេញការកើតឡើងដូចលោក..." សូមទោសចាំមិនបានឈ្មោះ សូមរំលងចុះបាទ។

[១១:១០:៤២]

**ស៖** តើគាត់ឲ្យឈ្មោះតែពីរនាក់ហ្នឹងទេ ឬក៏គាត់មានបានប្រើឯកសារ ទាក់ទងនឹងអ្នកទាំងអស់នេះ ដើម្បីបង្ហាញជូនទៅដល់អ្នកចូលរួមក្នុងវគ្គសិក្សានេះ?

**ឆ៖** ត្រង់ហ្នឹងមិនមែនគាត់បង្ហាញតែមួយឈ្មោះហ្នឹងទេ ធាតុពិតនោះបង្ហាញច្រើនឯកសារវាច្រើនដែរ ប៉ុន្តែដោយសារខ្ញុំចាំមិនបាន សូមទោសបាទ។

**ស៖** ហើយឈ្មោះដែលគាត់បង្ហាញនៅក្នុងឯកសារនេះ តើ នួន ជា ហ្នឹងគាត់ជាអ្នកមានឯកសារនោះ ឬក៏ -- ឬគាត់ជាអ្នកផ្តល់ឯកសារទាំងអស់នោះទៅអ្នកចូលរួមក្នុងវគ្គសិក្សា?

**ឆ៖** ពាក្យត្រង់ហ្នឹង ក៏មិនមែនជាឯកសារផ្តល់ឲ្យអ្នកនេះចូលរួមទេ តែការពិតគឺជាការនិយាយភាសារបស់គាត់ផ្ទាល់មាត់ តាមដំណើរគាត់អង្គុយអត្ថាធិប្បាយក្នុងឱកាសសាលារៀននេះឯង បាទ។

**ស៖** តើគាត់មានបាននិយាយប្រាប់លោកថា កុយ ធួន ជានរណា ហើយ កែវ មាស នោះ ជាអ្នកណា ហើយគាត់និយាយអំពីអ្វីខ្លះ នៅក្នុងសុន្ទរកថាគាត់នោះ?

**ឆ៖** និយាយត្រង់ហ្នឹង ខ្ញុំដូចបញ្ជាក់អម្បាញ់មិញថា ឯកសារមិនមែនមួយទេ គឺមានច្រើន ប៉ុន្តែដោយសារវែងវាឆ្ងាយពេក ខ្ញុំមិនអាចចាំបានអស់។ អ៊ីចឹងគោលការណ៍ខាងដើមមុននឹងនិយាយអំពីលោក កុយ ធួន លោក -- គាត់បាននិយាយអំពី ចាន់ ចក្រី ជាមេទ័ពសម័យនោះដែរ គឺ ចាន់ ចក្រី គាត់ប្រាប់ថា ចាន់ ចក្រី មានគំនិតបំបះបំបោរបំផ្លាញបក្ស នោះនៅពេលដែលខ្ញុំមុនមករៀន គឺគាត់បញ្ចេញតាមឯកសារនេះឯង។ នេះគឺជាភាសារបស់លោក នួន ជា ការពិតនោះគឺ ឃើញហេតុផលចាប់ជាបន្តបន្ទាប់មែន។ ដូច្នេះ ខ្ញុំខ្លាចណាស់នៅពេលនោះ ក៏រហូតដល់មិនប៉ាននិយាយអីទាំងអស់។ បាទ សូមអស់បាទ។

[១១:១៣:១២]

**ស៖** ទាក់ទងទៅនឹងបញ្ញាជន ហើយនិងនិស្សិតមកពីបរទេស លោកបានលើកឡើងថា "នួន ជា បានវាយប្រហារពួកគាត់ទាំងអស់នេះ នៅក្នុងវគ្គសិក្សាហ្នឹង"។ តើ នួន ជា មានបានប្រាប់ពី -- ពីមូលហេតុដែលគាត់បន្ទុះបង្អាប់ទៅនិស្សិត ហើយនិងអ្នកដែលមកពីបរទេសទាំងអស់ហ្នឹងដែរឬទេ?

គាត់និយាយវាយប្រហារហ្នឹងមានមូលហេតុអ្វីដែរ?

**ឆ៖** ពាក្យថា "វាយប្រហារ" នេះ មូលហេតុដោយសារ គាត់ឃើញថា និស្សិតទាំងអស់នោះ មិនបានបំពេញអី កាតព្វកិច្ចអី នៅក្នុងប្រទេសរបស់ខ្លួន។ អ៊ីចឹងទៅសិក្សានៅបរទេសមានន័យថា អ្នកទាំងអស់ទទួលមនោគមន៍វិជ្ជាពីបរទេស។ ដូច្នេះ គាត់យល់ថា និស្សិតទាំងអស់ សុទ្ធតែទៅទទួលមនោគមន៍វិជ្ជាពីបរទេស ដើម្បីបំផ្លិចបំផ្លាញបដិវត្តន៍របស់គាត់។ ហ្នឹងសូមជម្រាបបាទឲ្យច្បាស់។

**ស៖** បាទ សូមអរគុណ។ នៅក្នុងសុន្ទរកថា គាត់នេះ តើគាត់មានបាននិយាយអំពីជនក្បត់ដែលនៅក្នុងបណ្តាញខ្មាំងដែរឬទេ? តើពាក្យ "បណ្តាញខ្មាំងនេះ" លោក នួន ជា បាននិយាយពីពាក្យហ្នឹងទេពីខ្សែខ្មាំង?

[១១:១៤:៤៥]

**ឆ៖** បណ្តាញខ្មាំង មិនមែននិយាយភាសាហ្នឹង មិនមែននិយាយតែលោក នួន ជា ទេ ឲ្យតែថ្នាក់ដឹកនាំចាប់តាំងពីថ្នាក់ឃុំ មេឃុំតាមមូលដ្ឋានឃុំឡើងទៅ ព្រោះខ្ញុំបានចូលរួមតាំងពីនោះមកដល់ណេះ ខ្ញុំអាចចូលរួមបានច្រើនណាស់។ ឯភាសាដែលប្រើពាក្យថា "បណ្តាញៗ" នេះឯងគឺគេមើលឃើញតាមដំណើរ។ យ៉ាងណាមិញ ដូចជានិស្សិតៗ តាំងថាៗ មានរីកចម្រើនអីដល់ជាតិ គឺវាតែងតែយល់ថា អ្នកដែលបានទៅក្រៅ -- គឺអ្នកទៅក្រៅទាំងអស់នោះមិនមែនជាអ្នកគិតគូរសុខទុក្ខៗរបស់ជាតិទេ។ ដូច្នេះអស់មិត្តគួរកុំធ្វើតាមបញ្ញវន្ត អត់បានប្រយោជន៍។ ហ្នឹងគឺភាសារបស់គាត់ តែគោលដៅរបស់គាត់យ៉ាងណានោះ ខ្ញុំគ្រាន់តែស្តាប់តាមភាសានយោបាយ។ សូមជ្រាបបាទ។

**ស៖** តើលោកមានបានឮ នួន ជា និយាយក្នុងសុន្ទរកថារបស់គាត់ ឬក៏មេដឹកនាំផ្សេងទៀតនោះជាពិសេសពេលគាត់និយាយអំពី កុយ ធួន, កែវ មាស ហើយនិង ចាន់ ចក្រី ហ្នឹងតើគាត់មានបាននិយាយអំពីអត្ថិភាពនៃខ្សែបណ្តាញគិញដែរឬទេ?

[១១:១៦:១៣]

**ឆ៖** ត្រង់ហ្នឹង អ្នកតាំងសំណួរសូមពិចារណាថា យល់ថាការនិយាយនេះហាក់ដូចជាច្រំដែរសំណួរហ្នឹងណ៎ា ព្រោះខ្ញុំបានបញ្ជាក់ហើយថាបណ្តាញៗវាល្អិតល្អោចណាស់។ កាលណាយើងនិយាយល្អិតល្អោច វាខាតប៉ះពាល់ពេលវេលា ហាក់ដូចជានិយាយដដែល។ ពីព្រោះលោក នួន ជា គាត់ថាអ៊ីចឹង លោក ខៀវ សំផន ក៏ពាក្យអ៊ីចឹង។ ម្ល៉ោះហើយខ្ញុំបកស្រាយចុះឡើងៗ ហាក់ដូច--

**ប្រធានអង្គជំនុំ៖**

លោកសាក្សីស្តាប់សំណួរឲ្យបាន រឿងគឺលោក លោកចេះនិយាយឆ្លើយតបហ្នឹង លោកមិនស្តាប់សំណួរដែលសួរទេ។ លោកបានញ៉ែកញាប់ គឺយើងចាកចេញពីសំណួរដែលសួរ ឬក៏ពន្លាតទៅនៅអ្វីដែលមិនឆ្លើយតបទៅនឹងភាពចាំបាច់ នៃការឆ្លើយតបទៅនឹងសំណួរ។ អ៊ីចឹងហើយបានមានសំណួរបន្ថែម។ ទី២ គឺលោកត្រូវឆ្លើយតបទៅនឹងសំណួរ លើកលែងតែយើងមិនឲ្យលោកឆ្លើយតប ដោយមូលហេតុមានសេចក្តីជំទាស់ ឬដោយឆន្ទានុសិទ្ធិ។ លោកស្តាប់សំណួរម្តងទៀត ហើយឆ្លើយតប សូមឆ្លើយតបទៅនឹងកម្រិតភាពចាំបាច់នៃការសួរបានហើយ!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៏ ដេស្នាឯល៖**

**ស៖** លោកប្រធាន បាទ ខ្ញុំសូមរៀបសំណួរខ្ញុំឡើងវិញ។ តើ នួន ជា នៅពេលដែលរូបលោកនិយាយអំពីខ្មាំង ឬក៏ជនក្បត់ លោកបានឲ្យឧទាហរណ៍ទាក់ទងលោក កុយ ធួន, កែវ មាស, ចាន់ ចក្រី តើគាត់មានបាននិយាយពីគិញដែរឬទេ? បាទ នេះខ្ញុំកំពុងនិយាយអំពីបណ្តាញគិញ។

**លោក អែម អឿន៖**

**ឆ៖** បាទ មាន១ បាទ។ មាននិយាយពីបណ្តាញគិញ។ សូមបន្តទៀតចុះ។

[១១:១៨:៣៥]

**ស៖** តើគាត់មានបាននិយាយអំពីបណ្តាញគិញ ដែលមានសកម្មភាពនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ហើយមាននិយាយថា បណ្តាញគិញនោះមកពីប្រទេសណាដែរឬទេ?

**ឆ៖** បាទ មាន។ សូមបន្ថែមតសួរ -- បន្តសួរទៀតចុះបាទ គ្រាន់ថា មាន។ សូមបញ្ជាក់បន្ថែមថា ឈ្មោះថាមាននេះ គឺមានភាគច្រើនបន្តទៅមាន គឺការចោទប្រកាន់នេះផ្តួលភាគច្រើនទៅលើប្រទេសអាមេរិក និងប្រទេសសូវៀត។ បាទ មានប៉ុណ្ណឹងបាទ។

**ស៖** សូមអរគុណ។ តើលោកមានចាំឈ្មោះដែលគេឲ្យដែរឬទេ ទាក់ទងទៅនឹងបណ្តាញគិញអាមេរិក និងសូវៀតនោះ តើគេមានឲ្យឈ្មោះទេនៅពេលនោះ?

**ឆ៖** បាទ មានឈ្មោះ បើទៅខាងភ្នាក់ងាររបស់អ្នកចារកម្មនោះ គឺឈ្មោះអាមេរិក គឺ សេ.អ៊ី.អា។ បើបណ្តាញរបស់សហភាពសូវៀត គេឲ្យឈ្មោះថា កា.ហ្សេ.បេ។ បើមួយទៀត ខ្ញុំសូមបន្ថែមមួយខ្ញុំមិនបាននិយាយអំមិញ មួយទៀតគេចោទប្រកាន់ទៅលើបណ្តាញយួន ភ្នាក់ងារយួន១លេបទឹកដី។

នេះភាសារបស់ ប៉ុល ពត -- អំ របស់លោក នួន ជា បាទ។

**ស៖** នៅពេលដែលលោកឮ នួន ជា និយាយអំពីជនបង្កប់ ហើយនិងគាត់ឲ្យឈ្មោះជាដើមនោះ ហើយនិងនិយាយអំពីជនក្បត់នោះ តើលោកមានប្រតិកម្មយ៉ាងម៉េចដែរ នៅពេលដែលលោកស្ដាប់ឮការនិយាយទាំងអស់នេះ? តើលោកបញ្ចេញប្រតិកម្មរបៀបណា? លោកភ័យ ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំសូមបញ្ជាក់ ឮសំឡេងនេះ ភាសានេះ ប្រហែលមិនមែនតែខ្ញុំទេ ប៉ុន្តែបើកាលណានិយាយទៅវាចាកប្រធាន ខ្ញុំទោសថាខ្ញុំឮភ័យ។ ខ្ញុំឮពាក្យអ៊ីចឹងភ័យបាទ។

[១១:២១:១៩]

**ស៖** បាទ សូមអរគុណ។ បាទ ឥឡូវនេះខ្ញុំសូមត្រឡប់មកនិយាយអំពីសុន្ទរកថារបស់លោក ខៀវ សំផន វិញម្ដង។ ខ្ញុំមានសំណួរដដែល គឺថាលោកមានបានកត់សម្គាល់ទាក់ទងទៅនឹងអ្វីដែលលោក ខៀវ សំផន និយាយនោះ តើមានព័ត៌មានណាដែលបង្ហាញថាគាត់មិនយល់ស្របនឹងអ្វីដែលបានលើកឡើងដោយ ប៉ុល ពត និង នួន ជា គាត់បាននិយាយមុនលោក ខៀវ សំផន នោះ?

**ឆ៖** ត្រង់ហ្នឹង ខ្ញុំសូមបញ្ជាក់បន្តសម្ដីខាងដើមមុននឹងគាត់ធ្វើការមានចេញនយោបាយពីគាត់ គឺគាត់ច្រើនតែប្រើពាក្យដូចៗគ្នាខាងដើម។ តែជាគោលការណ៍តាមខ្ញុំចាំបាន ដើម្បីជួយកែមុខ គាត់ថាដើម្បីជួយកែមុខដល់ជនដែលជាអ្នកក្បត់បដិវត្តន៍ ហើយឈ្មោះថាជនដែលស៊ីរូងផ្ទៃក្នុង ចូរអស់មិត្តពិនិត្យមើលគោលការណ៍ដែលយើងធ្វើដាច់ខាតដើម្បីឲ្យដឹង ឆាប់ដឹងស្គាល់មិត្ត សត្រូវ យើងទាល់តែបង្កើតពាក្យថា “បង្កើនការងារឲ្យបានច្រើន ហូបបាយបានតិច ការងារបង្កើនច្រើន សម្រាកតិច”។ អាហ្នឹងសូម -- ហ្នឹងជាការចាំ ការយល់របស់ខ្ញុំ។ មិនយល់ទេ ការពិតឮតាមត្រចៀក។ សូមលោកទទួលបាទ។

[១១:២២:៤៣]

**ស៖** បាទ សូមអរគុណ។ កាលពីថ្ងៃព្រហស្បតិ៍មុននេះ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបានអានសម្រង់មួយ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោកនោះ ទាក់ទងទៅនឹងសុន្ទរកថារបស់លោក ខៀវ សំផន។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាងឈៈ**

សូមលោកប្រធាន សូមអនុញ្ញាតអានសម្រង់នេះឡើងវិញ ក៏ប៉ុន្តែចោទសំណួរផ្សេង។ ទាក់ទងទៅនឹងខ្លឹមសារនៃសម្រង់នេះ។ ខ្ញុំសូមអានសម្រង់នេះជាពីរផ្នែក គឺថាជាឯកសារដដែលទេ គឺថា

ឯកសារ D22/3963។ គឺថាជាភាសាខ្មែរគឺ ERN 00573979, ជាភាសាអង់គ្លេសគឺ 007 -- គឺថា 51867, ជាភាសាបារាំងគឺ 00786186។ លោកប្រធានសូមអនុញ្ញាតបញ្ចាំងឯកសារនេះនៅលើអេក្រង់ផងដែរ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១១:២៤:០៥]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្ហាឯល៖**

បាទ ខ្ញុំសូមអានផ្នែកទី១ ហើយនិងចោទសំណួរមួយចំនួន។ បាទចម្លើយរបស់លោកគឺថា លោកនិយាយថា "ថ្ងៃទី៤ ថ្ងៃទី៥ ខ្ញុំឃើញ ខៀវ សំផន។ ជាដំបូង គឺថាគាត់រំឭកអំពីពាក្យពេចន៍របស់ នួន -- អ៊ំ ប៉ុល ពត, នួន ជា ហើយបន្ទាប់មកទៀត គាត់និយាយអំពីគោលនយោបាយយុទ្ធសាស្ត្រដែលអនុវត្តដោយអង្គការ។ ហើយគាត់បានប្រាប់យើងផងដែរថា "សមមិត្តទាំងអស់ យើងត្រូវតែមើលៗការជោគជ័យរបស់បក្ស ហើយនិងអង្គការ ហើយនិងត្រូវដើរតាមគោលការណ៍បក្ស។ បើសិនជាអង្គការផ្តល់ការងារអ្វីឲ្យយើងធ្វើ យើងត្រូវតែបំពេញជាដាច់ខាត"។ បាទសូមបញ្ចប់ការដកស្រង់ត្រង់នេះសិន។

បាទសំណួរទី១ របស់ខ្ញុំទាក់ទងទៅនឹងគោលនយោបាយយុទ្ធសាស្ត្ររបស់អង្គការ។ តើលោកអាចពន្យល់អំពីខ្លឹមសារនៃពាក្យ "គោលនយោបាយ យុទ្ធសាស្ត្ររបស់អង្គការ" បានដែរឬទេនៅសម័យនោះ? តើលោក ខៀវ សំផន មានបាននិយាយអំពីគោលនយោបាយយុទ្ធសាស្ត្រនេះដែរឬទេ?

**ឆ៖** សូមបន្ថែមព្រោះស្តាប់អត់បាន។ បន្ថែមសំណួរស្តាប់អត់បាន!

**ស៖** បាទ នៅក្នុងសម្រង់ដែលខ្ញុំបានអាននេះ គឺជាបកប្រែទៅជាភាសាបារាំង គឺថាជាពាក្យពេចន៍របស់លោក គឺថា "មានលើកឡើងថា នួន ជា និយាយអំពីគោលនយោបាយយុទ្ធសាស្ត្រដែលអង្គការអនុវត្ត" តើលោកអាចពន្យល់បានដែរឬទេ អំពីពាក្យថា "គោលនយោបាយយុទ្ធសាស្ត្រ" ដែលអង្គការអនុវត្តនេះ? ដូចដែលលោក ខៀវ សំផន បានពន្យល់?

[១១:២៦:០៧]

**ឆ៖** គោលនយោបាយយុទ្ធសាស្ត្រ នេះមិនមែនថាយុទ្ធសាស្ត្រតែ លោក ខៀវ សំផន ទេ គឺជាយុទ្ធសាស្ត្ររបស់បក្សបដិវត្តន៍កម្ពុជា។ ខ្ញុំបញ្ជាក់ថា ប៉ុន្តែនៅក្នុងឱកាសនោះ លោក ខៀវ សំផន បានបញ្ជាក់ក្នុងឋានៈគាត់ជាអ្នកដឹកនាំរដ្ឋ។ អ៊ីចឹងមុននឹងធ្វើអីគាត់និយាយអស់ពីគោលការណ៍ដែលត្រូវយើង

ធ្វើ។ ពិសេសបំផុត ក្នុងឱកាសនោះ គឺគាត់និយាយសង្កត់ធ្ងន់គឺអ្នកចូលសិក្សានៅពេលនោះតែម្តង។ ពិសេសគឺខ្លាំងបំផុត គឺជាអ្នកមានឈ្មោះថា ជាសមាជិកបក្សៗកុម្មុយនីស្តហ្នឹងឯង។ អ៊ីចឹងលោក ឲ្យឃើញអំពីដំណើរដែលហៅថា ស៊ីរូងផ្ទៃក្នុងបក្សបដិវត្តន៍នោះ យើងជាបក្ស យើងជាសមាជិកបក្ស ដើម្បីឲ្យរឹងប៉ឹងក្នុងជួរបក្ស វាទាល់តែយើងស្គាល់ពីដំណើរការ ភារកិច្ចរបស់យើង។ ក្នុងហ្នឹងដែរ លោកនិយាយបាន -- បាននិយាយជាច្រើនដែរ ប៉ុន្តែក្នុងឱកាសហ្នឹង ខ្ញុំសួរយោបល់លោកខាងចៅក្រម តើអនុញ្ញាតឲ្យខ្ញុំនិយាយបានដែរឬអត់?

[១១:២៧:១៧]

**ប្រធានអង្គជំនុំ៖**

លោកនិយាយកម្រិតត្រឹមតែ តបទៅនឹងសំណួរបានហើយ! ខ្វះចន្លោះបញ្ហាផ្សេងទៀត ចាំស្តាប់សំណួរបន្តទៀត នឹងមាន -- អាចមានសំណួររាប់រយទៀតនឹងសួរលោក មិនមែនតែប៉ុណ្ណឹងទេ។ លោកត្រៀមខ្លួនដើម្បីឆ្លើយតបទៅនឹងសំណួរ ព្រោះនៅមានភាគីដទៃទៀត នៅបីភាគីទៀតដែលត្រូវសួរលោក។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមអរគុណលោកប្រធាន។

[១១:២៧:៥១]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** បាទ នៅក្នុងសម្រង់អម្បាញ់មិញនោះ មានឃ្លាមួយទៀត ដែលខ្ញុំនឹងត្រឡប់មកនិយាយអំពីខ្លះនេះវិញនៅបន្តិចទៀតនេះ។ គឺជាឃ្លារបស់លោក ខៀវ សំផន ដែលនិយាយថា "ត្រូវតែដើរតាមគោលការណ៍របស់អង្គការ បើសិនជាអង្គការឲ្យធ្វើអ្វីមួយត្រូវតែបំពេញដាច់ខាត"។ អម្បាញ់មិញនេះ លោកក៏បាននិយាយអំពីចំណុចហ្នឹងដែរ តើក្នុងឋានៈជាកម្មាភិបាលរបស់បក្សនោះ លោកត្រូវតែគោរពទាំងស្រុងតែម្តងនូវ -- ដើរតាមបក្សទាំងស្រុងតែម្តង ឬក៏យ៉ាងម៉េច?

**លោក អែម អឿន៖**

**ឆ៖** សូមឆ្លើយត្រង់ហ្នឹង គឺដាច់ខាត កាលណាឮហើយគឺត្រូវតែគោរព។ ហ្នឹងសូមមានចម្លើយប៉ុណ្ណឹង។

[១១:២៨:៥០]

**សៈ** អង្គាល់នៅបុរីកីឡានោះ បើតាមលោកដឹង តើអ្នកណាជាអង្គការ ដោយជាក់ច្បាស់តែម្តងនោះ តើមានកម្រិតខុសគ្នាច្រើន នៅក្នុងអង្គការ ហើយតើកម្រិតណាជាកម្រិតខ្ពស់ជាងគេ ថ្នាក់ណាជាថ្នាក់ខ្ពស់ជាងគេនៅក្នុងអង្គការ?

**ឆៈ** ខ្ញុំសូមបញ្ជាក់តបនឹងសំណួរ ឈ្មោះថា "អង្គការ១" បើតាមការយល់បានពីការសិក្សាសម័យនោះឈ្មោះថា "អង្គការ" គឺមនុស្សច្រើននាក់។ សរុបទៅៗបានន័យថា អ្នកណាមានតួនាទីសម្រេចក្នុងការងារដែលបក្សប្រគល់ឲ្យ ហើយតែទៅជាលក្ខណៈគ្នាច្រើន ពីបីនាក់ឡើងទៅហើយថា "អង្គការ" ហើយថា រកអ្នកណាជាប្រធានអង្គការណាធំជាងគេ គឺសម័យនោះ ខ្ញុំមិនបានដឹង សូមជ្រាបតាមត្រង់។ គឺតាមដំណើរការនៃកិច្ចការរបស់បក្ស គឺអ្នកធំជាងគេគឺ ប៉ុល ពត នេះតែម្តង។ អស់ៗចម្លើយបាទ។

[១១:៣០:០០]

**សៈ** បាទ សូមអរគុណ។ តើលោកមានបានឮនិយាយអំពីគណៈអចិន្ត្រៃយ៍ដែរឬទេ នៅក្នុងវគ្គសិក្សានេះ ឬក៏ក្រៅពីវគ្គសិក្សានេះ?

**ឆៈ** សូមឆ្លើយតប។ ឈ្មោះថា គណៈអចិន្ត្រៃយ៍មិនមែនឮតែក្នុងវគ្គសិក្សាទេ ខ្ញុំឮតាំងពីនៅឯមូលដ្ឋាន។ នេះគឺចម្លើយពិតហើយ។

**សៈ** នៅពេលដែលលោកនៅក្នុងមូលដ្ឋានហ្នឹង ថ្នាក់ដឹកនាំនៅមូលដ្ឋានហ្នឹង មានទទួលបញ្ជាពីគណៈអចិន្ត្រៃយ៍ដែរឬទេ?

**ឆៈ** ត្រង់ហ្នឹងខ្ញុំសុំឆ្លើយថា ចំពោះខ្ញុំមាននាទីត្រឹមទទួលតំណែង -- ទទួលបន្តពីប្រធានក្រសួងឬប្រធានតំបន់របស់ខ្ញុំ។ អ៊ីចឹងខ្ញុំមិនអាចដឹងថា លោកទទួលពី ខាងណាទៀតទេ ខ្ញុំអត់ដឹងទេបាទមានតែប៉ុណ្ណឹង។

[១១:៣១:២៣]

**សៈ** សូមអរគុណ។ ខ្ញុំនឹងបន្តអាន អត្ថបទនៃឯកសារដដែលគឺ D22/3963 គឺនៅទំព័រដដែល។ លោកបានសរសេរជាលាយលក្ខណ៍អក្សរនៅក្នុងឯកសារនេះថា លោកនិយាយអំពី ខៀវ សំផនៈ "ជាពិសេស គាត់បានសុំឲ្យកម្មាភិបាលទាំងអស់ប្រុងប្រយ័ត្នខ្ពស់ចំពោះប្រជាជនថ្មី ដែលបើតាមគាត់នោះ នៅជាប់កម្ពែលសក្តិភូមិ។ ខៀវ សំផន បានបញ្ជាក់ថាយ៉ាងច្បាស់ថា ដើម្បីស្វែងរកខ្មាំងដែលបង្កប់នៅក្នុងជួរប្រជាជននោះយើងត្រូវតែផ្តល់ភារកិច្ចលំបាកៗទៅដល់ប្រជាជនមូលដ្ឋាន និងប្រជាជនថ្មី។

នៅពេលធ្វើបែបនេះ ខ្មាំងមិនអាចលាក់នៅក្នុងជួររបស់យើងបានយូរទេ ហើយគាត់បានបន្ថែមទៀតថា ចំពោះកម្មាភិបាលយើង ជាពិសេសមិត្តដែលកំពុងរៀននេះ បើមិត្តណាម្នាក់មិនធ្វើការការងារតាមគោលដៅនោះទេ បុគ្គលនោះក៏ត្រូវបានចាត់ទុកជាសត្រូវរបស់អង្គការផងដែរ ហើយក៏នឹងត្រូវកម្ទេចចោលដោយខានមិនបាន"។ សូមបញ្ចប់ការដកស្រង់។

នៅពេលដែល ខៀវ សំផន និយាយអំពីប្រជាជនថ្មីដែលថា "នៅជាប់កម្អែលសក្តិភូមិ" តើលោកអាចពន្យល់ថាបានទេ ថាលោកដឹងអ្វីខ្លះអំពីសក្តិភូមិនៅសម័យនោះ? តើគេមានពន្យល់លោកអំពីវណ្ណៈសក្តិភូមិទេ?

[១១:៣៣:០២]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប! សូមអញ្ជើញលោកមេធាវីជាតិការពារក្តីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ លោកប្រធាន។ ខ្ញុំបាទសុំជំទាស់ចំពោះការធ្វើសេចក្តីសន្និដ្ឋានមួយបញ្ជាក់ទៅលើថា អ្វីដែលមាននៅក្នុងកំណត់នេះ ថាជាសម្តីរបស់លោក ខៀវ សំផន ។ ការពិតទៅសំណេរដែលមាននៅក្នុងឯកសារនេះ គឺឯកសារ D22/3963 នេះវាជាសំណេររបស់ដើម្បីបណ្តឹងរដ្ឋប្បវេណីដែលគាត់បានអះអាងថាជាសម្តីរបស់លោក ខៀវ សំផន។ អ៊ីចឹងសូមឲ្យ នៅពេលដែលសហព្រះរាជអាជ្ញាលើកយោងថា ជាសម្តីរបស់លោក ខៀវ សំផន នោះ គឺសូមបញ្ជាក់ឲ្យបានច្បាស់ផងថាវាមិនមែនជាសម្តីរបស់លោក ខៀវ សំផន ទេ តែវាជាការអះអាងរបស់ដើម្បីបណ្តឹងរដ្ឋប្បវេណីថាជាសម្តីរបស់លោក ខៀវ សំផន។ បាទ សូមអរគុណ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** សូមអរគុណច្រើនណាស់ខាងមេធាវីការពារក្តីដែលបានរំឭកខ្ញុំ។ ខ្ញុំអាននេះ គឺខ្ញុំអានពីចម្លើយរបសដើមបណ្តឹងរដ្ឋប្បវេណីដែលបានគាត់និយាយថា នេះជាសម្តីរបស់លោក ខៀវ សំផន។ ដូច្នេះគឺគាត់នេះហើយជាអ្នកនិយាយថា គាត់ចូលរួមនៅក្នុងវគ្គសិក្សាដែលមានលោក ខៀវ សំផន ធ្វើបទឧទ្ទេសនាម។ ដូច្នេះខ្ញុំយល់ថា ដូចជាមិនមានអ្វីដែលត្រូវជំទាស់នឹងសំណួរនេះទេ ហើយសំណួររបស់ខ្ញុំនេះវាមានលក្ខណៈច្បាស់លាស់ណាស់ គឺមិនមានការសង្ស័យអ្វីនោះទេ។

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយតបទៅនឹងសំណួរ!

[១១:៣៥:០០]

**លោក អែម អឿន៖**

**ឆ៖** សូមបញ្ជាក់ម្តងទៀត។ អំមិញដូចជាភ្លេចភាំង ស្តាប់មតិខាងក្រៅបាទ។ សូមបញ្ជាក់បន្ថែម។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** បាទ អ៊ីចឹងនៅក្នុងសម្រង់នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោកនេះ លោកបានឆ្លើយថា ខៀវ សំផន បានសុំឲ្យកម្មាភិបាលហ្នឹងប្រុងប្រយ័ត្នខ្ពស់ចំពោះប្រជាជនថ្មី ដែលគាត់គិតថាមានជាប់កម្អែលសក្តិភូមិ តើ ខៀវ សំផន មានបានពន្យល់ឲ្យបាន -- ឲ្យលោកដឹងទេថា អ្វីជាសក្តិភូមិ នៅក្នុងវគ្គសិក្សាដែលលោកបានចូលរួមនៅបុរីកីឡានោះ?

**ឆ៖** ពេលនោះ ខ្ញុំសូមជម្រាបពេលនោះ ខ្ញុំគ្រាន់តែឮពាក្យនេះ។ តែពាក្យដែលថា សក្តិភូមិខ្ញុំជាអ្នកមិនបានសិក្សាថាជាអ្វីសក្តិភូមិ គឺខ្ញុំមិនយល់ទេ។ ប៉ុន្តែពាក្យនេះគឺជាពាក្យពិតរបស់គាត់អ្នកថា តែជាគោលបំណងគាត់ត្រូវធ្វើអីនោះ ខ្ញុំបាទជាអ្នកឮ ដឹងឮ មិនបានដឹងថាគាត់បំណងធ្វើអីទេ។ ព្រោះខ្ញុំមិនស្គាល់ថាសក្តិភូមិជាអ្វី។ សូមអស់បាទ។

**ស៖** នៅពេលដែលខៀវ សំផន បានសុំឲ្យកម្មាភិបាលទាំងអស់ប្រុងប្រយ័ត្នខ្ពស់ចំពោះប្រជាជនថ្មីនោះ តើគាត់មានពន្យល់ឲ្យបានច្បាស់ទេថា តើពាក្យថា “ប្រុងប្រយ័ត្នខ្ពស់ចំពោះប្រជាជនថ្មី” នោះមានន័យយ៉ាងម៉េចទេ?

**ឆ៖** ការប្រុងប្រយ័ត្ន ខ្ញុំមើលឃើញសកម្មភាពនៅពេលនោះ ឃើញចាប់ផ្តើមដាក់បណ្តាញតាមដាន ម្នាក់តាមម្នាក់ តាមមើលសកម្មភាពទាំងអស់ពិសេសបំផុតដូចខ្ញុំថា ក្នុងឯកសារអ៊ីចឹង ថាខ្លាំងជាងគេបំផុតនោះគឺប្រជាជនដែលគេឲ្យឈ្មោះថា ប្រជាជន១៧ មេសា គេហៅថាប្រជាជនថ្មី។ អ៊ីចឹង យល់យ៉ាងណានោះ គឺជាពាក្យសម្តីពិតដែលគាត់បានលើកឡើងនៅក្នុងបទអត្ថាធិប្បាយក្នុងថ្នាក់នយោបាយពេលនោះឯង។ សូមជ្រាបបាទ។

[១១:៣៧:៣៣]

**ស៖** សូមអរគុណ។ ខ្ញុំមានសំណួរបន្ថែមទៀត ពាក់ព័ន្ធទៅនឹងសម្រង់នៃឯកសារនេះ។ លោក

បានឆ្លើយថា ខៀវ សំផន បញ្ជាក់យ៉ាងច្បាស់ថា ដើម្បីស្វែងរកខ្មាំងបង្កប់នៅក្នុងជួរប្រជាជន យើងត្រូវតែផ្តល់ការងារលំបាកៗទៅដល់ប្រជាជនចាស់ និងប្រជាជនថ្មី។ បើតាមលោកស្តាប់ឮអ្វីដែលលោក ខៀវ សំផន និយាយនោះ តើហេតុអ្វីបានជាយើងត្រូវផ្តល់ការងារលំបាកៗទៅឲ្យប្រជាជនដើម្បីស្វែងរកខ្មាំងនោះ? តើការងារបែបនេះ ជួយក្នុងការស្វែងរកខ្មាំងយ៉ាងម៉េច វែកមុខខ្មាំងយ៉ាងម៉េចដែរ?

**ឆ៖** ត្រង់ ត្រង់ណេះ ខ្ញុំសូមជម្រាបពីបញ្ហាថាធ្វើយ៉ាងណាៗនោះ ខ្ញុំដឹងតែគោលការណ៍ដែលគាត់ឲ្យធ្វើ គឺខ្ញុំចាំបានថា ដំណើរគោលការណ៍របស់បក្សកុម្មុយនីស្តពេលនោះគឺថា ដើម្បីវែកមុខ វែកមាត់អ្នកសត្រូវស៊ីរូងផ្ទៃក្នុងរបស់យើង វាទាល់តែយើងបង្កើនការងារឲ្យខ្ពស់ ធ្វើការងារឲ្យច្រើន សម្រាកឲ្យតិច ស៊ីបាយឲ្យតិច ធ្វើការងារឲ្យច្រើន។ អ៊ីចឹងនោះឯងទើបចេញមុខមាត់អ្នកលាក់ក្នុងពួជ៍ផ្ទៃក្នុងរបស់យើង។ នេះគឺជាពាក្យសម្តីដែលគាត់លើកឡើងក្នុងឱកាសនោះ។ ហើយខ្ញុំឮអ៊ីចឹងក៏ភ័យ ខ្ញុំពិចារណាទៅណាមកណា ទាំងមិត្តខ្ញុំ ក៏ទាំងខ្ញុំក៏ដូចគ្នា មានតែភាពភ័យខ្លាចប៉ុណ្ណោះឯង។ នេះសូមបញ្ជាក់ប្រាប់អ្នកម្ចាស់សំណួរ។

[១១:៣៩:១១]

**ស៖** សូមអរគុណ។ ក្រៅពីប្រធានបទដែលបានលើកឡើងនោះ គឺលោកបាននិយាយអំពីពាក្យថា "មហាអស្ចារ្យ មហាលោតផ្លោះ" "ខ្មាំង" "ប្រជាជនថ្មី"។ តើក្រៅពីនេះ តើ ខៀវ សំផន និង នួន ជា មានបាននិយាយអំពីប្រធានបទផ្សេងទៀតទេ នៅក្នុងវគ្គប្រជុំនេះ បើតាមការនឹកឃើញរបស់លោកនោះ?

**ឆ៖** ក្នុងចំណុចហ្នឹងភាគ -- ឈ្មោះថាសាលាសិក្សានយោបាយ មិនមែនប៉ុណ្ណឹងទេ វាច្រើនតែខ្ញុំមិនអាចចាំបាន។ ហ្នឹងសូមនិយាយលើកឡើងខ្លះៗ ដែលខ្ញុំចាំនោះឯង។ តែគោលការណ៍នោះតាមគោលបំណង ខ្ញុំមិនយល់ថាគាត់លើកនោះដើម្បីអីទេ។ តែខ្ញុំគ្រាន់ពិចារណារកការអនុវត្តរបស់ខ្លួន កុំឲ្យបក្សកម្ទេចខ្ញុំទាំងអស់។ ខ្ញុំសូមជម្រាបត្រង់បាទ។

**ស៖** ប្រសិនបើខ្ញុំយល់មិនច្រឡំទេ គឺមានន័យថា លោកអត់បាននឹកឃើញអំពីប្រធានបទផ្សេងទៀត ដែលវាគ្មិនផ្សេងៗបានលើកឡើងនៅក្នុងវគ្គអប់រំនយោបាយនេះទេ? អ៊ីចឹងមែនទេលោក អែម អឿន?

**ឆ៖** បាទ ត្រង់ហ្នឹងខ្ញុំចាំមិនបានទេបាទ។

**ស៖** សូមអរគុណ។ ខ្ញុំមានសំណួរចុងក្រោយមួយទៀត កាលពីថ្ងៃព្រហស្បតិ៍សប្តាហ៍មុន

លោកបានលើកឡើងនូវពាក្យស្លោកមួយរបស់ខ្មែរក្រហម ពាក់ព័ន្ធទៅនឹងខ្មាំង។ ពាក្យស្លោកនោះគឺមានន័យថា “ទុកក៏មិនចំណេញ ដកចេញក៏មិនខាត”។ តើនៅក្នុងវគ្គអប់រំនយោបាយនៅបុរីកីឡា មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ខ្លួនឯងផ្ទាល់នោះបានប្រើប្រាស់ពាក្យស្លោកមួយចំនួនរបៀបបែបនេះ ហើយបើសិនបើមានប្រើប្រាស់នោះ តើគាត់ប្រើប្រាស់ពាក្យស្លោកអ្វីខ្លះដែរ? សូមលោកជួយជម្រាបន្តិចទៅមើល!

[១១:៤១:២៥]

**ឆ៖** ត្រង់ហ្នឹង បើនិយាយពីពាក្យស្លោក ខ្ញុំចាំមិនបានទេ ព្រោះវាច្រើនណាស់ ប៉ុន្តែខ្ញុំចាំបានតែពាក្យប៉ុណ្ណឹង។ នេះគឺពាក្យពិតដែលគាត់ថា “ទុកក៏មិនចំណេញ យកចេញក៏ខាត”។ អ៊ីចឹងអត្ថន័យនោះយ៉ាងណាទេ -- យ៉ាងណានោះ ខ្ញុំមិនបកស្រាយយល់បានខ្លួនឯងទេបាទ។ សូមជម្រាបបាទ។ គឺចម្លើយគឺមានប៉ុណ្ណឹងបាទ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី ដែលបានចំណាយពេលវេលាឆ្លើយសំណួរ។ លោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំសូមបញ្ចប់ការសួរសំណួរ។

**ប្រធានអង្គជំនុំ៖**

បាទ អស់លោក លោកស្រីចៅក្រមមានសំណួរសួរដល់សាក្សី -- ដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះដែរឬទេ?

បាទ បើមិនមានទេ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ អ៎! ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

សូមអញ្ជើញ!

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន ហើយសូមជម្រាបសួរដល់អស់លោក លោកស្រីទាំងអស់នៅក្នុងសាលសវនាការ ហើយសូមជម្រាបសួរលោក អែម អឿន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

**ស៖** នៅពេលព្រឹកនេះ ខ្ញុំសូមចាប់ផ្តើមជាមួយនឹងសំណួរមួយចំនួន ពាក់ព័ន្ធទៅនឹង ថាតើៗលោកធ្វើយ៉ាងណាទើបអាចក្លាយខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបែបនេះ? ខ្ញុំនឹងព្យាយាមនិយាយឲ្យបាន

យឺតដើម្បីឲ្យអ្នកបកប្រែមានភាពងាយស្រួល។ សំណួរទី១ ដែលខ្ញុំចង់សួរលោក គឺថា តើៗលោកដឹង អំពី អ.វ.ត.ក និងដំណើរការនីតិវិធីរបស់ អ.វ.ត.ក ហ្នឹងជាដំបូងដោយរបៀបណា និងនៅពេលណា?

[១១:៤៤:០២]

**លោក អែម អឿន៖**

**ឆ៖** ខ្ញុំសូមជម្រាបម្ចាស់សំណួរ។ មូលហេតុដែលខ្ញុំដឹង គឺខ្ញុំចង់រកយូរហើយ ប៉ុន្តែដោយសារខ្ញុំមិនស្គាល់ថា កន្លែងណាជាកន្លែងណា។ ក្រោយមកប្អូនខ្ញុំម្នាក់នៅកំពង់ចាម គាត់បានឲ្យខ្ញុំជូនរកផ្ទះ គឺថាមជ្ឈមណ្ឌលឯកសារ ឯខ្ញុំកាលនោះ ទើបតែយល់ថាមជ្ឈមណ្ឌលឯកសារ។ ដល់ពេលមកដល់បានគេនិយាយពីពាក្យបណ្ដឹង ដល់ត្រង់ណោះ ទើបខ្ញុំសូមពាក្យបណ្ដឹងស្គាល់ត្រង់ណោះឯង។ តែខាងដើមកន្លងមក ខ្ញុំមិនស្គាល់ថាកន្លែងណា គេទទួលពាក្យ កន្លែងណាមិនទទួលអត់ដឹងទេ។ មូលហេតុដែលស្គាល់ខាងដើមដំបូងអស់ គឺជូនប្អូនខ្ញុំផ្ទាល់តែម្តង គឺឈ្មោះលោក សរ សារិន ដែលធ្លាប់បានស្គាល់នៅ បានធ្លាប់បម្រើការងារសម័យនោះក្នុងក្រុងភ្នំពេញ ក្នុងឋានៈគាត់ដឹកភ្ញៀវបាទ។ សូមជម្រាបបាទ។

**ស៖** តើលោកអាចជម្រាបឲ្យបានលម្អិតបន្ថែមទេ អំពីលោក សរ សារិន -- សៅ សារិន ថាតើគាត់មានតួនាទីអ្វីដែរ? ឥឡូវនេះ យើង -- ខ្ញុំសូមសួរបន្តទៀត តើលោក សៅ សារិន ហ្នឹង មានតួនាទីអ្វីដែរ?

**ឆ៖** សូមបញ្ជាក់បន្ថែម មិនមែន សៅ សារិន ទេ សរ សារិន។ គាត់មានបន្ទុកការងារនៅពេលនោះ គាត់មានបន្ទុកនាទីរបស់គាត់ បើកឡានជូនភ្ញៀវៗ បរទេស នៅដែលមាននៅប្រចាំនៅកម្ពុជាបាទ។

**ស៖** ប្រសិនបើខ្ញុំយល់មិនខុសទេ គឺថាលោក សរ សារុន ធ្វើការនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ឬមួយក៏មានបញ្ហាបកប្រែទេ?

[១១:៤៦:២៤]

**ឆ៖** សូមបញ្ជាក់បន្ថែម ខាងដើមមក លោក សរ សារិន នេះ ក៏ដូចជាសព្វថ្ងៃនេះដែរ មិនមែនជាមជ្ឈមណ្ឌលទេ ព្រោះគាត់បច្ចុប្បន្ន នៅជាកសិករ ព្រោះគាត់ធ្វើចម្ការ។

**ស៖** អឺចឹង ប្រហែលជាខ្ញុំយល់ខុសហើយ គឺដូច្នេះ ខ្ញុំសូមទោស។ លោកបាននិយាយអំពីទម្រង់ព័ត៌មានជនរងគ្រោះ ដើម្បីបញ្ជាក់ឲ្យច្បាស់ទៅលើបញ្ហានេះ ថាតើអ្នកណាជាអ្នកប្រគល់នូវទម្រង់ព័ត៌មានជនរងគ្រោះជាលើកទី១ ទៅឲ្យលោក?

**ឆ៖** ទម្រង់នៃជនរងគ្រោះនេះ ការពិត ខ្ញុំទទួលបានពីមជ្ឈមណ្ឌលឯកសារព័ត៌មាន ដែលទទួលដំបូងលើកទី១បង្អស់។ ដល់ខ្ញុំមានការឈឺចាប់ពេកកន្លងមក ដល់ពេលរកឃើញផ្លូវនេះ បានខ្ញុំប្រឹងប្រែងដើម្បីនឹកឃើញដល់ការបាត់បង់អាយុជីវិតបងខ្ញុំផង ឪពុកខ្ញុំផង ប្អូនខ្ញុំផង កូនក្មួយផងនោះ។ ខ្ញុំតែងតែស្វែងរកនេះ តែស្វែងរកអត់ដែរបាន ទើបតែឃើញ។ សូមអរគុណ។

[១១:៤៧:៥៤]

**ស៖** ដូច្នេះ គេប្រគល់នូវទម្រង់បែបបទព័ត៌មានជនរងគ្រោះដល់លោក ហើយបើតាមខ្ញុំយល់មិនខុសទេ គឺទម្រង់ព័ត៌មានជនរងគ្រោះទី១ ដែលលោកបានដាក់នៅថ្ងៃ២៥ ខែមករា ឆ្នាំ២០១០ តើបែបនេះមែនដែរឬទេ?

**ឆ៖** នោះជាការពិត។

**ស៖** តើត្រឹមត្រូវដែរឬទេ ដែលថាលោកអ្នកសរសេរនូវទម្រង់បែបបទព័ត៌មានជនរងគ្រោះ គឺថាលោកជាអ្នកសរសេរនូវព័ត៌មានទាំងអស់នៅក្នុងទម្រង់ហ្នឹង ហើយវាជាអក្សរដៃ អក្សរផ្ទាល់ដៃរបស់លោក តើមែនដែរឬទេ?

**ឆ៖** ក្នុងនោះ ខ្ញុំបានសរសេរខាងដើមដំបូងបង្អស់ គឺអក្សរផ្ទាល់ដៃ។ ប៉ុន្តែក្រោយមកខ្ញុំឲ្យៗខាងមេធាវី មិនមែនមេធាវី ឲ្យខាងមជ្ឈមណ្ឌលជួយធ្វើឯកសារឲ្យមួយទៀត ប្រហែលជាមានមួយទៀតខុសពីខ្ញុំ តែការពិត គឺខ្ញុំពឹងឲ្យគាត់ធ្វើ ហើយខ្ញុំបានផ្តិតមេដៃទាំងអស់។ ហ្នឹង សូមជ្រាបបាទ។

[១១:៤៩:២៥]

**ស៖** លោកបានស្នើសុំឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាជួយលោក នៅក្នុងការសរសេរ។ ប្រសិនបើឲ្យច្បាស់ ថាតើលោកសរសេរនូវទម្រង់ទាំងពីរ ឬមួយក៏លោកទទួលបានការជំនួយពីមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការសរសេរនូវទម្រង់ទាំងពីរនេះ តើមួយណាដែរ?

**ឆ៖** សូមបញ្ជាក់បន្ថែម ទម្រង់ទាំងពីរនេះ ខ្ញុំបានលោកខាង មេ -- ន៎ៃ មជ្ឈមណ្ឌលឯកសារខ្ញុំសំណើគាត់ ជួយនូវពាក្យបន្ថែមបំពេញ ប៉ុន្តែអក្សរ គឺអក្សរដៃខាងដើម គឺជាអក្សរខ្ញុំទាំងអស់បាទ។ តែក្រោយមក ខ្ញុំឲ្យលោកខាងមជ្ឈមណ្ឌលបន្ថែមបំពេញឲ្យនោះ គឺៗជាអក្សររបស់ខាងណោះខ្លះ អក្សរខ្លះសូមទទួលស្គាល់បាទ។

**ស៖** នៅពេលដែលលោកសរសេរទម្រង់បែបបទព័ត៌មានទី១ តើមានអ្នកណាផ្សេងគេជួយលោកនៅក្នុងការសរសេរដែរឬទេគឺថា ក្រៅពីទម្រង់ទី១ហ្នឹង តើមានអ្នកណាជួយលោកក្នុងការជួយ

សរសេរទេ?

**ឆ៖** សូមបញ្ជាក់បន្ថែមចំពោះការសរសេរដៃទាំងអស់នេះ អត់មានបុគ្គលណាជួយខ្ញុំឡើយ។ ខ្ញុំគ្រាន់ឲ្យសំណើគេទាំងអស់នេះជួយៗបំពេញបន្ថែមបាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១១:៥១:២០]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនចង់កាត់ផ្តាច់ទេ ក៏ប៉ុន្តែលោកមេធាវីនិយាយអំពីទម្រង់បែបបទទី១ ទី២ ហើយអត់មានផ្តល់លេខឯកសារនៅក្នុងសំណុំរឿងទេ។ មានឯកសារមួយដែលបានផ្តល់ជូនដើមបណ្តឹងរដ្ឋប្បវេណី គឺ -- ដែលមានលេខ D22/3963 ដូច្នេះមិនដឹងថា តើដាក់ទម្រង់មួយណាទេ ដែលលោកមេធាវីសំដៅដល់នោះ? នៅពេលដែលលោកនិយាយថាដាក់ទម្រង់បែបបទទី១ ដូច្នេះសូមលោកមេធាវីបញ្ជាក់ឲ្យបានច្បាស់ ដើម្បីកុំឲ្យមានការយល់ច្រឡំពាក់ព័ន្ធនឹងទម្រង់បែបបទទាំងពីរនេះ។

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមអរគុណចំពោះការស្នើមួយនេះ ហើយខ្ញុំសូមធ្វើការបញ្ជាក់គឺថានៅពេលដែលគាត់បានទទួលនូវ -- គឺយើងនឹងប្រគល់នូវទម្រង់ទាំងពីរនេះជូនទៅដើមបណ្តឹងរដ្ឋប្បវេណី ដូច្នេះខ្ញុំគិតថានឹងមិនមានការយល់ច្រឡំណាមួយដែលធ្វើឡើង ហើយបណ្តាលឲ្យដើមបណ្តឹងរដ្ឋប្បវេណីមានការយល់ច្រឡំនោះទេ។ ដូច្នេះអានេះ គឺយើងនិយាយអំពីទម្រង់ទាំងពីរដែលសរសេរ -- ដែលធ្វើឡើងដោយខាងដើមបណ្តឹងរដ្ឋប្បវេណី។ ដូច្នេះបន្តទៅទៀតនេះ គឺខ្ញុំនឹងសួរអំពីលក្ខណៈជាទូទៅនៃទម្រង់ ដូច្នេះខ្ញុំមិនចង់ឲ្យដើមបណ្តឹងរដ្ឋប្បវេណីគាត់មានការយល់ច្រឡំ ជាមួយនឹងឯកសារពិតប្រាកដអំពីតួលេខអ្វីនោះឡើយ។ ដូច្នេះខ្ញុំមិនចង់និយាយអំពីលេខយោង ឬក៏អ្វីនោះទេ។ ខ្ញុំសូមបន្តទៅទៀតដោយសារតែខ្ញុំគិតថា ដើមបណ្តឹងរដ្ឋប្បវេណីគាត់យល់ច្បាស់ ថាតើខ្ញុំនិយាយអំពីឯកសារណាមួយនោះហើយ។

[១១:៥៣:១៥]

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

**ស៖** ខ្ញុំគិតថា ខ្ញុំអាចបន្តទៅមុខទៀត។ នៅពេលដែលលោកបំពេញនូវទម្រង់បែបបទទី១

លោក អែម អឿន តើលោក សរ សារិន មានវត្តមាននៅទីនោះដែរឬទេ?

**លោក អែម អឿន៖**

**ឆ៖** សូមបញ្ជាក់បន្ថែមការធ្វើនេះមិនមាន សរ សារិន នៅជាមួយទេបាទ។

**ស៖** ដើម្បីកុំឲ្យមានការយល់ច្រឡំ តើលោកអាចពន្យល់បានដែរឬទេថា តើលោក សរ សារិន ហ្នឹងមានតួនាទីអ្វីដែរ នៅក្នុងទម្រង់បែបបទព័ត៌មានជនរងគ្រោះរបស់លោក?

**ឆ៖** សំណួរដូចក្លាប់មិនបាន សូមបញ្ជាក់ម្តងទៀត។

**ស៖** ខ្ញុំនឹងសួរលោក លោកបានបញ្ជាក់អំពីលោក សរ សារិន តើលោកអាចពន្យល់បានដែរឬទេតើលោក សរ សារិន ហ្នឹងគាត់មានជួយ ឬក៏គាត់មានបានធ្វើអ្វីខ្លះទាក់ទងទៅនឹងការដាក់ទម្រង់បែបបទព័ត៌មានជនរងគ្រោះរបស់លោក? តើលោក សរ សារិន ហ្នឹងបានជួយលោកអ្វីខ្លះក្នុងការបំពេញទម្រង់ដែលលោកដាក់មក អ.វ.ត.ក នេះ?

**ឆ៖** សូមបញ្ជាក់បន្ថែម បំភ្លឺឡើងចំពោះពាក្យថា សំណួរច្រឡំមិនមែនទេ ព្រោះ លោក សួរមកសួរទាំង មេធាវី ម្លោះហើយ ខ្ញុំជាអ្នកដើមក្តី ខ្ញុំមិនដឹងឆ្លើយថាម៉េច។ បើសួរខ្ញុំ ខ្ញុំឆ្លើយពិតថា ដូចនិយាយអំមិញថា ខ្ញុំមិនបាន សរ សារិន ហ្នឹង ជួយខ្ញុំទេ តែខ្ញុំដឹងតួនាទីរបស់ខាងដើមមក ខ្ញុំដឹងថា សម័យ ប៉ុល ពត ខ្ញុំដឹងថា គាត់ ជាអ្នកបើកបរឡាននៅក្នុងក្រសួងបរទេស -- ក្រសួងការ បរទេស បាទ។ សូមជម្រាប។

[១១:៥៥:៥៦]

**ស៖** ដូច្នេះ ខ្ញុំនឹងព្យាយាមលើកនូវសំណួរឲ្យបានងាយស្រួល។ តើលោក សរ សារិន ធ្វើអ្វីខ្លះនៅពេលបច្ចុប្បន្ននេះ? ហើយលោកនិយាយថា គាត់ជាកសិករ ប្រសិនបើគាត់ជាកសិករ តើលោកជាកសិករដែរ តើមែនទេ?

**ឆ៖** សួរមេធាវី ឬសួរខ្ញុំ?

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយនៅទីនេះ អ្នកដែលទទួលរង់ចាំស្តាប់សំណួរមានតែលោកទេ។ ភាគីទាំងអស់ និងពាក់ព័ន្ធសួរតែលោកទេ សួរតែលោកមួយ។ យើងបានជម្រាបលោកហើយ ថាលោកនឹងទទួលរងនូវសំណួរច្រើនរយទៀត រយសំណួរទៀត អ៊ីចឹងហើយបានជាយើងកំហិត រំឭកលោកថា ឲ្យស្តាប់សំណួរឲ្យបាន ហើយឆ្លើយតបទៅនឹងភាពចាំបាច់ តបទៅនឹងសំណួរបានហើយ ជៀសវាង

និយាយអូសបន្លាយ វាតចេញក្រៅភាពចាំបាច់ នៃសំណួរវានាំឲ្យខាតបង់ពេលវេលា ហើយនិងសម្ពាធរបស់លោកនៅក្នុងការឆ្លើយតបនឹងសំណួរ និងទទួលរងសម្ពាធយ៉ាងច្រើនជាបន្តបន្ទាប់ទៀត រហូតដល់ចប់កិច្ចដំណើរការនីតិវិធី នៃការតាំងសំណួរដេញដោលនេះ យើងប្រើពាក្យថា "តាំងសំណួរដេញដោលតាមផ្លូវតុលាការ"។

**លោក អែម អឿន៖**

អរគុណ។ សូមបញ្ជាក់ការពិតទៅ គាត់សួរមកចូលចិត្តគាត់ប្រើពាក្យថា មេធាវី ម្ដោះហើយខ្ញុំក្លាប់មិនបានន័យនេះ ខ្ញុំមិនប៊ានឆ្លើយទេ។

**លោក អែម អឿន៖**

**ឆ៖** អ៊ីចឹង ខ្ញុំសូមបញ្ជាក់នូវការពិតដែលគាត់សួរថា បើសិនជា សរ សារិន ជាកសិករ ខ្ញុំកសិករដែរ មែនអត់។ ការពិតណាស់ គឺខ្ញុំកសិករមែនបាទ។

[១១:៥៧:៤៥]

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

**ស៖** តាមដែលខ្ញុំយល់ គឺថាលោកស្គាល់គ្នាជាមួយនឹងលោក សរ សារិន ព្រោះថា លោកនៅក្នុងភូមិជាមួយគ្នា ហើយជាកសិករដូចគ្នា តើមែនទេ?

**ឆ៖** ខ្ញុំសូមជម្រាបម្ចាស់សំណួរថា មូលហេតុដែលខ្ញុំស្គាល់ សរ សារិន នេះ ព្រោះ សរ សារិន នេះ អតីតមកធ្វើការជាមួយប្អូនខ្ញុំ គាត់ហ្នឹងជាប្អូនធម៌របស់ខ្ញុំ។ ប៉ុន្តែបច្ចុប្បន្ន គេកសិករតែនៅឯមណ្ឌលគិរី ឯណោះ ឯខ្ញុំគឺកសិករដែរ ស្ថិតនៅកំពង់ចាមទេ។ អ៊ីចឹងការធ្វើកសិករ គឺកសិករដូចគ្នា។ ប៉ុន្តែមុខរបរផ្សេងពីគ្នា ខ្ញុំធ្វើស្រែ គេធ្វើចម្ការ អ៊ីចឹងភាពស្គាល់ អត់ដឹងទេថា ដឹងឮគ្នា ស្គាល់ៗ ប៉ុន្តែការនិយាយគ្នា អត់មានដែលនិយាយទេ។ សូមជម្រាបម្ចាស់សំណួរ សូមម្ចាស់សំណួរជ្រាបបាទ។

**ស៖** សូមអរគុណចំពោះការបញ្ជាក់បំភ្លឺរបស់លោក។ បន្តទៅទៀតនេះ ខ្ញុំនឹងសួរសំណួរលោកបន្តទៅទៀត ដើម្បីទទួលបាននូវបញ្ហាឲ្យបានច្បាស់លាស់។ តើលោក សរ សារិន បានប្រាប់លោកអ្វីខ្លះអំពី អ.វ.ត.ក?

[១១:៥៩:០៨]

**ឆ៖** កាលណោះ លោក សរ សារិន នេះគាត់បានបញ្ជាក់ថា បើខ្ញុំជាបងធម៌គេហ្នឹងមានការឈឺចាប់ ទៅមជ្ឈមណ្ឌលឯកសារទៅ ទើបមានការតវ៉ាអីបាន។ ដូច ខ្ញុំបានបងឯងធ្លាប់ស្គាល់ ធ្លាប់អីដែរ

គួរតែបងទៅមជ្ឈមណ្ឌលឯកសារ។ ហ្នឹង សូមបញ្ជាក់អ្នកម្ចាស់សំណួរ។

**ស៖** សូមអរគុណ។ ខ្ញុំបានទទួលនូវចម្លើយដ៏ច្បាស់លាស់ហើយ។ តើលោកបានពិភាក្សាជាមួយលោក សរ សារិន គឺពិភាក្សាអំពីការចងចាំរបស់លោក ដែលបានកើតឡើងនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ តើលោកមានបានពិភាក្សាដែរឬទេ?

[១២:០០:០០]

**ឆ៖** ត្រង់នេះ ក្រោយពីពេលដឹងឮហើយ ខ្ញុំតែងសាកសួរថា កម្មវិធីដែលធ្វើពាក្យបណ្តឹងនេះធ្វើយ៉ាងម៉េចៗ? ព្រោះគេ អ្នកធ្វើការនៅខាងក្រសួងការបរទេស។ អតីតកន្លងមក ប្រហែលជាគេយល់នោះសាកសួរមែន។ ហើយគេប្រាប់តម្រង់ថា ធ្វើទម្រង់អីខ្លះ? អ៊ីចឹងគេក៏ប្រាប់តាមទំនងដែលខ្ញុំធ្វើឡើងទៅតាមដំណើរ ទម្រង់ឯកសារមជ្ឈមណ្ឌលនេះឯង។ សូមជម្រាប។

**ស៖** តាមដែលលោកចាំ តើលោក សរ សារិន បានចូលរួមនៅក្នុងវគ្គរៀនសូត្រនយោបាយនៅបុរីកីឡាដែរឬទេ?

**ឆ៖** សូមបញ្ជាក់បន្ថែម បើតាមការយល់អះអាងរបស់គេផ្ទាល់ គឺថាបាន ប៉ុន្តែមិនមែនចូលវគ្គជាមួយនោះទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ មេធាវី។ អរគុណដើមបណ្តឹងរដ្ឋប្បវេណី។ បាទ ឥឡូវនេះដល់ពេលសមល្មមសម្រាក ដើម្បីពិសាថ្ងៃត្រង់ហើយ។ ហើយកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ដល់ពេលត្រូវសម្រាកហើយ។

អង្គជំនុំជម្រះសាលាដំបូងប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី២៨ ខែសីហា ឆ្នាំ២០១២ ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ដែលនឹងបន្តការតាំងសំណួរដេញដោលដោយក្រុមមេធាវីការពារក្តីលោក នួន ជា ហើយនិងមេធាវីពីរក្រុមទៀត។

អង្គជំនុំជម្រះសូមជម្រាបជូនភាគី និងសាធារណជនបានជ្រាបថា នៅរសៀលនេះ អង្គជំនុំជម្រះមិនធ្វើសវនាការលើសំណុំរឿងទេ ដោយអង្គជំនុំជម្រះត្រូវបន្តធ្វើនូវកិច្ចប្រជុំរៀបចំសវនាការ។ កិច្ចប្រជុំរៀបចំសវនាការដែលត្រូវធ្វើនៅរសៀលនេះ នឹងប្រព្រឹត្តិទៅជាអសាធារណៈ។

លោក អែម អឿន ការស្តាប់សក្ខីកម្មរបស់លោក នៅមិនទាន់ចប់នៅឡើយទេ។ សវនាការត្រូវបន្តធ្វើនៅថ្ងៃស្អែកទៀត។ ដូច្នេះ អង្គជំនុំជម្រះសូមអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មនៅព្រឹកថ្ងៃស្អែកទៀត គឺចាប់ផ្តើមពីម៉ោងប្រាំបួន។

[១២:០២:១២]

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ព្រមទាំងសាក្សីបម្រុងផងដែរវិលត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញ ហើយនិងឲ្យអញ្ជើញពួកគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកចំពោះលោក អែម អឿន។ ហើយដោយឡែក សាក្សីបម្រុងសូមឲ្យវត្តមានបម្រុងនៅក្នុងបរិវេណនៃ អ.វ.ត.ក នេះចាប់ផ្តើមពីព្រឹកថ្ងៃស្អែក។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូប ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំខ្លួនគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់ -- ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១២:០៣ នាទី)*